៨

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៤២ ខែ សីហា

ព.ស. ២៥១៤ គ.ស. ១៩៧០

-ភ្នំពេញ-

៨

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : ឈាង ហ័បអាន

និពន្ធនាយក-អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះមុនីកោសល សួរ-ហាយ

លោក ឈឹម-ឈាក លោក ឌឹក-គាម

អ្នកស្រី ពេជ-សល់

# បញ្ជីរឿង


| អត្ថបទ | ទំព័រ |
|---|---|
| **ផ្នែកសាសនា** | |
| ១– អត្ថធម្មប្រទីប ភិក្ខុសីលសំវរោ ជាម-សុផល់ រៀបរៀង | ៨១៥ |
| ២– អត្ថកាមកថា ព្រះមហា អ៊ុង-មាន រៀបរៀង | ៨៣២ |
| **ផ្នែកអក្សរសាស្ត្រ** | |
| ៣– រឿងសាមកុក លោក ឧកញ៉ា នូ-កន ប្រែរៀបរៀង | ៨៤៥ |
| ៤– ជីវប្រវត្តិលោក សុង-ស៊ីវ | ៨៥៧ |
| ៥– រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង | ៨៦៤ |
| ៦– អង្គរ ជាកាយ-ព្រលឹងខ្មែរ (ពាក្យកាព្យ) លោក លី-ធាមតេង រៀបរៀង | ៨៨២ |
| ៧– រឿងវរវង្សសូរវង្ស ចម្លងចេញពីសាស្ត្រាស្លឹករឹត លោក លី-ធាមតេង ពិនិត្យផ្ទៀងផ្ទាត់ | ៨៨៦ |
| **ផ្នែកកំណត់-ប្រវត្តិការណ៍** | |
| ៨- អង្គការអក្សរជាតិខាងវិប្បធម៌ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើប្រាសាទអង្គរ លោក លី ធាមតេង រៀបរៀង | ៩១៨ |


---

## តម្លៃជាវ៖


មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ៛

អាណត្តិសូមដាក់ថា៖ លោកនាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ,
ឲ្យជុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា "

ប.ព

# អត្ថធម្មប្រទីប

## សម្ដែងពីប្រយោជន៍ ៣ យ៉ាង

នមោ តស្ស ភគវតោ

អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះអរហន្តមុនី សម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌ និង ព្រះអរិយសង្ឃ ដោយសេចក្ដីគារព ។

វេលានេះខ្ញុំព្រះករុណាអាត្មាភាព សូមលើកយកប្រយោជន៍ ៣ យ៉ាង ដែលព្រះសម្ពុទ្ធជាម្ចាស់នៃយើងទ្រង់បានសម្ដែងទុកមក ដើម្បីធ្វើជាវត្តប្រតិបត្តិ, មកអធិប្បាយប្រគេន ជូន ផ្សាយតាមទស្សនាវដ្ដីកម្ពុជសុរិយា ទុកជាការត្រិះរិះ នៃពួកពុទ្ធបរិស័ទ ឲ្យសមតាមកាលវេលា ដូចតទៅនេះ :

## ឯប្រយោជន៍ ៣ យ៉ាងនោះគឺ :

១ – ទិដ្ឋធម្មិកត្ថ : ប្រយោជន៍ទាន់ភ្នែក ឬហៅថា ប្រយោជន៍បច្ចុប្បន្ន ។

២ – សម្បរាយិកត្ថ : ប្រយោជន៍ទៅក្នុងលោកខាងមុខ ។

៣ – បរមត្ថ : ប្រយោជន៍ប្រសើរបំផុត ឬប្រយោជន៍សម្រាប់ទៅកាន់ព្រះនិព្វាន ។

## សេចក្ដីអធិប្បាយ

ពាក្យថា : ប្រយោជន៍ដែលលោកបញ្ញត្តឲ្យប្រើក្នុងភាសាបាលីថា បយោជន: បានសេចក្ដីថា ផលដែលសមប្រកប ឬ ផលដែលគួរប្រាថ្នា គួរចង់បាននៃមនុស្សសត្វទូទៅ

ក) ទ្រព្យសម្បត្តិ យសសក្ដិ កិត្តិសព្ទជាដើម ដែលបុរស-ស្ត្រីស្វែងរកបានមកប្រកបតាមសេចក្ដីប្រាថ្នា ជាផលឲ្យកើតសេចក្ដីសុខកាយសប្បាយចិត្ត ឃើញច្បាស់តែក្នុងវេលាដែលមានជីវិតរស់នៅប៉ុណ្ណោះ, តែដល់ពេលស្លាប់ទៅហើយ មិនអាចយកទៅជាមួយកើត ឬជូនដំណើរទៅកាន់ភពខាងមុខបាន យ៉ាងនេះជាដើម ហៅថា ទិដ្ឋធម្មិកត្ថ: ប្រយោជន៍បច្ចុប្បន្ន ។

ព្រះបរមគ្រូ ជាសាស្ដាឯកមួយអង្គទ្រង់ធ្លាប់មានការពិសោធន៍ច្រើនក្នុងរឿងនេះ, ហើយតែងតែមានព្រះទ័យមេត្តាករុណាចំពោះសត្វលោក,

ព្រះអង្គទ្រង់បានណែនាំមនុស្សសត្វគ្រប់គ្នាឲ្យប្រឹងប្រែងធ្វើការងារឲ្យអស់ពីសមត្ថភាព ដើម្បីរក្សានូវជីវភាពជាប្រក្រតី និងពង្រីកជីវភាពធម្មតាឲ្យបានខ្ពង់ខ្ពស់ឡើងទៀត ហើយព្រះអង្គទ្រង់ប្រទានធម៌សម្បទា ៤ យ៉ាង សម្រាប់ឲ្យមនុស្សកសាងជីវភាពក្នុងបច្ចុប្បន្នគឺ:

១- ឧដ្ឋានសម្បទា ប្រែថា ដល់ព្រមដោយសេចក្តីខ្នះខ្នែង ស្រាក់ប្រះទេញឧស្សាហ៍ ។ មនុស្សម្នាក់ៗ ត្រូវមានសេចក្តីព្យាយាមប្រកបកិច្ចការជានិច្ចនិរន្ត កិច្ចការដែលត្រូវប្រកបនោះ គឺត្រូវហ៊ឹកហាត់ខ្លួនប្រាណឲ្យបានស្ទាត់ជំនាញ ឲ្យទៅជាមនុស្សស្ទុះស្ទា សង្វាត ឧហាត ឧស្សាហ៍ធ្វើការអត់ធ្មត់ទឹងការងារ ក្លាហានទឹងការងារ ហ៊ានពុះពារឧបសគ្គ និងសេចក្តីលំបាកគ្រប់យ៉ាង មិនធុញទ្រាន់ នឹងការងារធ្ងន់ឬស្រាលឡើយ ។ មិនព្យាយាមធ្វើការណាដែលប្រកបដោយទុច្ចរិតផ្សេងៗ មានលេងល្បែងភ្នាល់ជាដើម ។ សេចក្តីឧស្សាហ៍ក្នុងផ្លូវចិត្ត សំដៅយកលក្ខណៈនៃសេចក្តីធន់ទ្រាំរបស់ចិត្ត ដែលមិនញញើមចុះចាញ់ធម្មជាតិ មិនញញើមរាថយក្រោយចំពោះសេចក្តីលំបាក ចំពោះការមិនសមតាមបំណង ចំពោះការប្រមាថមើលងាយចំអកឡកឡឺយនៃជនដទៃ ចំពោះសេចក្តីនឿយណាយធុញទ្រាន់ ដែលចូលមកជ្រៀតជ្រែកនៅក្នុងសេចក្តីឧស្សាហ៍របស់ខ្លួន, នេះជាលក្ខណៈរបស់មនុស្សអ្នកមានស្មារតីវីរបុរសក្លាហានអង់អាច យកជ័យជំនះដាច់ខាតនៅលើករណីយនោះ អា

គ្នាសូមលើកឧទាហរណ៍ ដូចជាយើងរៀនសូត្រវិជ្ជាផ្សេង ៗ តាំងពីប្រឡងយកសញ្ញាប័ត្រ ឧបមា Bac I, Bac II, licence, Docteur, Agrégé ជាដើម មិនមែនសំរេចដោយការខ្ជិលច្រអូស មិនមានសេចក្ដីព្យាយាមនោះទេ គឺកើតមកអំពីសេចក្ដីប្រឹងប្រែងឧស្សាហ៍រៀនសូត្រពិត ៗ

រឿងនេះដូចមានពុទ្ធភាសិត ដែលព្រះអង្គទ្រង់បានពោលសរសើរសេចក្ដីឧស្សាហ៍ព្យាយាមថា :

"វិរយេន ទុក្ខមច្ចេតិ" គេឆ្លងទុក្ខបានព្រោះសេចក្ដីព្យាយាម ។ "ឧដ្ឋាតា វិន្ទតេ ធនំ" អ្នកណាដែលស្វះស្វាព្យាយាមរក អ្នកនោះរមែងរកទ្រព្យបាន ។

ពុទ្ធភាសិតមួយកន្លែង ដែលព្រះអង្គសម្ដែងបញ្ជាក់ថា "វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្បទា" កើតមកជាមនុស្សម្នាក់ៗ ទោះបុរសឬស្ត្រី គប្បីព្យាយាមធ្វើការ លុះត្រាតែសម្រេចប្រយោជន៍ ។ ដូច្នេះគួរតែយើងគ្រប់រូបប្រជាពលរដ្ឋរួមគ្នាព្យាយាម តស៊ូកាំងសត្រូវ កុំឲ្យវាមកយាយីយើងបានឡើយ ។

២- អារក្ខសម្បទា ប្រែថា ការដល់ព្រមដោយការរក្សា គឺរក្សាផលប្រយោជន៍របស់ខ្លួនដែលរកបានហើយ មិនឲ្យបាត់បង់ខូចខាតទៅវិញ, ចំណេះវិជ្ជាក្ដី ទ្រព្យសម្បត្តិក្ដី តំណែងការងារក្ដី ដែលជាវត្ថុធាតុសម្រាប់ធ្វើឲ្យជាតិ-សាសនារបស់ខ្លួនឲ្យស្ថិតស្ថេរ ព្រមទាំងមាន

ការចម្រើនលូតលាស់តទៅទៀត ។ ត្រូវរក្សាខ្លួនមិនឲ្យ មានរោគភ័យ វិបត្តិអន្តរាយនានា រក្សាទឹកដី ដែលជាកេរ្តិ៍តំណែលពីដូនតា មិនឲ្យ មានពួកជនជាពាលទុច្ចរិតទាំងខាងក្នុងប្រទេស ក្រៅប្រទេស វាយករបជាន់ ដណ្តើមយកបានឡើយ បើពួកទមិឡអឡេតិរ៍យ មកវាយដណ្តើម យកទឹកដីជាបុព្វសិទ្ធិនៃយើង យើងត្រូវតែមានសេចក្តីក្លាហានវាយប្រហារ តបត ឬច្បាំងប្រឆាំងនឹងពួកវាវិញ ដើម្បីការពាររក្សាទ្រព្យសម្បត្តិទឹកដី របស់ខ្លួនមិនឲ្យបាត់បង់ទៅវិញ បានសេចក្តីថា បើយើងតស៊ូដើម្បី បណ្តេញពួកខ្មាំងទាំងនេះឲ្យចេញផុតពីដែនដី ឈ្មោះថា យើងជាអ្នករក្សា សន្តិសុខឲ្យជាតិ សាសនានិងរដ្ឋខ្មែរ ឲ្យបានគង់វង្ស ឈ្មោះថាជាជន មានការរក្សាថែទាំទ្រព្យសម្បត្តិត្រឹមត្រូវតាមក្បួនតម្រាផង របស់ណា ដែលគេធ្វើឲ្យបាត់បង់ទៅ ត្រូវព្យាយាមរកឲ្យឃើញមកវិញ, របស់ណា ដែលទ្រុឌទ្រោមបាក់បែក ត្រូវព្យាយាមជួសជុលឲ្យបានល្អឡើងវិញ ហើយត្រូវស្គាល់ប្រមាណក្នុងការចាយវាយទ្រព្យសម្បត្តិមិនព្រមឲ្យមនុស្ស គ្មានសីលធម៌ ដណ្តើមយកបានឡើយ ។

៣- កាល្យាណមិត្តតា ប្រែថា ភាពនៃជនជាអ្នកមានមិត្តល្អ មិត្តសប្បុរស ជាអ្នកមានគំនិតមារយាទល្អគួរគប់រកនៃជនទូទៅ ។ បុរស ស្ត្រី អ្នកអាស្រ័យនៅក្នុងស្រុក ឬ និគមជនបទនិមួយៗ ដែលមាន មនុស្សចាស់ក្តីជាក្មេងក្តី, តែជាអ្នកមានកិរិយាមារយាទសណ្តាប់ធ្នាប់បែប

ចាស់ ឬ មនុស្សចាស់ ដែលមានកិរិយាមារយាទជាមនុស្សចាស់មែនទែន គឺជាមនុស្សមានការពិសោធន៍ច្រើន មានការត្រិះរិះច្រើន ជាមនុស្សបរិបូណ៌ដោយសទ្ធា សីល ចាគ និង បញ្ញា ក៏បានទៅគប់ប្រសព្វរាប់រកយកជាមិត្រ ដើម្បីនិយាយចរចាសាកសួរអំពីគតិលោកគតិធម៌ (គឺបញ្ហាជាតិ-សាសនា និងរដ្ឋ) ឲ្យឃើញថាត្រឹមត្រូវតាមរបៀបមេដឹកនាំនៃប្រទេសកម្ពុជាយើងហើយ ត្រូវតែបុរស-ស្ត្រីចូលទៅចម្លងយករបៀបបែបផែនរបស់ជនទាំងនេះ យ៉ាងនេះជាដើម ហៅថា កល្យាណមិត្តតា ។ ពាក្យថា កល្យាណមិត្តនេះ ព្រះសម្ពុទ្ធទ្រង់សម្ដែងថាមាន ៤ ពួក គឺ :

១– ឧបការោ មិត្រមានឧបការៈ (មិត្រជួយឧបត្ថម្ភទំនុកបំរុងយើងគេកល់គ្នា) ។

២– សុខទុក្ខោ យោ មិត្តោ មិត្ររួមសុខរួមទុក្ខ (គឺមិត្ររួមសុខរួមទុក្ខ-មិត្រសុខចិត្តស្លាប់រស់នៅជាមួយគ្នា) ។

៣– អត្ថក្ខាយី មិត្រប្រាប់ប្រយោជន៍ គឺមិត្រប្រាប់ហេតុផល សេចក្ដីសុខចម្រើនដល់គូសម្លាញ់ ដែលធ្លាប់បានរួមរស់នៅជាមួយគ្នា ។

៤– មិត្តានុកម្បកោ មិត្រមានសេចក្ដីអនុគ្រោះ (គឺមិត្រដែលមានចិត្តសន្ដោសប្រោសប្រាណ, បើឃើញមិត្រសម្លាញ់បាន

ប្រព្រឹត្តខុសផ្លូវ កំជួយអនុគ្រោះពន្យល់ណែនាំឲ្យបានប្រព្រឹត្តល្អត្រឹមត្រូវវិញ ។

មិត្តទាំង ៤ យ៉ាងនេះហើយ ដែលជាមិត្តល្អគួរទៅអង្គុយជិតដោយការគោរពបូជាដូចជាមាតានិងបុត្រ ព្រោះថាមិត្តទាំងនេះ ជាមិត្តមានសន្តានចិត្តស្មោះត្រង់ចំពោះខ្លួនយើងគ្រប់រូប ដើម្បីដឹកនាំយើងទៅរកផ្លូវត្រូវផ្លូវសុខសួស្តី ។ កំប៉ុន្តែផ្ទុយទៅវិញ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ហាមមិនឲ្យយើងចូលទៅសេពគប់នឹងមិត្តដទៃទៀត ដែលលោកហៅថាបាប-មិត្ត មិត្តចិត្តអាក្រក់មាន ៤ យ៉ាងគឺ :

១- អញ្ញទត្ថុហរោ មិត្តោ មិត្តគិតតែប្រយោជន៍ផ្ទាល់ខ្លួន (គិតតែប្រយោជន៍ត្រសាប-បង្ហូរចូលខ្លួន) ។

២- វចីបរមោ មិត្តល្អតែសម្តី ល្អតែមាត់ ឯក្នុងចិត្តវិញពោរពេញទៅដោយសេចក្តីអាក្រក់គ្រប់យ៉ាង (មិត្តនេះដូចពាក្យបុរាណថា " ចិត្តជាទេវទត្ត មាត់ជាទេវតា " ) ។

៣- អនុប្បិយភាណី មិត្តនិយាយពាក់ចំណោមឲ្យគាប់ចិត្ត (គឺមិត្តឃើញខុសក៏ស៊ី ឃើញត្រូវក៏ស៊ី) ។

៤- អបាយសហាយោ មិត្តសម្លាញ់ដឹកនាំទៅក្នុងផ្លូវវិនាស ។

មិត្តទាំង ៤ យ៉ាងនេះ ជាមិត្តដែលបុរស-ស្ត្រីគប្បីចៀសវាងមិនត្រូវ

គប់គេឡើយ, តែបើបុរស-ស្ត្រីណាមួយចូលទៅសេពគប់នឹងមិត្រទាំង ៤ ពួកនេះហើយ រមែងធ្វើឲ្យខ្លួនយើងវិនាសអន្តរាយ ចាកសេចក្តីចម្រើន និងខូចកេរ្តិ៍ឈ្មោះអាប់យសដោយពិតប្រាកដ ។

៤-សមជីវិតា ប្រែថាការចិញ្ចឹមជីវិតត្រូវ ឬ ការចិញ្ចឹមជីវិតស្មើ គឺបើមានទ្រព្យសម្បត្តិច្រើនចាយវាយប្រើប្រាស់តិច, បើមានទ្រព្យសម្បត្តិតិចចាយវាយឲ្យតិចចុះមកទៀតឲ្យល្មមរស់បាន ដើម្បីធ្វើការបម្រើជីវិតខ្លួន ជីវិតគ្រួសារ ជីវិតប្រទេសជាតិឲ្យបានសុខដុមរមនា លូតលាស់ចម្រើន ។ ជាបុគ្គលតាំងនៅក្នុងឧត្តមគតិថា: រស់នៅត្រឹមតែរស់ មិនរស់នៅហ៊ឺហាច្រងេងច្រងាងដែលចុះក្នុងតម្រាថា "ជាអ្នកស៊ីចាយខ្ជះខ្ជាយស្វែងរកសេចក្តីសប្បាយឥតប្រយោជន៍" ឬចុះក្នុងតម្រាថា "ជាអ្នកស៊ីចាយចាំ នាំឲ្យរូបកាយមានសុខភាពមិនល្អ" ។ ជាអ្នកចេះចាយវាយទ្រព្យសម្បត្តិឲ្យមានប្រយោជន៍ដល់ខ្លួន និងមានប្រយោជន៍ដល់គ្រួសាររបស់ខ្លួន ។

សម្បទាទាំង ៤ យ៉ាងនេះ ជាសម្បទាសម្រាប់ឲ្យបុរស-ស្ត្រីដែលរស់នៅក្នុងសង្គមជាតិ មានមិត្រល្អ មានសីលធម៌ មានមនុស្សធម៌ ព្រមទាំងឲ្យមានជីវភាពថ្លៃថ្នូរជាមនុស្សពេញសម័យនិយម, មិនមែនជាមនុស្សខុបអំណាចយកបុណ្យសក្តិសង្កត់សង្កិនមនុស្សដូចគ្នា គឺធ្វើឲ្យ

មនុស្សបេះសន្ដោសប្រោសប្រាណ តាមលំអានសុចរិត យុត្តិធម៌ មិនរើកវេកធ្វើអកុសលធម៌ឡើយ ។

២- សេចក្ដីសុខកាយសប្បាយចិត្ត ដែលជាផលកើតអំពីការប្រព្រឹត្តសុចរិតល្អជាប់តាមដួនដំណើរទៅក្នុងភពដែលត្រូវកើត ទៅខាងមុខទៀតបាន បីដូចជាស្រមោលអន្ទោលតាមប្រាណ យ៉ាងនេះជាដើមហៅថាប្រយោជន៍ក្នុងលោកខាងមុខ ឬហៅថាប្រយោជន៍អនាគតកាលក៏បាន ។

ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ឃើញប្រយោជន៍បរលោកសត្វគ្រប់ហើយ ទើបព្រះអង្គទ្រង់មានមេត្តាករុណាដល់សត្វលោក, ក៏ទ្រង់សម្ដែងប្រយោជន៍បរលោកមាន ៤ យ៉ាងទៀតគឺ ៖

១- សទ្ធាសម្បទា ប្រែថា ដល់ព្រមដោយសទ្ធាឬជំនឿ គឺបណ្ដុះជំនឿឲ្យមាននៅក្នុងខ្លួនថា: មនុស្សលោកបានទទួលកំណែងខ្ពស់ទាបជាងគ្នា ឬមានកំឡាំងសង្ខារតិចច្រើនជាងគ្នា មកតែអំពីកម្ម គឺចំណេះវិជ្ជា ឬការងារដែលខ្លួនបានធ្វើតិចឬច្រើនប៉ុណ្ណោះ មិនមែនបានមកអំពីជំនួយអាទិទេពណាមួយមកជួយសង្គ្រោះទេ, មនុស្សដែលមានទ្រព្យសម្បត្តិច្រើនក៏បានមកតែអំពីការព្យាយាម ខំប្រឹងស្វែងរកផ្សំជាមួយនឹងបុណ្យកុសលដែលខ្លួនបានធ្វើទុកមកពីជាតិមុនៗនោះឯង ។ បើនិយាយឲ្យចំទៅពាក្យថា សទ្ធា ប្រែថាជំនឿនោះ បេតសិកមួយក្នុងចំណោម

សោភណចេតសិក គឺចេតសិកល្អៗ ដែលនៅប្រមុខនៃចេតសិកទាំងពួង, សទ្ធានេះឯងហើយ បើបុគ្គលណាមួយយកទៅប្រើខុសផ្លូវ រមែងជួបប្រទះនឹងសេចក្តីទុក្ខលំបាកពុំខាន ។ ឧទាហរណ៍ ដូចជាយើងជឿពាក្យឃោសនាបោកប្រាស់របស់ពួក យៀកម៉ិញ-យៀកកុង និយាយថា: វាមកជួយរំដោះប្រទេសខ្មែរឲ្យផុតអំពីការជិះជាន់នៃពួកអាមេរិកាំង, បើកាលណាវាច្បាំងឈ្នះហើយ វានឹងប្រគល់ទឹកដីនេះមកឲ្យខ្មែរវិញ ។ សូមអស់លោកពិចារណាថា: តើយៀកកុង-យៀកម៉ិញមានសទ្ធាអ្វីម្ល៉េះ? តើវាមកជួយបាញ់សម្លាប់ទាហានខ្មែរ-យុទ្ធជនខ្មែរយើងយ៉ាងហ្នឹងឬ ? ។ តែបើបុរស-ស្ត្រីណាមួយប្រើសទ្ធាខុសវិចារណញ្ញាណដូច្នេះហើយ សេចក្តីទុក្ខលំបាកវេទនា ប្រាកដជានឹងត្រឡប់មកកាន់បុរស-ស្ត្រីនោះយ៉ាងជាក់ច្បាស់ ។

អាស្រ័យហេតុដូចដែលបានអធិប្បាយមកខាងលើនេះ លោកបានពន្យល់ថា កាលបើអ្នកណាមួយយកបញ្ញាទៅប្រើអែបជាមួយនឹងសទ្ធាផង; ទើបអាចធ្វើកុសលអ្វីមួយបានសម្រេចល្អ ព្រោះថាព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ពន្យល់ថា បើបុគ្គលណាយកសទ្ធាទៅប្រើ ត្រូវបញ្ចូលជាមួយនឹងសទ្ធាឲ្យកើតទៅជាសទ្ធាបញ្ញា, ទើបត្រិះរិះនូវហេតុផលបានល្អប្រពៃ ។

២- សីលសម្បទា ប្រែថាដល់ព្រមដោយសីល គឺធ្វើខ្លួនឲ្យ

មានកិរិយាមារយាទ បរិយាសណ្ដាប់ធ្នាប់ល្អ វៀរចាកការជិះជាន់បៀត-បៀនអ្នកដទៃ ដោយប្រើអំណាចបុណ្យសក្ដិ ឬដោយកម្លាំងទ្រព្យ ឬក៏វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការនិយាយកុហកយ៉ាងនេះជាដើមហៅថា សីលសម្បទា ។ ពាក្យថា សីល ប្រែថាការរក្សាកាយវាចាឲ្យមានរបៀបរៀបរយ ដែលប្រាសចាកអំពើអកុសល គឺត្រូវប្រព្រឹត្តអាកប្បកិរិយាទន់ភ្លន់សុភាពរាបសា មិនបៀតបៀនញុះញង់អ្នកដទៃឲ្យគេបានសេចក្ដីក្ដៅក្រហាយជាដើម នេះជាលក្ខណៈរបស់សីល ។ ពួកយៀកកុង-យួនខាងជើង គ្មានសីលអ្វីបន្ដិចបន្តួចទេ, បើកាលណាពួកវាទៅដល់កន្លែងណាហើយ វាបំផ្លាញទ្រព្យសម្បត្តិរដ្ឋ ដូចជាស្ពានផ្លូវថ្នល់ ទ្រព្យសម្បត្តិអ្នកស្រុកជាដើម ពួកវាដាក់គ្រាប់បែក-មីន ធ្វើឲ្យបាក់បែកស្ពាន-ផ្លូវថ្នល់ ហិនហោចអស់ ។ ធ្វើឲ្យយើងខកខានទឹងធ្វើដំណើរទៅសួរសុខទុក្ខបង-ប្អូនយើងដូចសព្វថ្ងៃនេះ ។ តើពួកសេយ្យសាសន៍ទមិឡអន្យត្ថិយ៍ទាំងនេះ វាមានសីល វិន័យដែរឬទេ ? សូមអស់លោកពិចារណាមើលឲ្យបានវែងឆ្ងាយផង ។

៣- ចាគសម្បទា ប្រែថាការដល់ព្រមដោយការបំពេញទាន គឺចាយទ្រព្យបូជា ដូចជាបូជាចំពោះមាតាបិតា ឬក៏សាងបុណ្យកុសលសង្គ្រោះអ្នកក្រខ្សត់ (គឺចំណាយទ្រព្យសង់ស្ពានផ្លូវថ្នល់ឬក៏ចំណាយទ្រព្យជួយជាតិ-សាសនា និងរដ្ឋ ។

៤- បញ្ញាសម្បទា ប្រែថា ដល់ព្រមហើយដោយបញ្ញា គឺការត្រិះរិះពិចារណារកហេតុផលខុសត្រូវ, ស្ដាប់ច្រើន រៀនច្រើន ការទាធម៌ដែលត្រូវការទា, ធម៌ដែលត្រូវការទាមានសមថកម្មដ្ឋាន និងវិបស្សនា ជាដើម ។ (បើយើងមិនការទាធម៌បែរទៅជាការទា ជឿសម្ដីហោកប្រាស់ពួកយៀកកុង-យៀកមិញ ដែលជាកលល្បិចបញ្ឆោតឲ្យយើងចូលចិត្តនិងវា ប្រយោជន៍ទីងយកទឹកដីខ្មែរទៅធ្វើជាចំណុះរបស់ពួកវា តែប៉ុណ្ណោះ ។ សូមអស់លោក-អ្នកមានបញ្ញាត្រិះរិះពិចារណាឲ្យបានទូលំទូលាយសព្វគ្រប់ផងចុះថា តើយៀកកុង យៀកមិញ វាប្រើមធ្យោបាយបែបនេះ តើប្រយោជន៍អ្វី ? មិនគឺបង់យកស្រុកយើងទៅធ្វើជាខ្ញុំកញ្ជះនៃពួកវាទេឬ ? ។ ត្រង់នេះ បញ្ជាក់ឲ្យឃើញថា កាលណា យើងប្រើសទ្ធា ខ្វះបញ្ញា ក៏មិនបានសេចក្ដីសុខចម្រើនតាមកាលសម័យនិយមទេ ) ។

អ្នកសាងបុណ្យកុសល ត្រូវតាំងនៅក្នុងឧត្តមគតិថា "បុណ្យកុសលជាអំពើល្អ ជាសការល្អបរិសុទ្ធ ជាធម៌សម្រាប់ដុះលាងចិត្តវិញ្ញាណឲ្យបានស្អាតផូរផង់, កាលបើចិត្តស្អាតបរិសុទ្ធនិងមានសុគតិភពជាទីប្រព្រឹត្តទៅក្នុងលោកខាងមុខ", ដូច្នោះបុណ្យកុសល រមែងសម្រេចផលឲ្យដល់អ្នកដែលបានធ្វើ បានសាង មិនបាច់មានអ្នកណាដឹកនាំ គឺធ្វើដោយសេចក្ដីពេញចិត្ត ធ្វើដោយការវៃឆ្លាត ដោយសំអាង

យកគោលព្រះពុទ្ធសាសនាជាច្បាប់ ។ ការធ្វើបុណ្យកុសលជាអំពើសម្រេចមកអំពីចិត្ត មានចិត្តជាសភាពដឹកនាំ មានចិត្តជាសភាពផុសខាត់រលីង ឲ្យថ្លាស្អាត, ចិត្តស្អាត-ចិត្តភ្លឺប្រាសចាកចិត្តសៅហ្មង គួរដល់បុណ្យកុសលនេះហៅថា បញ្ញាសម្បទា ។ ម្យ៉ាងទៀត អ្នកធ្វើបុណ្យកុសល ត្រូវសម្រាំងចិត្តទៅលើបុណ្យកុសល មិនគប្បីសម្រាំងចិត្តទៅក្នុងការយកកេរ្តិ៍ឈ្មោះ ទៅក្នុងការអួត ទៅក្នុងការយកមុខ-មាត់ព្រោះថាសេចក្តីល្អ ដែលខ្លួនបានធ្វើហើយ ទោះមិនមានអ្នកណាដឹងឮក៏គង់ខ្លួនឯងបានដឹងជាប្រាកដ ទោះជាមិនមានអ្នកណាប្រោសប្រាណក៏គង់នឹងមានព្រះពុទ្ធអង្គណាមួយនឹងប្រោសប្រាណទៅក្នុងលោកខាងមុខមិនខាន ។ កាលបើអ្នកណាបានធ្វើបុណ្យស្ថិតនៅក្នុងឧត្តមគតិដូចបានរៀបរាប់មកខាងលើនេះ អ្នកនោះនឹងបានគព្ភប្រសូតនូវជោគវាសនាខ្ពង់ខ្ពស់ក្នុងអនាគតជាតិមិនខាន ។

គ- បរមសុខ ដែលកើតអំពីការរួចស្រឡះចាកភ្លើងកិលេស គឺរាគៈ ទោសៈ មោហៈ និងភ្លើងទុក្ខ គឺ ជាតិ ជរា ព្យាធិ មរណៈ ជាសុខយ៉ាងស្ងប់ ឥតមានលាយដោយទុក្ខបន្តិចបន្តួចសោះយ៉ាងនេះហៅថា បរមត្ថ ប្រែថា ប្រយោជន៍ប្រសើរបំផុតគឺព្រះនិព្វាន។

ពាក្យថា បរមត្ថ អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាតាំងទុកថាជាព្រះនិព្វាន ជាគុណធម៌ ដែលមនុស្សត្រូវស្គាល់ បើមិនស្គាល់ច្បាស់នូវប្រ-

យោជន៍ព្រះនិព្វានទេ ក៏ឈ្មោះថាមិនស្គាល់ប្រយោជន៍ប្រសើរបំផុត គឺមិនស្គាល់ទីដៅរបស់ព្រះពុទ្ធសាសនា ពីព្រោះព្រះពុទ្ធសាសនាបាននិយាយត្រឹមត្រូវតាមសេចក្តីពិត, ព្រះនិព្វានជាទីបំផុតនៃជីវិត ជាទីបំផុតរបស់ព្រះពុទ្ធសាសនា បើមិនសិក្សាឲ្យដល់ទីបំផុត ក៏មិនអាចនឹងធ្វើឲ្យដល់ទីបំផុតនៃបរមសុខបានឡើយ ។ ដូច្នេះសូមពុទ្ធមាមកជនគ្រប់រូបនាំគ្នាសិក្សាអំពីព្រះនិព្វានឲ្យបានច្រើន ដើម្បីដឹកនាំខ្លួនយើងទៅកាន់ទីដៅព្រះពុទ្ធសាសនា ដែលជាទីកប់អាននៃយើងរាល់គ្នាកុំបីខាន ។

តាមធម្មតា ព្រះសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គតែងដឹកនាំសត្វទៅតាមនិស្ស័យសន្តាន បើសត្វណាប្រកបរបរចិញ្ចឹមជីវិតក្នុងបច្ចុប្បន្ន ក៏ព្រះអង្គសម្តែងពន្យល់អំពីប្រយោជន៍បច្ចុប្បន្ន ។ បើឃើញថាពួកសត្វទាំងនោះយល់សព្វគ្រប់ហើយ ក៏ព្រះអង្គពន្យល់អំពីប្រយោជន៍បរលោកនិងព្រះនិព្វានតទៅទៀត ដើម្បីឲ្យមនុស្សសត្វបានសម្រេចនូវព្រះនិព្វាន, ពីព្រោះព្រះអង្គចង់ឲ្យពួកសត្វ ស្គាល់នូវទីបំផុតនៃព្រះពុទ្ធសាសនា ។ ដូច្នេះហើយបានជាព្រះអង្គទ្រង់សម្តែងអំពីបរមត្ថប្រយោជន៍ ៤ យ៉ាងតទៅទៀត ។

១- ទុក្ខៈ សិក្សាពិចារណា ឲ្យស្គាល់នូវសភាពពិតនៃសេចក្តីទុក្ខ ហើយត្រិះរិះកំណត់ចំណាំថាជាទុក្ខ ។

២- សមុទយៈ សិក្សាឲ្យស្គាល់ច្បាស់នូវមូលហេតុដែលនាំឲ្យ

កើតសេចក្ដីទុក្ខ ហើយគេវិធីលះបង់នូវមូលហេតុនៃសេចក្ដីទុក្ខនោះចោលចេញ ។

៣- និរោធៈ សិក្សាឲ្យស្គាល់ច្បាស់នូវព្រះនិព្វាន ហើយធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

៤- មគ្គៈ សិក្សាឲ្យស្គាល់នូវផ្លូវទៅកាន់ព្រះនិព្វាន ហើយដើរទៅតាមផ្លូវដែលចំត្រង់ព្រះនិព្វានតែម្ដង ។ មាតិកា ២ ខាងដើម គឺ ទុក្ខ និង សមុទយៈ ឯ សមុទយៈ ជាហេតុ ទុក្ខ ជាផល ។ ចំណែកខាងមាតិកាពីរខាងចុងគឺ មគ្គៈ ជាហេតុ និរោធ ជាផល ។

-ហេតុអ្វីបានជាថា សមុទយៈ ជាហេតុ ? បានជាថាដូច្នេះព្រោះថា សមុទយៈ សំដៅយកអវិជ្ជាតណ្ហា ឧបាទាន និង កម្ម ដែលជាពលនានាំសត្វឲ្យចង់កើត ចង់ធំ ចង់សប្បាយ ចង់សុខ ។ កាលណាមានការចង់ដូច្នេះហើយ តែបើមិនសម្រេចដូចបំណង ក៏រមែងប្រែក្លាយទៅជាទុក្ខ ពាក្យថាទុក្ខនេះឯង ដែលសំដៅយកការកើត-ចាស់-ដកឈឺ-ស្លាប់ ជាសភាពមិននៅគង់គ្រង់មនុស្សលោកនិង ធម្មជាតិ ជាសភាពមិនតាំងនៅក្នុងតំណាក់មួយៗ មានការប្រែប្រួលពីសភាពមួយទៅសភាពមួយ, បន្តបន្ទាប់គ្នា នាំឲ្យមនុស្សសត្វនិងធម្មជាតិទ្រាំទ្រនៅពុំបានឡើយ គឺអាស្រ័យមកតែអំពីតណ្ហាដែលជាឫសគល់ ។

-ហេតុដូចម្ដេចបានជាថា មគ្គៈ ជាហេតុ? និរោធ ជាផល? បានជាថាដូច្នេះ ពីព្រោះពាក្យថា មគ្គៈ នេះ សំដៅយកផ្លូវល្អ ផ្លូវត្រូវ មាន ៨ ប្រការគឺៈ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ជាផ្លូវត្រង់ទៅកាន់ព្រះនិព្វាន ។ ពាក្យថា និរោធៈ នេះ សំដៅយកព្រះនិព្វានដែលជាគុណធម៌ មិនមាននៅក្នុងលោកណាមួយ មានតែនៅជាមួយនឹងលោក ដែលអស់បុណ្យអស់បាបប៉ុណ្ណោះ ។

ការសម្ដែងធម៌ទេសនាដែលខ្ញុំព្រះករុណាអាត្មាភាព បានលើកយកប្រយោជន៍ ៣ យ៉ាងគឺៈ ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍បច្ចុប្បន្ន, សម្បរាយិកត្ថៈ ប្រយោជន៍បរលោក, និង បរមត្ថៈ ប្រយោជន៍ប្រសើរបំផុតគឺព្រះនិព្វាន ក៏សមគួរកាលវេលានឹងបញ្ចប់ហើយ ក៏ប៉ុន្តែមុននឹងបញ្ចប់ធម៌ទេសនានេះ សូមលើយកមហាកុសលដែលកើតអំពីធម្មទេសនានេះ ប្រគេនចំពោះសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ សូមព្រះអង្គបានប្រកបដោយសេចក្ដីសុខ និងព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ។ សូមជូនមហាកុលសនេះចំពោះឯកឧត្ដមប្រមុខរដ្ឋ សភាទាំងពីរ, រដ្ឋាភិបាលស្រោចស្រង់ជាតិ មានឯកឧត្ដមនាយករដ្ឋមន្ត្រី និងឯកឧត្ដមឧបនាយករដ្ឋមន្ត្រីទី ១ - ទី ២ ជាដើម ព្រមទាំងអស់លោករដ្ឋការគ្រប់ជាន់ថ្នាក់ សូមបានប្រកបតែនឹងសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់កាលវេលា ។ ជាពិសេសសូមជូនមហាកុសលនេះចំពោះលោក

មេទ័ព និងក្រុមយោធាយុទ្ធជនជាតិយើង សូមអស់លោកមានជ័យជម្នះ ឈ្នះអស់មារសត្រូវនៅគ្រប់ទីសមរភូមិ កុំឲ្យសត្រូវវាចូលមកបៀតបៀន បានទៀតឡើយ និងសូមឲ្យសត្រូវខ្ចាតខ្ចាត់ខ្ចាយចេញអំពីប្រទេសកម្ពុជា ក្នុងពេលឆាប់ៗនេះ ។

អាយំ សង្វេង សមត្តា ធម៌ដែលអាត្មាភាពបាន សម្តែងក្នុងពេលនេះ ក៏សន្មតថាចប់ដោយសង្ខេបតែប៉ុណ្ណោះ ឯវំ ។

# អត្តកាមកថា

ព្រះមហា អ៊ុង-មាន រៀបរៀង

ក្នុងអត្ថបទនេះ ខ្ញុំសូមលើកយកគាថាមួយ ក្នុងឧទានសុត្តន្តបិដកត្រង់វគ្គទី ៥ ហៅ សោណត្ថេរវគ្គ មកដោះស្រាយ ដើម្បីជាប្រយោជន៍ក្នុងការសិក្សាព្រះពុទ្ធសាសនា ។ គាថានោះ មានដូចតទៅនេះ ៖

សព្វា ទិសា អនុបរិគម្ម ចេតសា
នេវជ្ឈគា បិយតរមត្តនា ក្វចិ
ឯវំ បិយោ បុថុ អត្តា បរេសំ
តស្មា ន ហិំសេ បរមត្តកាមោ

" បើយើងធ្វើដំណើរពេញពិភពលោក ដោយបំណងថានឹងស្វែងរកបុគ្គលណាមួយ ដែលស្រឡាញ់ខ្លួនអ្នកដទៃជាជាងខ្លួនឯងនោះ ប្រាកដជាពុំមានឡើយ ។ កាលបើដឹងថាសត្វទាំងឡាយ សុទ្ធតែស្រឡាញ់ខ្លួនឯងជាជាងខ្លួនរបស់អ្នកដទៃដូច្នេះហើយ បុគ្គលអ្នកស្រឡាញ់ខ្លួនកុំគប្បីបៀតបៀនអ្នកដទៃឡើយ " ។

ព្រះពុទ្ធដីកាខាងលើនេះ ព្រះពុទ្ធបរមគ្រូទ្រង់សម្តែងក្នុងវត្តជេតពនវិហារក្រុងសាវត្ថី ប្រារព្ធព្រះបាទបសេនទិកោសល ។

តាមតំណាលថា ថ្ងៃមួយ ព្រះបាទបសេនទិកោសល បានស្តេចឡើងទៅកាន់បន្ទប់ខាងលើនៃមហាប្រាសាទជាមួយនឹងព្រះអគ្គមហេសី ព្រះ

នាងមល្លិកា ។ ពេលនោះ ព្រះបាទបសេនទិកោសល ទ្រង់មានព្រះរាជ-ឧង្ការទៅកាន់ព្រះនាងមល្លិកាថា សូមព្រះនាងប្រាប់យើងផងមើល៍ តើមានបុគ្គលរូបណា ដែលស្រឡាញ់ខ្លួនព្រះនាងជាជាងខ្លួនរបស់គេទេ? ព្រះនាងមល្លិកាទ្រង់ទូលតបវិញថា ចំពោះយោបល់របស់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់យល់ថាគ្មានបុគ្គលណាម្នាក់ ដែលស្រឡាញ់ខ្លួនអ្នកដទៃជាជាងស្រឡាញ់ខ្លួនរបស់ខ្លួនឡើយ ។ ព្រះបាទបសេនទិកោសល ទ្រង់ក៏មានព្រះយោបល់ដូចព្រះនាងមល្លិកាដែរ តែទ្រង់មិនអស់ហើយក្នុងព្រះទ័យ ទ្រង់បានយាងចុះពីលើមហាប្រាសាទមកវិញ ហើយទ្រង់បានស្តេចយាងទៅកាន់សម្នាក់ព្រះពុទ្ធជាម្ចាស់ ហើយទ្រង់លើកយកបញ្ហានោះ ក្រាបទូលសួរព្រះបរម-គ្រូទៀត ។ ព្រះពុទ្ធជាម្ចាស់ ទ្រង់បានដោះស្រាយនូវបញ្ហានោះ ដោយទ្រង់បន្ទូលនូវគាថាដូចដែលបានភាន់មកខាងលើ ។

ព្រះពុទ្ធគាថានោះ មានន័យថា សូម្បីយើងរើបចង្អើប ដើរពាសពេញសាកលលោក ដោយបំណងចង់សាកសួររកបុរស-ស្ត្រីរូបណា ដែលស្រឡាញ់ខ្លួនអ្នកដទៃជាជាងខ្លួនឯងនោះ ប្រាកដជាគ្មានសោះឡើយ ។

តាមពុទ្ធភាសិតខាងលើនេះ ឃើញថាជាការពិតណាស់ ។ មនុស្សសត្វក្នុងលោកសន្និវាសនេះ ដែលខំប្រឹងប្រែកបការងារគ្រប់បែបគ្រប់យ៉ាងមានការសិក្សារៀនសូត្រ និង ការប្រកបអាជីពផ្សេង ៗ ជាដើម សុទ្ធតែដើម្បីផ្គាប់ផ្គុនផ្គត់ផ្គង់ខ្លួនឯង ដោយមកពីការស្រឡាញ់ខ្លួនហ្នឹងឯង ។

ពាក្យថា ស្រឡាញ់ខ្លួន នេះពុំមែនមានន័យដូចគ្នានឹងពាក្យថា ប្រកាន់ខ្លួនឡើយ ។ ការប្រកាន់ខ្លួនដែលហៅថា អស្មិមានះ ជាទោស និងជាឧបសគ្គមួយយ៉ាងធំដល់ជីវិត ។

ឥឡូវនេះ មានបញ្ហាចោទឡើងថា ចុះបើយើងដឹងច្បាស់ថា យើងស្រឡាញ់ខ្លួនយើង ជាជាងស្រឡាញ់ខ្លួនអ្នកដទៃដូច្នេះហើយ តើយើងត្រូវទុកដាក់ខ្លួនយើងទៅបែបណា ដើម្បីឲ្យបានសមថាជាអ្នកស្រឡាញ់ខ្លួនពិតៗ ? គប្បីយើងបៀតបៀនអ្នកដទៃឲ្យមានសេចក្តីទុក្ខព្រួយ ឲ្យក្តៅក្រហាយ ឲ្យលំបាក ដោយសារតែយើងស្រឡាញ់ខ្លួនយើងឬ ? ឬគប្បីយើងអង្គុយស្ងៀម មិនប្រកបធ្វើការងាររកស៊ីទាំងអស់ ដើម្បីឲ្យខ្លួនយើងបានធាត់ធំមានសុខភាពល្អ ? ឬក៏គប្បីយើងចំណាយពេលវេលាទាំងយប់ទាំងថ្ងៃ ដើម្បីតុបតែងរូបកាយយើងឲ្យបានស្អាតស្អំផូរផង់ ដើម្បីទាញអូសអារម្មណ៍របស់អ្នកដទៃ ?

ចម្លើយថា ទេ ទេ ទេ

ត្រង់ចទថា យើងស្រឡាញ់ជីវិត ឬ ខ្លួនយើងជាងជីវិត ឬ ខ្លួនអ្នកដទៃនេះ ពុំមែនមានន័យថា យើងត្រូវចំណាយពេលវេលាទៅលើការស្អិតស្អាងរូបកាយតែម្យ៉ាងទេ យើងត្រូវខំប្រឹងប្រែងបំពេញកិច្ចការផ្សេងៗ ដែលជានាទី និងជាកាតព្វកិច្ចរបស់យើងឲ្យបានសមរម្យទៅតាមជំនឿដែលយើងធ្លាប់មានមកថា កើតហើយស្លាប់ មានកម្មនិងផលជា

យថាហេតុ ។ ហេតុនោះ មនុស្សម្នាក់ៗ ត្រូវតែខំប្រឹងបំពេញមុខការរបស់ខ្លួនឲ្យបានទាន់ពេលវេលា ព្រោះថា ពេលវេលា មិនរង់ចាំយើងឡើយ ។ ដូចព្រះពុទ្ធដីកាមួយកន្លែងក្នុងធម្មបទដ្ឋកថាថា ៖

អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ

កិច្ចការណាដែលយើងត្រូវបំពេញ ត្រូវធ្វើ យើងគប្បីធ្វើនូវកិច្ចការនោះ ក្នុងថ្ងៃនេះឲ្យហើយទៅ ព្រោះថា គ្មានបុគ្គលណាម្នាក់ អាចដឹងបានថា ក្នុងថ្ងៃស្អែកសេចក្ដីស្លាប់នឹងចូលមកដល់ឡើយ ។

មួយទៀត យើងត្រូវទុកដាក់ខ្លួនយើងឲ្យសមរម្យចំពោះជនដទៃ ឲ្យបានជាទីគាប់ចិត្ត គាប់អធ្យាស្រ័យរបស់ជនដទៃផង ។ យើងគប្បីតមវៀរនូវការបៀតបៀនអ្នកដទៃ ធ្វើអ្នកដទៃឲ្យមានសេចក្ដីទុក្ខព្រួយ ដោយសារតែការចង់បានសេចក្ដីសុខចំពោះខ្លួន ។ យើងត្រូវតម្កល់ខ្លួនយើងក្នុងសម្មាអាជីវៈ គឺរស់នៅតាមមានតាមបាន រស់នៅតាមកម្លាំងកាយនិងកម្លាំងប្រាជ្ញារបស់យើង ។ យើងមិនត្រូវប្រើអាការរំលោភឈ្លានីសជិះជាន់អ្នកដទៃដោយកាន់បុណ្យសក្ដិ ឬទ្រព្យសម្បត្តិរបស់ខ្លួនឡើយ ។ អ្នកដែលចិញ្ចឹមជីវិតខុសគន្លងធម៌ ឈ្មោះថាបៀតបៀនខ្លួនឯងផង បៀតបៀនអ្នកដទៃផង ទាំងឈ្មោះថាជាអ្នកមិនស្រឡាញ់ខ្លួនផង ដូចព្រះពុទ្ធដីកាក្នុងគាថាខាងលើត្រង់បាទទី ៤ ថា ៖

តស្មា ន ហឹំសេ បរមត្តកាមោ ។ ព្រោះហេតុនោះ អ្នកដែលស្រឡាញ់ខ្លួន មិនគប្បីបៀតបៀនអ្នកដទៃឡើយ ។

មនុស្សយើង ដោយមានភាគច្រើន ច្រើនគិតតែពីជីវិតរបស់ខ្លួន ភ័យព្រួយណាស់តែនឹងការឈឺចាប់ ជំងឺតម្កាត់ចំពោះរូបកាយរបស់ខ្លួន តែមិនអើពើគិតគូពីសុខទុក្ខជីវិតអ្នកដទៃឡើយ ម៉្លោះហើយក៏គេប្រព្រឹត្តរំលោភដោយវាយឬកពាប៊ើនម៉ឺនប៊ើនត្រឹមធ្វើងខ្មៃ គម្រាមកំហែងគេឯង ដើម្បីយកសេចក្តីសុខផ្ទាល់ខ្លួន ដោយស្មានថាការប្រព្រឹត្តធ្វើបែបនេះ ជាការនាំឲ្យបានសុខសួស្តីដល់ខ្លួនរបស់គេ ហើយគេមានជំនឿថា ការសម្តែងអាកប្បកិរិយារឹងត្អឹងបែបនេះ ទើបបានឈ្មោះថាជាអ្នកស្រឡាញ់ខ្លួន ។ តាមការពិត មនុស្សប្រភេទនេះ ពុំបានឈ្មោះថាជាអ្នកស្រឡាញ់ខ្លួនឡើយ ។ បុគ្គលប្រភេទនេះ ឈ្មោះថាជាអ្នកបំផ្លាញខ្លួនឯងទាំងស្រុង ។ មានសុភាសិតមួយកន្លែងថា " បើយើងចង់បានសេចក្តីសុខដល់ខ្លួនយើង យើងត្រូវផ្តល់សេចក្តីសុខដល់អ្នកដទៃផង; បើយើងចង់ឲ្យអ្នកដទៃ មានការពិត ការប្រាកដផងនោះ យើងត្រូវតម្កល់ខ្លួនយើងឲ្យតាំងនៅក្នុងការពិតការប្រាកដនោះៗ ជាមុនសិន រីឯអ្នកដទៃប្រាកដជានឹងក្លាយខ្លួនទៅជាអ្នកពិត អ្នកប្រាកដតាមពុំខាន" ។ ដូចពុទ្ធភាសិតក្នុងធម្មបទដ្ឋកថាថា ៖

សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខំ ។

បុគ្គលណា សូម្បីមានដំបងក្នុងដៃ មិនបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នានូវសេចក្ដីសុខ បុគ្គលនោះ ឈ្មោះថាជាអ្នកស្វែងរកសេចក្ដីសុខឲ្យដល់ខ្លួន ហើយរមែងបានជួបនូវសេចក្ដីសុខទៀត ក្នុងពេលបន្ទាន់ពីមរណភាពទៅ ។

ក្នុងឧទានត្រង់ សោណត្ថេរវត្ថុ ដដែលព្រះពុទ្ធបរមគ្រូ ទ្រង់ដាស់តឿនទៀតថា ៖

សចេ ភាយេថ ទុក្ខស្ស  សចេ វោ ទុក្ខមប្បិយំ
មាកត្ថ បាបកំ កម្មំ  អាវិ វា យទិ វា រហោ
សចេ ច បាបកំ កម្មំ  ករិស្សថ ករោថ វា
ន វោ ទុក្ខា បមុត្យត្ថិ  ឧបេច្ចាបិ បលាយតំ ។

ប្រសិនបើ យើងភ័យខ្លាចចំពោះសេចក្ដីទុក្ខហើយ បើយើងដឹងថា សេចក្ដីទុក្ខមិនជាទីស្រឡាញ់ទេ យើងមិនគប្បីធ្វើនូវអំពើអាក្រក់ណាមួយឡើយ ទោះក្នុងទីប្រជុំជនក្ដី ក្នុងទីកំបាំងក្ដី ។ ប្រសិនបើ យើងធ្វើ ឬនឹងធ្វើនូវអំពើលាមកណាមួយ យើង ក៏មិនអាចរួចចាកទុក្ខបានឡើយ; អំពើបាបនោះ តែងជាប់តាមយើងទៅក្នុងជាតិខាងមុខទៀតមិនខាន ។

អ្នកដែលស្រឡាញ់ខ្លួនពិតៗ មិនដែលហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ណាមួយ ក្នុងទីជាសាធារណៈ ឬក្នុងទីស្ងាត់ ព្រោះអ្នកនោះឯង យល់ច្បាស់ថា អំពើទាំងល្អទាំងអាក្រក់ ដែលគេបានធ្វើហើយនោះ ទោះបីសាធារណជន មិនបានឃើញ មិនបានឮ មិនបានដឹងក៏ដោយ តែខ្លួនអ្នកនោះឯង គង់ឃើញ គង់ឮ គង់ដឹងនូវរឿងនោះៗ ដែលខ្លួនបានធ្វើហើយដោយខ្លួនឯងម្នាក់ឯងពុំខាន ។ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងថា ៖

នត្ថិ លោកេ រហោ នាម

ក្នុងលោកនេះ មិនមានទីណាមួយ ដែលហៅថា ទីស្ងាត់កំបាំងឡើយ ។

បុគ្គលអ្នកស្រឡាញ់ខ្លួន មិនទម្រន់ខ្លួន មិនដេកផ្សងព្រេង មិនផ្សងវាសនា មិនបន់ស្រន់វត្ថុស័ក្ដិសិទ្ធិ ទេព្តា អារក្ស អ្នកតាឲ្យជួយស្រោចស្រង់ជីវិតខ្លួន ឬជួយផ្ដល់សេចក្ដីសុខចម្រើនដល់ខ្លួនឡើយ ។ អ្នកស្រឡាញ់ខ្លួន ជាអ្នកស្វះស្វាស្រវាស្រទេញ ប្រកបការងារតាមកម្លាំងសមត្ថភាពរបស់គេជានិច្ច ។ មនុស្សយើងបើគ្រាន់តែអង្គុយនឹកគិត ហើយមិនព្រមចុះដៃប្រកបកិច្ចការផ្សេងៗ យើងកុំសង្ឃឹមថា នឹងមានវត្ថុទាំងពូកែឯណា អាចនាំយកនូវលទ្ធផលមកប្រគល់ឲ្យយើងបានឡើយ ។ ការងារដែលយើងបានធ្វើហើយនោះ ប្រសិនបើមិនបានសម្រេចលទ្ធផលដូចបំណងទេ តើយើងគួរស្ដីបន្ទោសឲ្យនរណា ? ត្រង់នេះយើងគប្បី

ថ្វីបើថា យើងមិនត្រូវដាក់ទោសកំហុសទៅលើបុគ្គលណា ឬ តេជ្ជៈមួយឡើយ យើងគួរខំធ្វើកិច្ចការនោះតទៅទៀត កុំទម្លាក់ចោលឡើយ ។ មានមនុស្សខ្លះ បានផ្ដើមធ្វើកិច្ចការផ្សេងៗ លុះជួបប្រទះ ឧបសគ្គខ្លះ ៗ ក៏ទម្លាក់ចោលកិច្ចការនោះកណ្ដាលផ្លូវទៅវិញ ព្រោះខ្លាចសេចក្ដីលំបាក ។ បុគ្គលបែបនេះ ពុំបានឈ្មោះថាជាអ្នកស្រឡាញ់ខ្លួនឡើយ ។

បុគ្គលដំពូកខ្លះ គិតចង់បានតែពីផ្លែផ្កា តែមិនព្រមលូកដៃទៅដាំបណ្ដុះ ឬរែកដាក់តនោះៗ ម្ល៉ោះហើយ កាលណាឡើយ នឹងបានផ្លែផ្កានោះយកមកប្រើប្រាស់នឹងគេ ។ មនុស្សដំពូកខ្លះ ប្រព្រឹត្តតែអំពើអាក្រក់ ហើយតាំងបន់ស្រន់តែស័ក្ដិសិទ្ធិ សុំសុខ សុំចម្រើន ។ មនុស្សខ្លះទៀត ចង់បានតែឈ្មោះ សម្បូរ ចង់បានសុខស្រួល ចង់បានល្អនឹងគេដែរ តែមិនព្រមធ្វើអំពើល្អសោះ តើនឹងបានឈ្មោះថាអ្នកស្រឡាញ់ខ្លួនដូចម្ដេចកើត ។ មនុស្សប្រភេទនេះ ឈ្មោះថា អ្នកផ្ដុកបំផ្លាញខ្លួនឯង ដូចសុភាសិតសំស្ក្រឹតមួយក្នុងនោះថា:

បុណ្យស្យ ផលំ ឥច្ឆន្តិ បុណ្យំ ន កុរ្វន្តិ មានវា:
បាបស្យ ផលំ នេច្ឆន្តិ បាបំ កុរ្វន្តិ យត្នតា ។

មនុស្សទាំងឡាយ ចង់បានផលរបស់បុណ្យ (តែយ៉ាង) តែមិនធ្វើបុណ្យតាមតែសោះ ហើយមិនចង់បានផលរបស់បាបទេ តែធ្វើបាបយ៉ាងពេញទំហឹង ។

បុគ្គលអ្នកស្រឡាញ់ខ្លួន ជាអ្នកមានស្មារតីភ្ញាក់រលឹកជានិច្ច មិនបណ្តោយឲ្យសេចក្តីខ្ជិលច្រអូស ចូលមកជះជាន់យាយីដល់រូបកាយគេបានឡើយ ។

ព្រះពុទ្ធបរមគ្រូ ទ្រង់ដាស់តឿនណែនាំសាវ័ករបស់ព្រះអង្គ ឲ្យតម្កល់ខ្លួនក្នុងគុណធម៌ដ៏សមគួរ ដោយយកសតិនិងសម្បជញ្ញៈ មកជាទីតាំងជានិច្ច ។ ព្រោះថា ជីវិតដែលមានសេចក្តីសុខ គឺជីវិតដែលប្រកបដោយបញ្ញា ។ ដូចពុទ្ធភាសិតថា:

បញ្ញាជីវី ជីវិតមាហុ សេដ្ឋំ

អ្នកប្រាជ្ញពោលថា ជីវិតរបស់បុគ្គលដែលរស់នៅប្រកបដោយប្រាជ្ញា ឈ្មោះថាជាជីវិតដ៏ប្រសើរ ។

បុគ្គលអ្នកស្រឡាញ់ខ្លួន មិនគប្បីដេកដំអក់រង់ចាំស្លាប់ឡើយ គប្បីជាអ្នករស់នៅប្រកបដោយបញ្ញាការត្រិះរិះត្រឹមត្រូវជានិច្ច ។

មួយវិញទៀត បើយើងពិតជាស្រឡាញ់ខ្លួនរបស់យើងមែន យើងគប្បីព្យាយាមកម្ចាត់បង់នូវអកុសលធម៌ទាំងឡាយ គឺ លោភៈ ទោសៈ និង មោហៈ ដាច់ដើមឲ្យជ្រះស្រឡះ ។ បើស្តីតាមបរមត្ថធម៌ ការយោរយៅ ការគំនុំគុំគួន ការបៀតបៀន និង ការបំផ្លិចបំផ្លាញនូវគ្នានិងគ្នានេះ សុទ្ធតែផុសចេញមកពីប្រភពខាងក្នុងដែលហៅថា ការស្រឡាញ់ខ្លួននេះ [illegible] ជាតិដែលផុសឡើងក្នុង [illegible] ហើយត្រូវគត់ចំពោះ

ដោយដៃដូច្នោះ, ហេតុនោះ យើងគប្បីបន្សាត់បោលនូវការស្រឡាញ់ខ្លួន ហើយគប្បីព្យាយាមបណ្ដុះចិត្តឲ្យចាប់តោងយកនូវសន្តិមគ្គ គឺព្រះនិព្វាន ដែលព្រះពុទ្ធទ្រង់បានសម្ដែងទុកមកហើយ ។ ព្រោះពាក្យថា "ស្រឡាញ់" នេះ ជាឫសគល់ នៃទុក្ខទោសគ្រប់យ៉ាង ការទាស់ទែងខ្វែងគំនិតគ្នា ការកាប់សម្លាប់រវាងគ្នានិងគ្នាទាំងនេះ កើតចេញមកពីប្រភពតែមួយ គឺ ការស្រឡាញ់នេះឯង ។ ក្នុងធម្មបទដ្ឋកថា ខុទ្ទកនិកាយ ព្រះពុទ្ធទ្រង់ សម្ដែងថា :

បេមតោ ជាយតេ សោកោ
បេមតោ ជាយតេ ភយំ
បេមតោ វិប្បមុត្តស្ស
នត្ថិ សោកោ កុតោ ភយំ ។

សេចក្ដីស្រឡាញ់ ជាហេតុនាំឲ្យមានសេចក្ដីសោកនិងភ័យ, បើ បុគ្គលរូបណា មិនមានសេចក្ដីស្រឡាញ់នៅក្នុងសន្ដានទេ បុគ្គលរូបនោះ ឈ្មោះថា ផុតសោក ផុតភ័យគ្រប់យ៉ាង ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ដាស់តឿនសត្វឲ្យចេះរកមធ្យោបាយដោះស្រាយ ការស្រឡាញ់ខ្លួននេះ ដោយការទូន្មានឲ្យយក សម្មាទិដ្ឋិ ការយល់ត្រូវ សម្មាសង្កប្ប ការត្រិះរិះត្រូវមកជាទីតាំង ព្រោះអរិយមគ្គទាំងពីរនេះ ជាឧបាយមានអត្ថប្រយោជន៍សំខាន់ណាស់ ដើម្បីដឹកនាំមនុស្សឲ្យយល់

ច្បាស់នូវភាតរភាព សុវត្ថិភាព សន្តិភាព និងសេចក្តីចម្រើន ដល់មនុស្សជាតិក្នុងពិភពលោក ។ ឧបាយដ៏ប្រសើរនេះ ប្រជាពលលោកដែលជាអ្នកស្វែងរកសន្តិភាពផ្តល់ឲ្យពិភពលោក បានទទួលយល់ស្របទាំងស្រុងថា ជាមាគ៌ាដ៏ប្រសើរបំផុត ។

ព្រះពុទ្ធបរមគ្រូ ព្រះអង្គឈ្មោះថា ជាអ្នកស្រឡាញ់ខ្លួន ទ្រង់មិនលុះទៅក្នុងអំណាចនៃសេវនធម៌ណាមួយឡើយ ។ ដូចពុទ្ធភាសិតក្នុងធម្មបទដ្ឋកថាថា :

អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ
សាទានេសុ អនាទានំ តំ អហំ ព្រូមិ ព្រាហ្មណំ ។

"បុគ្គលដែលតថាគតហៅថាព្រាហ្មណ៍ (មនុស្សប្រសើរឬមនុស្សឧត្តម) គឺបុគ្គលអ្នកមិនប្រទុស្ត សូម្បីរស់នៅក្នុងសង្គមអ្នកប្រទុស្ត ជាបុគ្គលស្ងប់ក្នុងចំណោមនៃជនទាំងឡាយ ដែលមានដំបងក្នុងដៃ ដើម្បីធ្វើទុក្ខទោសអ្នកដទៃ, ជាអ្នកប្រស្រឡះចាកអកុសលធម៌ទាំងឡាយ ក្នុងចំណោមនៃជនទាំងឡាយ ដែលមានតណ្ហានិងឧបាទានក្នុងសន្តាន" ។

មនុស្សភាគច្រើនដែលយល់ខុសថា បើយើងស្រឡាញ់ខ្លួនយើង យើងត្រូវតែកាប់សម្លាប់អ្នកដទៃ លួចប្លន់របស់ទ្រព្យអ្នកដទៃ ប្រព្រឹត្តអនាចារលើកូនប្រុស-ស្រីឬស្វាមី-ភរិយាអ្នកដទៃ និយាយកុហកសេពសុរានិងមេរ័យជាដើម ដើម្បីបំពេញសេចក្តីសុខដល់ខ្លួនឯង ។ បុគ្គល

ប្រភេទនេះ ឈ្មោះថាជាអ្នកបៀតបៀនខ្លួនឯងផង បៀតបៀនអ្នកដទៃផង ។ បុគ្គលដែលជាអ្នកស្រឡាញ់ខ្លួននោះ ទោះបីក្នុងពេលណាក៏ដោយ នៅតែមិនព្រមប្រព្រឹត្តខុសពីគន្លងធម៌ឡើយ ។ ដូចពុទ្ធភាសិតមួយកន្លែងក្នុងធម្មបទដ្ឋកថាថា :

សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវាទិនំ
អត្តនោ កម្ម កុព្វានំ តំ ជនោ កុរុតេ បិយំ ។

ប្រជាជនហៅអ្នកនោះថាជាអ្នកស្រឡាញ់ខ្លួន គឺអ្នកដែលមានសីលបរិសុទ្ធ បានតម្កល់ខ្លួនក្នុងគុណធម៌ បានឃើញច្បាស់នូវសច្ចធម៌ ហើយបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនសព្វគ្រប់ ។

ព្រះពុទ្ធដីកាមួយកន្លែងទៀតក្នុងធម្មបទដ្ឋកថាថា ៖

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។

“បើអ្នកមានប្រាជ្ញាដឹងថា ខ្លួនជាទីស្រឡាញ់របស់ខ្លួនហើយ គប្បីរក្សាខ្លួនទុកឲ្យបានល្អ, គប្បីបម្អាតខ្លួនឲ្យស្អាតដោយនិច្ចក្នុងយាមទាំង ៣” ។

សប្បុរសជន គប្បីធ្វើទុកក្នុងចិត្តឲ្យខ្ជាប់ខ្ជួន ត្រង់ពាក្យថា “ស្រ-ឡាញ់ខ្លួន” នេះជាលោកវោហារសុទ្ធសាធ ជាពាក្យសម្រាប់ប្រើប្រាស់ចំពោះលោកិយជនប៉ុណ្ណោះ ។ តែបើស្តីតាមផ្លូវបរមត្ថវិញ ពាក្យថា “ស្រឡាញ់ខ្លួន” នេះពុំមានលទ្ធភាពឡើយ ។ ព្រោះថា បុគ្គលដែល

នៅមានចិត្តជាប់ជំពាក់នឹងរូបកាយ (ការស្រឡាញ់ខ្លួន) នេះសុទ្ធតែនៅក្រោមអំណាចនឹមនៃតណ្ហានិងឧបាទាន ដែលជាមេនាំឲ្យកើតចាស់-ឈឺ-ស្លាប់តាំងអស់ ។ ហេតុនោះ យើងជាពុទ្ធបរិស័ទ គប្បីត្រិះរិះរកមធ្យោបាយកម្ចាត់ចោល នូវការស្អប់ និង ការស្រឡាញ់នេះឲ្យបានផុតស្រឡះ ដើម្បីក្រេបជញ្ជក់នូវឯកន្តបរមសុខ គឺព្រះនិព្វាន ។

ព្រះមហា អ៊ុខ - មាន [ចន្ទវណ្ណោ]

វត្តឧណ្ណាលោម

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ - កាន

## ប្រែ - រៀបរៀង

## (ត)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងចេះឲបាយកលចំណាន | ទាំងមានសន្ដានស្នេហាជាតិ |

យូរ-អ៊ុន

## សាមកុកខ្សែ ៣៤

តាំងពីកូឌិនកាត់ប្រើកោឈុយជានាយកងលើកទ័ពទៅវាយយកស្រុកលីវសៀ, បែះយកបំណាច់ខ្លួនក៏ឲ្យសុម៉ាអ៊ីមានសេចក្ដីគាប់ប្រសើរតែម្នាក់ឯង, លុះលើកទៅក៏មានជ័យជម្នះ កោ-សៀង, អងបេង និងអ៊ុយអៀនដែលរត់មកជួបកណ្ដាលផ្លូវ លុះនឹងលើកចូលទៅជណ្ដើមយកស្រុកលីវសៀ ក៏ឃើញកងទ័ពសុម៉ាអ៊ីវាយយកបានជាមុន, រហូតដល់សុម៉ាអ៊ីទូលព្រះចៅចូយ៉យឲ្យចាត់ប្រើហេកជៀវចៅហ្វាយស្រុកហោសៃ ឲ្យលើកទ័ព ទៅទប់ទ័ពខុះបេង នៅតំបន់តាន់ផង ។

---

ខណៈនោះ, ចូជិនដែលនៅឈរគ្រងស្រុកប៉ៃសៀដឹងដំណឹងថា: សុម៉ាអ៊ីវាយបានទីគេតេងហើយក៏គិតថា: សុម៉ាអ៊ីនោះ, មុខជាមានសេចក្ដីគាប់ប្រសើរក្នុងជាន់នេះលើសជាងខ្លួន, គិតដូច្នោះហើយក៏បបចាត់ប្រើ កោឈុយឲ្យលើកពលទ័ពចេញទៅទន្ទឹមជណ្ដើមយកស្រុកបើវសៀ,

ដើម្បីបែងយកគុណបំណាច់ក្នុងរាជការខ្លះ, លុះលើកទ័ពទៅដល់ពាក់កណ្ដាលផ្លូវ ក៏ជួបប្រទះនឹងកោសៀ, អង់បេង, អ៊ុយអៀនដែលបែកទ័ពរត់ទៅ, កោឈុយក៏បរពលទាហានចូលបោមព័ទ្ធនាយទ័ពទាំង៣ ក៏បានតដៃចាក់កាប់សម្លាប់គ្នាទៅវិញទៅមកវិនាសពលទាំងសងខាង កោសៀង, អង់បេង និងអ៊ុយអៀនថយកម្លាំងណាស់ នឹងប៉ះពារតស៊ូនឹងកោឈុយពុំបាន, ក៏នាំពលទាហានដោះរត់ទៅចូលគយយ៉ាំងបេងគួន ។

ឯកោឈុយឃើញថាអ៊ុយអៀនចាញ់ដៃរត់ទៅហើយ ក៏និយាយនឹងទាហានទាំងពួងថា: គ្រានេះ, ទោះបីជាយើងយកទីកេតេងមិនបានក្ដីណា, បើគ្រាន់តែវាយយកបានស្រុកលីវសៀប៉ុណ្ណោះ, ក៏គង់មានកេរ្ដិ៍ឈ្មោះជាគាប់ប្រសើរស្មើគ្នា, ទើបផ្ដើមដេញទាហានឲ្យចំស្រូតរូតះទៅដើម្បីនឹងវាយយកស្រុកលីវសៀ, លុះទៅដល់ជិតជើងកំពែង ក្រឡេកទៅឃើញទង់ជ័យដោតហែលើសើទបន្ទាយ, ទើបរំសាយទ័ពឈប់មើលកលការ, សុម៉ាអ៊ីដឹងថាកោឈុយលើកទ័ពមក, ក៏ទៅឈរលើសើទអើតមុខឡើងបំអកទៅថា នែអ្នកកោឈុយ! ហេតុម្ដេចអ្នកឯងបានជាទើបលើកទ័ពមកយឺតយូរម្ល៉េះ ?

កោឈុយឃើញសុម៉ាអ៊ីឈរនៅលើសើទ, ហើយស្រែកបំអកឲ្យដូច្នោះ ក៏ខឹងអៀនខ្មាសពេកណាស់ គិតថា: អាះ! សុម៉ាអ៊ីនេះ ប៉ុនប្រសប់ដូចទេវតា, កាលណាក៏គិតយើងនឹងស្មើគេបាន, គិតហើយកោឈុយ ក៏លើកពលចូលទៅក្នុងស្រុកនោះ, លុះទៅដល់ហើយក៏ចូលទៅ

គំនាប់ស៊ុម៉ាអ៊ីតាមប្រវេណីដោយសុភាព, ស៊ុម៉ាអ៊ីក៏តបរៀបប្រាប់ថា: វេ-លានេះយើងវាយយកទីកោតេងជាទីសំខាន់បានហើយ, មុខជាខុងបេងនឹងលើកទ័ពតែទៅវិញជាប្រាកដ, ត្រូវអ្នកឯងនឹងចូដឹននាំទាហានទៅតាមដេញចាប់យកខ្លួនខុងបេងឲ្យបាន, កោឈុយទទួលបង្គាប់ហើយ ក៏គំនាប់លា ស៊ុម៉ាអ៊ីលើកទ័ពចេញទៅ ។

ស៊ុម៉ាអ៊ីនិយាយប្រាប់ទាប់ថា: ចូដឹនប្រើកោឈុយឲ្យលើកទ័ពមកគ្រានេះ, ប្រាថ្នានឹងបែងវែកវែកយកមុខឲ្យបានទំនុកគាប់ប្រសើរ, តែបានដំណើរលើយើងវាយយកស្រុកនេះជាមុនបាន, ឯខ្លួនយើងក៏គ្មានដឹងនឹងតាំងចិត្តគិតដណ្តើមគុណបំណាច់តែឯងសោះ, ហេតុតែត្រូវចន្លោះ ព្រោះបុណ្យភ័ក្ត្ររបស់យើងជួយជូនឲ្យបានស្រួលឯណោ ទម្លុកកោះសៀង, អង-បេង, ហ៊ុយគៀន, ម៉ាចេក តាំង ៤ នាយយើងក៏វាយបែកបាក់អស់ហើយ, មិនលែងឡើយនឹងនាំគ្នាទៅប្រជុំឯគយ[illegible]ងបេងខ្លួន, បើយើងនឹងគិតឲ្យចាំមួនលើ[illegible]ធោវាយស្រុកនេះ, ក៏នឹកឲ្យខ្លាចគ្រប់[illegible]ខុងបេង វែកងណោដឹងនឹងលេកទ័ពទៅខ្ចប់វាយពីក្រោយឲ្យរង្វាន់ការ, ការនេះត្រូវតែអ្នកនាំពលយោធាទៅចាំស្កាត់កណ្តាលផ្លូវ ដែលនឹងចូលទៅវាយយ៉ុងបេងខ្លួនជាមុនចុះ, រួចសឹមយើងលើកទ័ពធំតាំងអស់ទៅចាំវាយពីតខុងបេងទៅតំបន់ចាំកុក តែថាត្រូវវែរមុខ ទម្រង់កងទ័ពទៅលើស្រុកសេសៀទើបបាន, ព្រោះស្រុកសេសៀនោះខុងបេងក្តិ៍គ្រប់ទាហាន នឹងប្រមូលស្បៀងអាហារទុកជាច្រើនណាស់, ទីនោះក៏សំខាន់, បើយើងបានស្រុកសេសៀជា

កំណាន់ហើយ គង់នឹងបានស្រុកឡាំអាន់ និងស្រុកធៀនស៊ុយឧង, ព្រោះ ស្រុកនោះជាផ្លូវទៅមករួមគ្នា, តែបើឃើញខុងបេងទៅដល់កន្លែងដែល អ្នកឯងពួនបង្កប់នោះ, អ្នកចូលលើកពលទាំងអស់ចេញទៅកាត់ស្បៀង ឲ្យទាន់តែបាន, ទៀវទាប់បានស្តាប់ពតិមានសព្វគ្រប់ក៏គំនាប់លាទ័ព លើកចេញទៅ, សុម៉ាអ៊ុកចាត់ស៊ុនតាំ, ស៊ិនងីឲ្យនៅរក្សាស្រុកលីវសៀ ហើយក៏ប្រមូលពលរេហ៍លើកចេញទៅ ។

ឯបម្រើដែលអង់បេងចាត់ឲ្យនាំផែនទីទៅជូនខុងបេងនោះ, បាន ទៅដល់ក៏យកផែនទីនោះជូនទៅខុងបេង, ហើយក្រាបទូលតាមដំណើរ ដែលបានធ្វើការនោះគ្រប់ប្រការ, ខុងបេងក៏ទទួលយកផែនទីទៅលា មើលស្រៀងញ៉ាត់ពីមុខក៏លើកដៃគក់ត្រូងហើយថា: ហេតុអ្វីឡើយបានជា ម៉ាឆេកទៅតាំងបន្ទាយនៅលើភ្នំខ្ពស់នេះ, ចុះបើធ្វើយ៉ាងនេះសត្រូវនឹងលើក ទ័ពទៅខ្ទប់ផ្លូវទឹកអស់ហើយឬ? មុខជាទាហានទាំងអស់ក៏នឹងវិនាស អន្តរាយឃ្លាតខ្លាយស្លាប់ហើយ, ដែលវាធ្វើការយ៉ាងនេះ, ចំពោះតែនឹងឲ្យ ទាហានយើងស្លាប់ជាប្រាកដ, គៀវងីឆ្លើយថា: ខ្ញុំបាទនឹងសុំអាសារទៅ ការពារតំបន់គេតេងដោយខ្លួនឯងចុះ, ហើយសុំផ្លាស់ឲ្យម៉ាឆេកវិលមក វិញ ។

ខុងបេងថា: អ្នកឯងនិយាយនេះត្រូវណាស់, បើដូច្នោះចូរកុំបង្អង់ យូរ ឲ្យឆាប់ទៅគិតគូរលើកទាហានទៅចុះ, គៀវងីទទួលប្រសាសន៍ ហើយក៏ឆាប់ទៅរៀបចំទាហានលើកចេញទៅ, ទទួលបម្រើសេះកូលមក

ជម្រាបថា ឥឡូវតំបន់កេតេងទិងស្រុកលីសៀវបែកខ្ចូចទៅហើយ, ខុង-
បេងឮដូច្នោះក៏ស្ទុះក្រោកទ្រទ្រំជើងយំហើយថា ការធំរបស់យើងគ្រានេះ
មុខជាខូចទាំងអស់ជាមិនខាន ខូចទាំងពលទាហានមិនមានសេសសល់
ឡើយ, ទើបផ្តាប់ខ្លួនហ៊ុន, ទៀវប៉ៅ ឲ្យនាំទាហានម្នាក់៣.០០០លើក
ទៅតួនបង្កប់នៅប្រហាបផ្លូវតូចក្បែរភ្នំប៉ិកអងសាន់ហើយកំជាប់ថា បើ
ឃើញទ័ពស៊ុម៉ាអ៊ីលើកមកក៏កុំអាលចេញច្បាំង, ត្រូវតាំងរាយឈ្មោះគោះ
គងខ្ចូងកើរស្រែកហោរឲ្យខ្លាច, បើប្រសិនជាទាហានស៊ុម៉ាអ៊ីអស់អំណាច
លើកថយទៅក៏មិនត្រូវឲ្យដេញតាម, ត្រូវតែលើកពលស្រូតរូតទៅឯគយ
យ៉ាំងបេងគួនវិញ ។

ខុងបេងក៏ចាត់ការឲ្យបណ្ដាហេព័ពលទាំងអស់ ប្រុងប្រៀបរៀបស្បៀង
អាហារទុកជាស្រេច, ទើបចាត់ប្រើទៀវអេកឲ្យលើកទៅជាទ័ពមុខ,
សម្រាប់ទីងបុានដំរះផ្លូវឲ្យកងទ័ពដើរទៅបានដោយស្រួល, ចាត់ឲ្យអៀង-
អ៊ុយនិងម៉ាតាយ ២ នាយនេះ ជាមេកងទ័ពក្រោយ, ឲ្យរាងនៅមាត់ច្រក
ផ្លូវត្រូវឲ្យការពារទាហានទាំងពួងកុំឲ្យមានអន្តរាយ, ហើយចាត់បម្រើឲ្យ
ស្រូតទៅប្រាប់អ្នកដែលរក្សាស្រុកធៀនស៊ុយ, ស្រុកឡាំអាន់, ស្រុក
សេសៀ ទាំង៣ស្រុកនេះឲ្យដោះបោលស្រុកចេញ, ហើយឲ្យរត់
ស្រូតចូលទៅស្រុកហាន់តុងចុះ, រួចចាត់បម្រើឲ្យទៅនាំមាតាកៀងអ៊ុយ
ដែលមកចុះចូលនោះ យកទៅជាមួយផង, ខុងបេងរៀបចាត់ការស្រេច
ក៏លើកទាហាន ៥.០០០ ចេញទៅស្រុកសេសៀ, លុះទៅដល់ហើយ ក៏

ប្រមូលពលទាហានបាន ២.៥០០ ទៅដឹកជញ្ជូនស្បៀងអាហារពីគ្រប់តំបន់យកមក, ឯខ្លួនខុនបេងឯងក៏នាំពលពាក់កណ្ដាលចូលទៅតាំងនៅក្នុងស្រុកនោះ ។

ខណៈនោះ មានទាហានល្បាតចូលទៅប្ដឹងខុនបេងថា: ស៊ុម៉ាអ៊ីលើកទ័ពមកជិតហើយ, ខុនបេងព្រួយព្រោះក៏ភ័យណាស់, បណ្ដាពួកទាហានទាំងអស់ក៏តក់ស្លុតដូចបាត់ស្មារតីពល់គ្នា, ខុនបេងវេលានោះមានពលទាហានតិចណាស់ នាយទាហានក៏មានតិចខ្លួន, ខុនបេងជប់ធុញពន់ប្រមាណមិនជាបានទឹងគិតតតាំងច្បាំងយ៉ាងម្ដេច ទើបឡើងទៅនៅលើសេនបន្ទាយ ក្រឡេកទៅឃើញកងទ័ពស៊ុម៉ាអ៊ីលើកមកពីចម្ងាយច្រើនណាស់ណា ឧបមាដូចស្រមោចឬកណ្ដាប់ ដូចជានឹងមកជាន់កំទេចឲ្យល្អិតស្រុកនោះជាផងធូលី, ខុនបេងក៏បង្គាប់ឲ្យរើដកទ័យអំពីទីសេនបន្ទាយនោះចេញអស់, ហើយឲ្យបើកទ្វារស្រុកគ្រប់បន្ទោះ ទិសទាំង ៤ ចំហររហូតទៅ, ក្រៅអំពីនោះក៏ចាត់ទាហាននិងពួកអ្នកស្រុកឲ្យចេញទៅបោសប្រាសតាមច្រកទ្វារជាបែបធម្មតា, ក្នុងមាត់ទ្វារនីមួយៗចំនួនមនុស្ស ២០ នាក់, ហើយបង្គាប់កុំឲ្យភ័យភ្ញាក់ញាញើតខ្លាចឲ្យសោះ, ទាហានក្រៅពីនោះឲ្យដោះចេញទៅពួនបង្កប់កុំឲ្យមានសូរឲ្យឮសូរសម្ដី ហើយខុនបេងនិយាយថា យើងធ្វើកលឧបាយនេះ ដើម្បីឲ្យស៊ុម៉ាអ៊ីលើកថយទ័ពទៅឯងឲ្យបាន, បើនណាចរចាគ្នាឲ្យឮប៉ុន្មាន ត្រូវកាត់ក្បាលចេញទាំងអស់, លុះបង្គាប់ហើយ ខុនបេងក៏ពាក់តែងរាងកាយយ៉ាងស្អាតបាត

ហើយនាំកូនក្មេង ២ នាក់ឡើងទៅអង្គុយលើសេះ, ឲ្យក្មេងម្នាក់កាន់ក្របី ម្នាក់កាន់សែលឈរកែមខ្លួនខុនបេង, ហើយតាំងតម្កល់ពានដុតធូបបូជាពីខាងមុខ, ឯខ្លួនខុនបេងអង្គុយដេញពិណលេងសប្បាយ ៗ

ខណៈនោះ, ទាហានកងមុខចំពស៊ុម៉ាអ៊ី លើកចូលមកជិតជើងកំពែងស្រុក ក្រឡេកមើលទៅលើសេះ ឃើញខុនបេងអង្គុយដេញពិណព្រងើយដូច្នោះក៏ឲ្យទឹកញញើតខ្លាច ត្រឡប់ថយចេញទៅប្រាប់ស៊ុម៉ាអ៊ីថា: តូតែអស់យើងខ្ញុំលើកទ័ពទៅដល់ជើងកំពែងហើយ, ឃើញកណ្ដាលស្រុកស្ងាត់ឈឹងគ្មានរហែពលសោះ, ឃើញមានតែមនុស្សបោសផ្លូវទ្វារ ១ ចំនួន ២០នាក់ប៉ុណ្ណោះ, ឯខ្លួនខុនបេងនោះឃើញឡើងទៅអង្គុយដេញពិណលើសេះព្រងើយបែបប្លែកណាស់, បើនឹងលើករួតរះចូលទៅក្រែងត្រូវកលឧបាយខុនបេង ហេតុយ៉ាងហ្នឹងបានជាមកជម្រាបប្រសាសន៍ឲ្យលោកជ្រាប ៗ

ស៊ុម៉ាអ៊ីឮដូច្នោះក៏អស់សំណើចថា: ខុនបេងម្ដងនេះម្ដេចក៏មកធ្វើដូច្នេះទៅវិញ, គួរតែចេញទៅមើលបន្តិចចុះ, ស៊ុម៉ាអ៊ីក៏ឡើងសេះនាំទាហានប្រហែល២០នាក់ទៅឈរមើលពីឆ្ងាយ ឃើញខុនបេងតែងខ្លួនស្អាតបាត មើលទឹកមុខបែបសប្បាយរីករាយមិនភ័យសោះ, ក៏នឹកពិភាល់ថា: កងទ័ពយើងលើកមកជាការប្រទាល់គួរដល់ទីនេះហើយ ហេតុអ្វីឡើយបានជាខុនបេងគ្មានសេចក្ដីតក់ស្លុតសោះ, ត្រឡប់ធ្វើស្មោះដេញពិណលេងវិញ, ប្រហែលជាគេនេះមិញប្រើកលឧបាយបញ្ឆោតយើងទេដឹងឬ ? គិតដូច្នោះហើយក៏រឹតតែពិភាល់ចិត្តណាស់ ក្រែងខុនបេងបន្កប់

ទាហានទុកច្បាស់ហើយ, សុម៉ាអ៊ីក៏ញាក់សេះនាំទាហានត្រឡប់ទៅវិញ ដោយនឹកខ្លាចមិនអាចនឹងចាត់ការយ៉ាងណា, ក៏ត្រឡប់ឲ្យកងមុខជាកងក្រោយរត់បណ្ដោយថយទៅ ។

សុម៉ាជៀវជាបុត្រឃាត់បិតាថា: ហេតុម្ដេចលោកឪពុកមកក្រែងខ្លាចខុងបេងដូច្នេះ ខុងបេងគ្រានេះអស់សេចក្ដីគិតផុតអស់ទាហានហើយ នឹងតស៊ូនឹងយើងមិនបានទេ, ប្រថុយចាំតែស្លាប់ហើយ តែនៅមានមានះចិត្តគិតកលឧបាយទទេៗទៅ ។

សុម៉ាអ៊ីថា: កូនឯងនៅក្មេងសេចក្ដីខ្លីគំនិតណាស់, មិនទាន់ដឹងច្បាស់កលឧបាយខុងបេងនៅឡើយ, ឯខុងបេងនេះហើយជាមនុស្សមានប្រាជ្ញាជ្រាលជ្រៅ ស្គាល់យល់ផ្លូវ ស្ទាញស្ទាត់ប្រាកដក្នុងក្បួនពិជ័យសង្គ្រាមណាស់, បើនឹងធ្វើការអ្វីវែករហ័សមាំមួន, ធ្លាប់ធ្វើកលជល់សំនួនមានជ័យមកច្រើនគ្រា, កូនឯងមានសតិបញ្ញាតែត្រឹមប៉ុណ្ណោះ នឹងកន្ទង់មើលងាយប្រាជ្ញាខុងបេងជាមនុស្សដែលចាស់នោះមិនគួរ, បើនឹងទទួបដោយប្រាជ្ញាប្រទល់អួតនឹងខុងបេងក៏គង់នឹងនាំគ្នាស្លាប់អសារឥតការ ពាក្យដែលកូនឯងថានោះ ឪពុកនឹងជឿស្ដាប់ពុំទាន់បាន ថាហើយក៏ដេញពលទាហានថយចេញមក ។

ខុងបេងឃើញសុម៉ាអ៊ីលើកទ័ពត្រឡប់ទៅ ក៏ក្រោកឡើងទះដៃសើច, ពួកពលទាហានឃើញដូច្នោះក៏សួរថា: ហេតុម្ដេចមហាឧបរាជមិនភ័យខ្លាច, ត្រឡប់ជាទះដៃសើចវិញដូច្នេះ, វេលានេះសុម៉ាអ៊ីលើក

ពលមកដល់១៥ម៉ឺនទឹងធ្វើអន្តរាយលោក ៗ ក៏ទាល់ច្រកជាទីបំផុតឥតរំពឹងសោះហើយ, ខុងបេងថា: ដែលយើងស៊ើបនោះ, ព្រោះឃើញថាស៊ុម៉ាស៊ីមិនស្មើប្រាជ្ញានឹងយើង សម្គាល់ថាយើងបង្កប់ទាហានទុកជាទីកំបាំង ក៏តាំងតែខ្វាបរត់ទៅឯង, ឯកលឧបាយនេះ បើយើងនឹងមិនធ្វើក៏ចំពោះលើដំណើរត្រូវធ្វើខាងមិនបាន, ព្រោះជាទីទាល់ខ្លួនប្រាណផុតសង្ឃឹមហើយ, ឯស៊ុម៉ាស៊ីថយទ័ពទៅវេលានេះ មុខជាទៅតាមផ្លូវតូចក្បែរភ្នំប៉ិកអងសានជាប្រាកដ ត្រូវនឹងយើងសន្មតបាក់ឱ្យគួនហ៊ុន, ទៀវហ៊ឿវទៅបង្កប់ទាហានទុកនៅរ៉ែនោះ ត្រូវតាមគំនិតយើងមិនខុសសោះឡើយ ៗ

ទាហានទាំងពួងឮហើយក៏ត្រេកអរនាំគ្នាឈូងរបូលទៅជូនគំនាប់ខុងបេងហើយថា បើប្រស័នណាគស់យើងខ្ញុំទាំងឡាយគិតយ៉ាងនេះ, កាលណាឡើយនឹង[illegible]បាននៅបាន, គង់នឹងនាំពលទាំងប៉ុន្មានរត់បោលស្រុកគស់ទៅហើយ ខុងបេងឆ្លើយថា: បើនឹងធ្វើចិត្តឱ្យទន់មិនអត់ធន់នៅ ហើយរត់បេញទៅបោលស្រុកដូច្នោះ, ពលយើងទាំងអស់មានត្រឹមតែមួយក្តាប់ នឹងមិនស្លាប់ដោយកម្លាំងពលរបស់គេ១៥ម៉ឺននោះទេឬ? គេក៏គង់នឹងដេញជាន់ចាប់ឈ្លើចល្ងើ ដូចកូនមាន់កូនទាតែមួយវេលាក៏ចង់ខ្ទុះប្រមុះបានគ្មានសល់, ថាហើយក៏ទះដៃសើចទៀត, ទាហានទាំងពួងត្រេកអររីករាយ, ខុងបេងថា: ឥឡូវស៊ុម៉ាស៊ីលើកទ័ពថយទៅហើយ, ព្រោះបានញកលឧបាយរបស់យើង, តែថាអាក្រក់ៈឬគង់នឹងរកត្រឡប់មក

ខ្ញុំជឿអ្នកយើងពុំខាន, យើងមិនត្រូវគិតស្មានដោយទុកចិត្តសោះ, វេលានោះខុងបេងក៏ឲ្យកៀរគ្រប់គ្រួបណ្ដា ដែលមានក្នុងស្រុកនោះសុសសត្វគេទើបណ្ដើរនាំទៅទុកឯប្រុកហាន់តុងតាំងអស់ ។

ឯសុម៉ាអ៊ីលើកទ័ពត្រឡប់ទៅដល់ភ្នំប៉ុកអង់សាន, បានឮសម្លេងតាហានគួនហ៊ុន, ទៀវប៉ៅដែលចង្កប់នៅទីនោះ ស្រែកហ៊ោគឹកកងរំពងចេញមកក៏ភ័យណាស់, និយាយនឹងសុម៉ាហ៊ូ, សុម៉ាជៀវជាបុត្រថា ប្រសិនណាយើងកុំថយទ័ពត្រឡប់មក ក៏គង់នឹងត្រូវកលខុងបេងមិនខាន ថាមិនទាន់អស់ពាក្យប៉ុន្មាន, ស្រាប់តែក្រឡេកទៅឃើញកងទ័ពលើកចុះមកពីលើភ្នំ, មានទង់ខ្មៅធំសម្រាប់មេទ័ពចារឹកអក្សរក្លាប់ថា ទៀវប៉ៅ (មេកងធំ) ទ័ពសុម៉ាអ៊ីក៏ផ្អូកផ្អើលប្រឡូកប្រឡំរវីកវរណាស់ ស៊ុះបោលអស់គ្រឿងសស្ត្រាវុធរត់ត្រឡប់ទៅក្រោយ ចំណាយទៅដល់មាត់ផ្លូវទឹងចេញទៅផ្លូវធំ, ឃើញកងទ័ពមួយក្រុមលើកមកស្កាត់ទទឹងពីមុខ មានទង់ក្រហមចារឹកអក្សរថាគួនហ៊ុន ( មេកងធំ ) ហើយឮសម្លេងហ៊ោក្នុងព្រៃភ្នំគឹងកង ។

សុម៉ាអ៊ីតែតែភ័យក្រែកទ្រូងមហិមៈគិតថា : មុខជាខុងបេងធ្វើកលឧបាយពលតាំងឡាយក៏ផ្អើលជ្រួលច្របល់ តាំងកងទ័ពនាំគ្នារត់ពួនពាក់បោលអស់ស្បៀងអាហារ គ្រឿងសស្ត្រាវុធច្រើនណាស់, ខ្លះក៏រត់យកតែខ្លួន, គួនហ៊ុន, ទៀវប៉ៅក៏មិនចុះទលើកទ័ពដេញតាមបណ្ដាំខុងបេងប្រើងតែឲ្យរើសដណ្ដួនយ ..ស្បៀងអាហារនិងគ្រឿងសស្ត្រាវុធ ហើយក៏

លើកទ័ពត្រឡប់ទៅវិញ ។

ឯចូជិនពុថា កងទ័ពខុងបេងលើកត្រឡប់ទៅហើយ, ក៏ស្រូតលើកទាហានទន្ទ្រានតាមទៅដល់មាត់ផ្លូវដែលកៀងអ៊ុយ, ម៉ាតាយបង្កប់ទាហាននៅនោះ, លុះទៅប្រទះប្រទល់គ្នាក៏បរពលយោធាចូលតតាំងច្បាំងទៅវិញទៅមក កៀងអ៊ុយ, ម៉ាតាយក៏កាប់សម្លាប់កងទ័ពចូជិនស្លាប់អស់ជាច្រើន, ចូជិនបាញ់ដៃតស៊ូមិនបាន ក៏ថយទ័ពត្រឡប់ក្រោយទៅវិញ, កៀងអ៊ុយ, ម៉ាតាយបានជ័យជម្នះហើយ ក៏លើកទ័ពត្រឡប់ទៅស្រុកហាន់តុងវិញ ។

ឯជូឡុង, តេងជីដែលលើកពលទៅតាំងនៅតំបន់គីកុកនោះ, លុះដឹងថាខុងបេងលើកទ័ពត្រឡប់ចេញពីភ្នំកិកអង់សានហើយ ក៏ប្រឹក្សានឹងតេងជីថា: ឥឡូវកងទ័ពពួកយើងនៅភ្នំកិកអង់សាននោះលើកបយអស់ទៅហើយ, មុខជាសុម៉ាអ៊ីនឹងលើកតាមទៅពុំខាន, អ្នកឯងចូរគិតគានសារសេរអក្សរចុះនៅទង់ជាឈ្មោះយើង, បើឃើញសុម៉ាអ៊ីលើកមកតាមកាលណា, ចូរនាំពលយោធាស្រូតតែតម្រង់ទៅផ្លូវធំ, ឯខ្ញុំនឹងនាំទាហានតូចដើរទៅតាមដងព្រៃ, ពួកសុម៉ាអ៊ីឃើញគ្នាយើងតិចណាស់នៃក៏គង់នឹងរៀសរៀវដេញតាមទៅ, យើងនឹងចូងផ្លូវចេញខ្ទប់ពីក្រោយកុំឲ្យគេបទាន់, អ្នកឯងត្រូវត្រឡប់ទ័ពជញ្ជាន់មកពីមុខឲ្យជាប់, មុខជាកងទ័ពសុម៉ាអ៊ីនឹងបែកពុំខាន, លុះប្រឹក្សាគ្នាឃើញផ្លូវលំគាប់សព្វគ្រប់ហើយ ក៏លើកពលចេញទៅរៀងខ្លួនតាមដែលគិតគ្នា ។

ឯកោឈុយលើកទ័ពទៅតាមបង្គាប់សុម៉ាអ៊ីគ្រានោះ, ក៏កំជាប់លើឈ្មោះដៅហ៊ូថា: អ្នកឯងត្រូវនាំទាហានចេញទៅជាកងមុខគ្រានេះ, ត្រូវតែមើលកលការតាមអធ្យាស្រ័យ កុំបីធ្វេសប្រមាទដល់សត្រូវឡើយ, បើឃើញទ័ពជូឡុងហើយចាញ់រត់ទៅកាលណា, កុំឲ្យបំពារដេញតាមឲ្យសោះ, ត្រូវតែពរង់ចាំអស់គ្នាមើលកលការសិន, ព្រោះជូឡុងនោះជាចៅបញ្ញាចេះផ្អិនប៉ុនប្រសប់ព្រម រមែងចេះលួងលោមបញ្ឆោតឲ្យសត្រូវចាញ់ដោយកលឧបាយ, ហើយទាំងថ្វីដៃក៏ពូកែឆើតឆាយគ្មាននរណាស្មើ ត្រូវតែមើលឲ្យសព្វ គួរថយឲ្យថយ គួរឈប់ឲ្យឈប់ ។

ដោហ៊ូថា: លោកកុំបីព្រួយបារម្ភឲ្យសោះ, ការត្រង់ណោះជាធុរៈលើខ្ញុំបាទ, ឯថ្វីដៃជូឡុងនោះ ខ្ញុំក៏សង្វាតនឹងពង់ល្បងឲ្យឃើញគ្នា ខ្ញុំបាទក៏មិនពាញញើតប៉ុន្មាន, សុំឲ្យលោកលើកទាហានជំនួយទៅឲ្យទាន់ការចុះ, បើខ្ញុំបាទបានប្រទះនឹងជូឡុងវេលាណា នឹងអាសាចាប់ខ្លួនឲ្យបាន, ថាហើយដៅហ៊ូក៏លើកទាហាន ៣.០០០ ស្រូតទៅដល់តំបន់គីកុក ឃើញទ័ពមខតេងជីដើរលេះលោំងរត់ទៅតាម ផ្លូវធំមានទង់ជ័យល្យំជាជួររៀងរាយ ឃើញអក្សរនៅចុងជាយថា "ជូឡុង" ក៏គិតថាជាជូឡុងពិត ៗ រឹតតែដេញទាហានបំពានតាមទៅ ចម្ងាយផ្លូវប្រហែល ៣០ សិន ( ១.២០០ម. ) ។

(នៅមានត)

# ជីវប្រវត្តិលោក ស៊ុង-ស៊ីវ



ឈ្មោះដើមក្នុង ក្នុងសំបុត្រកំណើត និងក្នុងអត្តសញ្ញាណប័ណ្ណ សរសេរឈ្មោះថា **"ចាវ-ស៊ុង-ស៊ីវ"** ក្នុងស្នាដៃនិពន្ធទាំងអស់ សរសេរត្រឹមតែ **"ស៊ុង-ស៊ីវ"** ។

## ជាតិបរិច្ឆេទនិងភូមិកំណើត

ទារក **ស៊ុង-ស៊ីវ** កើតនៅថ្ងៃព្រហស្បតិ៍ ១៥ កើត ខែ កត្តិក ឆ្នាំកុរ ព.ស. ២៤៦៥ គ.ស. ១៩២២ ក្នុងភូមិអន្លង់សំណ សង្កាត់កំពង់ជីក្រែង ស្រុកជីក្រែង ខែត្រសៀមរាប, បិតាឈ្មោះ **អាំង-ចាវ** មាតាឈ្មោះ **តាង់ - ស៊ុង** មានបងស្រីម្នាក់ឈ្មោះ **អាំង - លី** និងប្អូនស្រីម្នាក់ឈ្មោះ **អាំង-ឆាយ** ។

កាលកុមារ **ស៊ុង-ស៊ីវ** មានអាយុបីឆ្នាំ បិតាទទួលអនិច្ចកម្មដោយរោគាពាធទៅ, ឆ្នាំបន្ទាប់មក មាតាក៏ទទួលអនិច្ចកម្មទៀត ។ កុមារ **ស៊ុង-ស៊ីវ** និងបងប្អូនកំព្រាទាំងបីនាក់ រស់នៅក្នុងការថែរក្សា របស់ជីដូន ជីតាខាងមាតា នៅក្នុងភូមិ ស្រុក ដដែល ។

## ការសិក្សា

កុមារ **ស៊ុង-ស៊ីវ** មានអាយុ ៧ ឆ្នាំ ជីដូនជីតាបានឲ្យចូលសិក្សាវិជ្ជាអក្សរខ្មែរ-បារាំង ក្នុងសាលាបឋមសិក្សាកំពង់ក្ដី (ទីប្រជុំជន

ស្រុកដីក្រែង) ។ រៀនផុតថ្នាក់មធ្យមដ្ឋានក្នុងសាលានោះ ត្រូវទៅបន្តវិជ្ជាក្នុងខេត្តសៀមរាប ។ ពេលនោះបារាំងច្បាំងនឹងសៀម, ដោយឧបសគ្គនេះ ក៏អាក់ខានឈប់ទៅបន្តវិជ្ជាត្រឹមនោះ ។ ជីដូនជីតាបានឲ្យចូលទៅសិក្សាវិជ្ជាខាងពុទ្ធសាសនាវិញ, ឲ្យបួសជាសាមណេរក្នុងវត្តបុព្វទិសារាម (កំពង់គ្គី), តមកឲ្យបួសជាភិក្ខុក្នុងវត្តអន្ទង់សំណា (កំពង់ដីក្រែង) បានទៅប្រឡងយកវិញ្ញាបនប័ត្រសាលាបាលីរងក្នុងវត្តដំណាក់ (ខេត្តសៀមរាប) ជាប់លេខ ១ ។

ក្នុងព.ស. ២៤៨៧ គ.ស. ១៩៤៤ ភិក្ខុ **សុខ-ស៊ីវ** មកប្រឡងចូលរៀននៅសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ, ប្រឡងជាប់ហើយ បានសំណាក់នៅកុដិសម្តេចព្រះធម្មលិខិត (**លី-ឯម**) វត្តលង្កា ។ លុះសិក្សាគ្រប់ ៤ ឆ្នាំហើយ ប្រឡងយកសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ក្នុងព.ស. ២៤៩១ គ.ស. ១៩៤៨ ផុតថ្នាក់សិក្សាវិជ្ជា ផ្នែកពុទ្ធសាសនាក្នុងសម័យនោះ ។

## ជីវភាពផ្នែកបព្វជិត

ភិក្ខុ **សុខ-ស៊ីវ** នៅក្នុងវត្តលង្កាបាន ១ ឆ្នាំ កំពុងសិក្សាក្នុងថ្នាក់ទី ១ នៃសាលាបាលីជាន់ខ្ពស់, សម្តេចព្រះធម្មលិខិត (**លី-ឯម**) បានតែងតាំងជា “បាឡាត់ឧត្តមលិខិត” សំរាប់ទទួលភារៈទាក់ទងជាមួយក្រសួងធម្មការ និងក្រសួងព្រះសង្ឃនាយកតាមបញ្ជារបស់សម្តេច ។

កាលភិក្ខុ **សុខ-ស៊ីវ** នៅសិក្សាក្នុងថ្នាក់ទី ១ ទី២ នៃសាលាបាលី

ជាន់ខ្ពស់បានសរសេរសៀវភៅពីរមុខ ដោះពុម្ពផ្សាយជាសាធារណប្រយោជន៍ គឺសៀវភៅវេយ្យាករណ៍ ទីប និង សភាសិតសង្គ្រោះ ។ លុះចប់ការសិក្សាប្រឡងយកសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់បានហើយ,សម្ដេចព្រះធម្មលិខិតប្រគល់ការៈឲ្យធ្វើគ្រូបង្រៀនសាលាបាលីក្នុងវត្តលង្កា និងប្រគល់សិទ្ធិឲ្យរៀបចំការសិក្សាក្នុងសាលាបាលីរង់វត្តលង្កា ឲ្យមានរបៀបទាន់សម័យផង ។

អាចារ្យ **ស៊ុខ-ស៊ីច** បំពេញការៈនេះបានសម្រេចតាមបំណងសម្ដេចអស់ការៈ ៤ ឆ្នាំ, ឆ្នាំទាំង៤នេះហើយជាឆ្នាំសំខាន់បំផុតក្នុងជំនោរជីវិតរបស់ខ្លួន ខាងការជួយព្រះពុទ្ធសាសនា គឺបានបង្ហាត់បង្រៀនភិក្ខុសាមណេរពប់ពាន់រូបផង បានជួយសមាគមមិត្តសាលាបាលីឲ្យបានទីស្នាក់ការស្ថិតនៅក្នុងវត្តលង្កាដល់សព្វថ្ងៃនេះផង នៅទេសនាក្នុងក្រុងនិងខេត្តនានាគ្រប់ប្រកល្អកបានជាទីគាប់អធ្យាស្រ័យអ្នកស្ដាប់ផង និងបានសរសេរសៀវភៅបោះពុម្ពផ្សាយចំនួន ១៥ មុខក្នុងពេលនោះផង គឺ សៀវភៅត្រៃភូជធម៌, ល្បើកប្រែតភាគ១, ប្រជុំនិទានជាតកភាគ១, ល្បើកប្រែតភាគ២, ធាយកបរិហារ, កប្បកថា, ប្រស្នាចតុប្បារិសុទ្ធិសីល, ទូរេនិទានប្បញ្ហា, ប្រជុំនិទានជាតកភាគ២, អរិយមគ្គាធិប្បាយ, ត្រៃលក្ខណៈប្រទីប, កម្មប្រទីប, ប្រជុំកថាវិន័យ, ប្រជុំពុទ្ធប្បញ្ញត្តិនិងសំយោគវិធាន ។ ផ្ទេកអចលនវត្ថុ បានសង់កុដិ១ ខ្នងក្នុងវត្តលង្កា ដោយបច្ច័យធម្មបូជាផ្ទាល់ខ្លួន តកការកែអក្ខរាស, ក្ដិបនេះមិនមែនសង់នៅផ្ទាល់

ខ្លួនទេ គឺសង់ហើយវេរចំពោះសង្ឃ រួចលាចាកសិក្ខាបទក្នុងថ្ងៃនោះ (ចុងឆ្នាំ ១៩៥២) ។

## លក្ខណៈពិសេស

អាចារ្យ **សុខ-ស៊ីវ** មានគុណភាព ខាងការនិយាយ និងការសរសេរស្មើគ្នា ។

## ជីវភាពផ្នែកគ្រហស្ថ

បណ្ឌិតមហា **សុខ-ស៊ីវ** មានអធ្យាស្រ័យម្យ៉ាង ប្លែកអំពីមិត្ររបស់ខ្លួនគឺ តាំងពីចាប់រៀនមក គ្មានបំណងផ្ញើរសនាលើសញ្ញាប័ត្រដើម្បីតាមទារកៅអីក្នុងដំណែងកងការណាមួយឡើយ បានតាំងចិត្តថា "ក្នុងជាតិនេះ មិនយកជីវិតខ្លួននិងជីវិតគ្រួសារទៅប្រជ្រៀតផ្ញើនឹងថវិកាជាតិឡើយ ត្រូវរស់នៅដោយមធ្យោបាយផ្សេង ហើយជួយបំពេញថវិកាជាតិវិញ" ។

ដោយឧត្តមគតិនេះមានជាទម្ងន់ នាំឲ្យបណ្ឌិតមហា **សុខ-ស៊ីវ** ចូនចិត្តគំនិតទៅក្នុងរបរពាណិជ្ជកម្មនិងឧស្សាហកម្ម ផ្សំនឹងសមត្ថភាពខាងការសរសេរមានបន្តិចបន្តួចផង ក៏ក្លាយខ្លួនទៅជាកូនឧស្សាហករមួយរូបក្នុងសម័យសង្គមរាស្ត្រនិយម, មិនបានបង់ខាតក្រដាសមួយសន្លឹកផ្ញើដីម៉ុង សុំប្រឡងប្រជែងដណ្តើមកៅអី ក្នុងដំណែងកងការណាមួយឡើយ។

អាស្រ័យហេតុនេះ, ក្នុងដើមឆ្នាំ១៩៥៣ បណ្ឌិតមហា **សុខ-ស៊ីវ** បានដាក់ខ្លួនជាកម្មករទៅស៊ីឈ្នួលកៃរញ្ញាសា ក្នុងរោងពុម្ពជនបរទេសមួយ

ដើម្បីសង្កេតពិនិត្យ រៀនហ្វឹកហាត់ កាយ វាចា ចិត្ត ជាឧស្សាហកឲ្យមានបទពិសោធន៍ក្នុងការទិញនិងលក់ ការគិតបញ្ជីបង់ពន្ធដារ ការប្រើកម្មករ ការប្រើគ្រឿងម៉ាស៊ីន និងការធ្វើតុផ្សេងៗ ដែលត្រូវផលិតពេញពីរោងពុម្ព ។

ដល់ឆ្នាំ១៩៥២បណ្ឌិតមហា **ស៊ុខ-ស៊ីវ** មានសមត្ថភាពគ្រប់គ្រាន់ជាផលិតករផ្នែករោងពុម្ពហើយ ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយនាង **យិម-ស៊ី** ដែលមានទីលំនៅក្នុងក្រុងភ្នំពេញ ។ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ហើយ បានបើករោងពុម្ពមួយឈ្មោះ "រោងពុម្ពជាតិ" ក្នុងឆ្នាំ ១៩៥៥ ។

ចាប់ពីឆ្នាំ១៩៥៥ ដល់មកឥឡូវនេះ ឧស្សាហករ **ស៊ុខ-ស៊ីវ** មានជីវភាពប្រព្រឹត្តទៅស្រួលតាមសមត្ថភាព បានបង់ពន្ធដារជូនរាជការជួយបរិការជាតិ ក្នុង ១ ឆ្នាំៗជាច្រើនម៉ឺនរៀលតាមការដែលផលិតបានច្រើនតិច ដល់ចុងឆ្នាំ ១៩៦៦ បើកបណ្ណាគារមួយទៀតឈ្មោះ "បណ្ណាគារប្រជាប្រិយ" ។

## សមាសភាពគ្រួសារ

ឧស្សាហករ**ស៊ុខ-ស៊ីវ** និងអ្នកស្រី **យិម-ស៊ី** មានកូនពីរនាក់គឺ :

១– កូនស្រីឈ្មោះ**ស៊ីវ-ភូជា**,

២– កូនប្រុសឈ្មោះ **ស៊ីវ-នាគសេន** ,

ផុតជីវប្រវត្តិត្រឹមឆ្នាំ១៩៦៦ នេះ, ពេលក្រោយនឹងបានតទៅទៀត ។

# ការសរសេរ

ស្នាដៃដែលអ្នកនិពន្ធ **សុខ-ស៊ីខ** បានសរសេរបោះពុម្ពផ្សាយរួចហើយ តាំងអស់មកទល់ឆ្នាំ ១៩៦៦ មាន ៣៥ មុខ ៖

១- វចនប្រទីប
២- សុភាសិតសង្គ្រោះ
៣- ត្រៃភូដធមិ
៤- ល្បើកប្រេតភាគ១ (កាព្យ)
៥- ប្រជុំនិទានជាតកភាគ ១
៦- ល្បើកប្រេតភាគ២ (កាព្យ)
៧- ទាយកបរិហារ
៨- កប្បកថា
៩- ប្រស្នាចតុប្បរិសុទ្ធសីល
១០- ទូរេនិទានបញ្ហា
១១- ប្រជុំនិទានជាតកភាគ ២
១២ អរិយមគ្គាធិប្បាយ
១៣- ត្រៃលក្ខណប្រទីប
១៤- កម្មប្រទីប
១៥- ប្រជុំកងវិន័យ
១៦- ប្រជុំពុទ្ធប្បញ្ញត្តិ
១៧- សំយោគវិធាន
(ត្រឹមទី១៧នេះសរសេរកាលនៅជាបព្វជិត) ។
១៨- ដំណើរពាក់កណ្ដាលសាសនា
១៩- ប្រជុំនិទានជាតក ភាគ ៣
២០- មធុរទេសនា
២១- សាសនប្រតិបត្តិ
២២- ប្រជុំរឿងព្រេងនិងភាសិត ភាគ ១
២៣- ប្រស្នាសាសនប្រតិបត្តិ
២៤- អនុបុព្វីកថាធិប្បាយ
២៥- អបាយមុខទំនើប (កាព្យ)
២៦- ប្រជុំរឿងព្រេងនិងភាសិត ភាគ ២
៤៧- កាសាវុទ្ធ
២៨- ប្រជុំនិទានជាតកភាគ ៤
២៩- ប្រវត្តិព្រះនាងឥសិកាសីថេរី
៣០- តម្រាឲ្យឈ្មោះកូន

៣១-វែកញែកទម្លាប់ទំនៀមឈាបនកិច្ច
៣២-ប្រជុំនិទានជាតកភាគ ៥
៣៣-ព្រះរស់
៣៤-សុជីវធម៌ប្រចាំសង្គមគ្រួសារ
៣៥-ជំនឿចាស់មនុស្សថ្មី . . . ។

សៀវភៅទាំង ៣៥ មុននេះ បានបោះពុម្ពផ្សាយជាច្រើនលើករៀងរាល់ឆ្នាំ ។

ធ្វើនៅថ្ងៃទី ៤-៧-៦៦

ហត្ថលេខា : សុង-ស៊ីវ

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

## របស់លោក រ៉ាប៊ិន្ទ្រណាត តាហ្គរ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សាល់

## (ក)

## វគ្គ ទី ៥២

ការរស់នៅរបស់នាងកាមាលា ប្រៀបបាននឹងត្រីរស់នៅក្នុងទឹកថ្លុកភក់តូចមួយ ហើយទឹកនោះសោតក៏ពុំថ្លាល្អផង បើចង់ឲ្យរួចចេញពីកន្លែងនេះ មានតែលួចរត់ ប៉ុន្តែដឹងជារត់ទៅទីណាទៀត បើនាងមិនស្គាល់កន្លែងណាសោះ ម្យ៉ាងទៀត ការដែលនាងលួចរត់ទាំងយប់ងងឹតលើកមុន ធ្វើឲ្យនាងរាងចាលទៅហើយ ព្រោះថា លោកខាងក្រៅជាទីគួរខ្លាចទាំងអស់នៅពេលរាត្រី ម្ដេចឡើយនាងនឹងហ៊ានប្រថុយម្ដងទៀត ។

លោកយាយណាបឹកាលី គាត់ស្រឡាញ់នាងមួយបែបដែរ ប៉ុន្តែរបៀបដែលគាត់ស្រឡាញ់នាងនោះ នាងរកយល់គុណគាត់មិនកើត នាងសុខចិត្តធ្វើការជួបគោ-ក្របី ជាជាងនៅអង្គុយជាមួយលោកយាយនេះ ។

ថ្ងៃមួយលោកយាយ ហៅនាងមកស្តីបន្ទោសពីរឿងខ្ជះខ្ជាយ ៖

– នែ! កាមាណា អញមិនមែនថាឯងមិនចេះធ្វើបាយទឹកទេ តែឯងខ្ជះខ្ជាយពេក មិនដឹងជាទិញរបស់នោះមកធ្វើអ្វីខ្លះ? ឃើញតែទិញ?

ពេលលោកយាយស្តីបន្ទោស នាងកាមាណាធ្វើជាមិនឮ គិតតែធ្វើការ ប៉ុន្តែនាងខឹងតឹងដើមទ្រូងកនិយាយមិនកើត ហើយបែរជាមកគិតថា អ្វីក្នុងលោកនេះគឺជាទុក្ខទាំងអស់ រីឯការរស់នៅទៀតសោតក៏ជាអម្រែករបស់មនុស្ស" ។ កំពុងតែនឹកដូច្នេះ នាងទ្រឹងត្រចៀកដោយឮលោកយាយហៅឈ្មោះមនុស្សម្នាក់ ។ លោកយាយស្រែកប្រាប់ក្មេងដែលទៅទិញឥវ៉ាន់ថា ៖

– ខូលស៊ុ ឯងឈៀងចូលទៅអញ្ជើញលោកវេជ្ជបណ្ឌិតណាលីណាក់ស្ហាផង ជម្រាបលោកថាអញមិនស្រួល ។

លោកណាលីណាក់ស្ហា! រំពេចនោះ រន្ទះរស្មីចាំងចេញពីកែវភ្នែកនាងកាមាណា បីដូចជាចង្កៀងពិលដែលត្រូវដៃចុចចំកន្ទុំសនេះ ។ នាងទម្លាក់ចន្ទុះចោល ហើយស្ទុះទៅកិចនៅក្បែរមាត់ទ្វារ ចាំស្ទាក់ផ្លូវខូលស៊ុ ។ ខូលស៊ុចុះមក នាងចាប់ដាប់ ហើយសួរថា៖ "លោកវេជ្ជបណ្ឌិតណាលីណាក់ស្ហាជាអ្នកណា?"

– ជាគ្រូពេទ្យមួយល្បីល្បាញណាស់ក្នុងទីក្រុងនេះ ។

– លោកនៅឯណា?

នាងកាមាលាចិត្តល្អនឹងអ្នកបម្រើនៅផ្ទះជាមួយគ្នាណាស់ ដូចកាលនាងត្រូវចៅហ្វាយស្តីបន្ទោសដោយសារតែរឿងនេះផង ប៉ុន្តែនៅពេលដែលខ្ញុំលស៊ីរៀបនឹងឆ្លើយប្រាប់នាង ស្រាប់តែសម្លេងលោកយាយស្រែកខ្លាកពីលើមក :

- ឯងជំនុំឥនៅមាត់ទ្វារផ្ទះបាយទឹង មើចស្មានថាអញមិនមើលទេឬ? ឥចឹងតើបានតែមីនោះចាយលុយអញឥតសំចៃដៃយ៉ាងនេះ អាឯងទៅផ្សារចាំបាច់ទៅសុំច្បាប់មេធ្វើបាយដែរឬយ៉ាងម្តេច? រួចមីនោះទៀតឥតឹងាប់ភ្លេចម្ទេះ? កាលអញរើសវាមក អញអាណិតឲ្យជំបូលជ្រក ឥឡូវវាសងគុណអញក្លាម . . . ។

នាងកាមាលាស្ទុះចាប់គារក្លាម ប៉ុន្តែនាងមិនភ្លេចឃ្មាំមើលផ្លូវខ្ញុំលស៊ីត្រឡប់មកវិញទេ ខ្ញុំលស៊ីត្រឡប់មកវិញតែម្នាក់ឯង នាងស្ទុះទៅតែបមាត់ទ្វារទៀត :

- លោកពេទ្យ មិនអញ្ជើញមកទេឬ ? ខ្ញុំលស៊ី ?

- ម្តាយគាត់ឈឺដែរ គាត់មិនបានមកទេ ?

- ចុះគ្មានអ្នកណាថែម្តាយក្រៅពីលោកទេឬ ? លោកឥតមានប្រពន្ធទេឬ ?

- ឥតមានទេ អ្នកបម្រើលោកម្នាក់និយាយប្រាប់ខ្ញុំថា កាលពីដើមលោកនៅឯរ័ត្នបុរី . . . ។

- ខ្ញុំលស៊ី ! ! ! ( លោកយាយស្រែកចំពាលពីលើមក )

នាងកាមាលារត់ត្រង់កន្ទុយចូលទៅក្នុងជើងក្រាន្ត ។

ណាលីណាក់ស្ហា ! រ៉ង្គបូរ៍ ! នាងកាមាលាឈប់សង្ស័យៈហើយម្តងនេះ !

លុះដល់ល្ងាច នាងកាមាលាឆ្លៀតឱកាសសួរទូលស៊ីម្តងទៀត

– ទូលស៊ី ! ខ្ញុំមានបងប្អូនម្នាក់ឈ្មោះដូចលោកគ្រូពេទ្យនេះដែរណា៎ តើលោកជាត្រកូលព្រាហ្មណ៍ដែរមែនទេ ?

– មែន !

នាងកាមាលាឡើងទៅជម្រាបលោកយាយ សុំទៅងូតទឹក ត្បិតកិច្ចការទាំងអំបាលម៉ាន នាងធ្វើរួចហើយ ។

– ឯងចង់ចេញទៅងូតទឹកពេលហ្នឹងខុសហើយ ឯងដឹងទេ ប្តីអញកំពុងតែមិនសូវស្រួល បន្តិចត្រូវការនេះ បន្តិចត្រូវការនោះ ហើយបើឯងទៅបាត់បានអ្នកណាហុចនេះ ហុចនោះជូនគាត់ ម្យ៉ាងទៀត ចុះវាដល់អ៊ីទៀតហើយ ក៏ស្ទួនទៅរកងូតទឹកថ្មីនេះ ៗ

– ចាសលោកយាយ ខ្ញុំបានដឹងដំណឹងថាបងប្អូនខ្ញុំម្នាក់ នៅក្នុងទីក្រុងបេណារេសនេះដែរ បានជាខ្ញុំចង់ទៅជួបគាត់មួយភ្លែត ។

– នុ ! អ៊ុចឹង ! ទេ ! ដរាបណាឯងនៅបម្រើអញ អញគ្មានឲ្យឯងដើរទៅរកបងប្អូនណាៈទេ . . . . ?

រំពេចនោះ លោកយាយកំណាចដេញទូលស៊ីភ្លាម ហើយគ្មានឲ្យ

ប្រាក់កាសអ្វីទាំងអស់ ថែមទាំងហាមមិនឲ្យរត់ដើរមកក្បែរផ្ទះ គាត់ទៀតផង មិនតែប៉ុណ្ណោះសោត គាត់ហាមអ្នកបម្រើទាំងអស់កុំឲ្យមានការទាក់ទងអ្វីជាមួយនឹងនាងកាមាលាឲ្យសោះ ។

នាងកាមាលាខំអត់ណាស់ ប៉ុន្តែមានការអ្វី នាងតែងតែស៊ូទ្រាំជានិច្ច ?

- ឯងស៊ូទ្រាំរឿងអ្វី (លោកយាយកំណាចសួរនាង) ឯងចង់អត់បាយ អត់ទៅ តែឯងគ្មានច្បាប់បង្ខំឲ្យគេអត់តាមឯងទេ ?

- លោកយាយ ខ្ញុំលែងចង់នៅជាមួយលោកយាយតទៅទៀតហើយ ខ្ញុំទ្រាំរស់នៅទីនេះមិនបានទេ ឲ្យខ្ញុំសុំឈប់ទៅលោកយាយ ។

ហ្ន៎ ! ឃើញទេ តែចង់យកអាសារគេបានផលល្អភ្លាម គិតទៅមនុស្សយើងហ្ន៎ (លោកយាយនិយាយហើយសើចចំអក) ន្ហែ ! តស់មើលទៅ បើឯងចង់ ឯងមុខជាប់ដៃប៉ូលិសមិនខាន កូនអញធ្វើចៅក្រម តែវាថាមួយម៉ាត់ មុខជាអាសន្នធំហើយ កុំចង់លជាមួយនឹងអញមីនាង បើឯងមិនចង់ស្គាល់គុកទេ . . . ?

- ឃើញទេ នៅពេលដែលនាងកាមាលា មើលឃើញសុភមង្គលស្ទើរតែនឹងពាល់ត្រូវទៅហើយ ស្រាប់តែគេដាក់ខ្នោះដៃជាប់ ប៉ុន្តែឲ្យនាងទ្រាំនៅទៀតម្ដេចកើត បើមួយថ្ងៃក្ដៅបន្តិចមួយថ្ងៃក្ដៅបន្តិចយ៉ាងនេះ ពល់ល្ងាច តែកាលណានាងធ្វើការរួចអស់ហើយ នាងតែងដណ្ដប់

ក្រមាទៅឈរគើតតាមកំផែង មើលទៅផ្លូវដែលតម្រង់ទៅផ្សារ ប៉ុន្តែការសប្បាយរបស់នាងមិនមានអាយុវែងទេ ម្តងនោះ លោកយាយណា-ប៊ិនកាលីចូលទៅរកនាង នៅក្នុងផ្ទះបាយមិនឃើញ គាត់កាន់ចង្កៀងដើរជ្រោងមើលពេញផ្ទះ លុះឃើញនាងដើរចូលមក គាត់ជេរប្រទេចា នាងកាមាលាក្តៅណាស់មិនយំទេ នាងឈរយ៉ាងក្រអឺត ហើយវាត់សម្តីឲ្យគាត់វិញ :

– បើលោកយាយមិនពេញចិត្តនឹងខ្ញុំទេ ម្តេចមិនឲ្យខ្ញុំឈប ទុកខ្ញុំនៅធ្វើអ្វី ?

– អញមុខជាគ្មានទុកក្បាលឯងទេ អញមិនត្រូវការចិញ្ចឹមមក្រពើទុកក្នុងផ្ទះអញទេ ប៉ុន្តែមុននឹងបណ្តេញក្បាលឯងចេញ អញត្រូវធ្វើឲ្យឯងស្គាល់ដៃអញ បិន មក្រពើ . . . . ?

មួយថ្ងៃក្រោយមក ពេលល្ងាច ប្តីលោកយាយចេញទេះទៅដើរលំហែកាយ នាំទាំងអ្នកបម្រើពីរនាក់ទៅផង គាត់យកប្រវាក់ចាក់ទ្វារជាប់ គ្មានឲ្យអ្នកណាមួយចេញបានឡើយ គាប់ជួនពេលនោះ ឮមាត់មនុស្សហៅពីក្រៅ លោកយាយកំណាចស្រែកប្រើនាងកាមាលា

– កាមាលា ! លោកពេទ្យណាលីណាក់ស្ហាអញ្ជើញមកហើយ រត់ទៅបើកទ្វារជូនលោកមួយភ្លែត អញ្ជើញលោកចូលមក ហើយជម្រាបលោកថា ឲ្យចាំអញបន្តិចសិន . . . . . ។

នាងកាមាលាពុទ្ធោះ ញ័រដៃញ័រជើង អរផងភ័យផង នាងរត់ទៅយកចង្កៀងត្រជាក់ដៃដូចទឹកកក យកក្រមាចងមុខ រួចរត់ទៅបើកទ្វារជូនលោកណាលីណាក់ស្ហា .... ។

នាងអញ្ជើញភ្ញៀវចូលអង្គុយ រួចនាងថយចេញទៅលបមើលភ្ញៀវពីខាងក្រៅ ទឹកភ្នែកនាងហូរសស្រាក់ លោកគ្រូពេទ្យអង្គុយចាំម្ចាស់ផ្ទះ ហាក់ដូចជារវល់ចិត្តនឹងរឿងអ្វីមួយ តែនៅពេលនោះ មូគុនជាដើរចូលមក នាងកាមាលាក៏រត់ចូលទៅក្នុងផ្ទះបាយភ្លាម នាងសម្ងំចាំស្តាប់ ក្រែងព្ទលោកគ្រូពេទ្យចេញទៅវិញ ទឹងអាលបានទៅមើលមុខលោកម្តងទៀត នាងចេះតែសន្ទិសក្នុងចិត្តថា " ចុះបើរូបគេល្អម៉្លេះ ម្តេចឡើយនឹងទៅជាប្តីនាងកើត ប៉ុន្តែចិត្តមួយទៀតនាំឲ្យនាងនឹកថា ការដែលនាងត្រាំរង់កម្មជាយូរឆ្នាំនេះ មិនសមបើឥតអំពើឡើយ គឺនាងត្រូវតែទទួលផលល្អម្តង ទឹកហើយ នាងលើកដៃបិតទូលលើក្បាល អរ-គុណព្រះជាម្ចាស់ ដែលលោកមានភ្នែកទិព្វត្រចៀកទិព្វ ។

បន្តិចមក នាងព្រួសលោកគ្រូពេទ្យលាទៅវិញ មានអ្នកបម្រើម្នាក់កាន់ចង្កៀងជូនដំណើរទៅផង នាងរត់ទៅពួនក្បែរមាត់ទ្វារលបមើលម្តងទៀត នាងមើលបណ្តើរទឹកក្នុងចិត្តបណ្តើរ " នុ ! ម្ចាស់ចិត្តខ្ញុំអើយ ខ្ញុំនៅក្បែរអ្នកបង្អើយ បិនឆ្ងួរឡើយអ្នកមកដល់ហើយមើលខ្ញុំមិនឃើញ ឲ្យខ្ញុំរស់នៅទាំងវេទនាក្រោមដំបូលអ្នកដទៃ " នាងដើរចូលទៅក្នុងសាឡុង

ទៅអង្គុយកៅអីដែលលោកគ្រូពេទ្យបានអង្គុយ . . . . ។

ព្រឹកស្អែកឡើង នាងឮម្ចាស់នាងនិយាយថា លោកគ្រូពេទ្យបានបង្គាប់ឲ្យគាត់អញ្ជើញទៅនៅមាត់សមុទ្រ ដើម្បីឲ្យជំងឺគាត់ឆាប់ស្បើយ ម្ចាស់ផ្ទះក៏រៀបចំដំណើរ ដើម្បីនឹងទៅនៅយូរខែនៅទីក្រុងមួយ នៅខាងលិចក្រុងបេណារេស នាងឆ្លៀតឱកាសចូលទៅជម្រាបចៅហ្វាយ :

– ជម្រាបប្រសាសន៍លោកយាយ ខ្ញុំមិនចង់ចេញពីបេណារេសនេះទេ ?

– ឯងត្រូវតែទៅ តែអញទៅនៅឯនោះកើត ឯងត្រូវតែនៅកើតដែរ អីក៏ស្រឡាញ់បេណារេសឃ្លាតមិនបានអ៊ីក្លាមទៅហើយ ?

– ទេលោកយាយ ខ្ញុំចង់នៅឯនេះវិញ ។

– ចុះឯងឲ្យអញទៅរកអ្នកធ្វើបាយឯណាភ្លាមបាន បើឯងមកប្រាប់អញឆាប់យ៉ាងនេះ . . . . ។

## វគ្គទី ៥៣

មួយថ្ងៃបន្ទាប់អំពីថ្ងៃដែលលោកតាភាណាជា-បាប៊ូបាននិយាយអំពីរឿងចង់រៀបចំកូនមក លោកត្រូវវិបត្តិសុខភាពយ៉ាងខ្លាំង ដូចកាលដែលគាត់ទៅឯកាល់កុត្តាឯនោះ ។ គ្រាន់តែមិនស្រួលតែប៉ុន្មានម៉ោង

សោះ មើលទៅមុខលោកហាក់ដូចជាឈឺកប់ឆ្នាំរួចមកហើយ តែកាលណានាងហិមណាលីនីសម្លឹងមើលមុខឪពុក នាងចេះតែនឹកស្ដាយ ព្រោះថា ឪពុកឈឺដោយសារតែនាងមិនព្រមរៀបការជាមួយនឹងអាក់ស្ហាយ តែនាងទាល់គំនិត មិនដឹងជាធ្វើដូចម្ដេច ។

នាងកំពុងតែនឹកដូច្នេះ ស្រាប់តែឃើញអាក់ស្ហាយដើរចូលមក នាំទាំងលោកមាឃកផង នាងប្រែស្រឡាំងកាំង ដោយឃើញមនុស្សប្លែក ។

— លោកពូនេះឈ្មោះចក្រពត្តិ នៅគ្រាស៊ីបុរី នៅក្នុងស្រុកនោះអ្នកណាក៏ស្គាល់គាត់ដែរ (អាក់ស្ហាយនិយាយ) លោកពូមានការមួយសំខាន់ណាស់ ចង់ជម្រាបលោកអ៊ុំនឹងអ្នកនាង ។ ភ្ញៀវទាំងពីរនាក់ ក៏ទម្លាក់អង្គុយលើបង្កាន់ដៃថ្កៀវលោកតា ដែលគេបាននាំគាត់មកឲ្យអង្គុយនៅក្នុងសួន ដើម្បីឲ្យត្រូវថ្ងៃខ្លះ លោកមាចាប់ផ្ដើមនិយាយ :

— គេបានប្រាប់ខ្ញុំថា ការមេស្ហជាសម្លាញ់របស់លោក ហើយខ្ញុំចង់បានដំណឹងអំពីប្រពន្ធគេនោះ គ្រាន់តែឮពាក្យផ្ដើមប៉ុណ្ណោះ លោកតាការណាថ បាប៊ូ ចង់របូតដង្ហើម នាងហិមណាលិនីដាក់មុខចុះ ។ លោកមានិយាយបន្ត ៖

— លោកទាំងអស់គ្នាមុខជាយល់ថា ខ្ញុំជាអ្នកលេងដើងចាស់ ហើយថែមទាំងស្អប់ខ្ញុំផង ប៉ុន្តែបើសិនជាលោកស្ដាប់ខ្ញុំបន្តិចសិន លោកនឹងយល់ថា ខ្ញុំមិនមែនខំធ្វើដំណើរចម្ងាយប៉ុណ្ណោះមក ដោយឥតការទេ

លោក ខ្ញុំសូមជម្រាបលោកថា គ្មានអ្នកណាមួយដែលបានឃើញនាងកាមាលាហើយ ថាមិនស្រឡាញ់ទេ ៗ រូបខ្ញុំនេះជាមនុស្សច្នឹកក្នុងរឿងទទួលទុក្ខ ហាប់ស្បែក រឹងសាច់ បេះដូងខ្ញុំចង់ក្លាយទៅជាថ្មអស់ទៅហើយ តែខ្ញុំរកបំភ្លេចកូននោះមិនបានសោះ ព្រោះអ្វី ? ព្រោះកាលដែលខ្ញុំបានជួបនឹងនាងនេះជាដំបូង គឺនៅលើកប៉ាល់ នាងកាមាលានឹងខ្ញុំហាក់ដូចជាមាននិស្ស័យនឹងគ្នា គ្រាន់តែស្គាល់គ្នាភ្លាមដូចជាបេះតែឲ្យខ្ញុំចូលចិត្តនឹងនាង នាងក៏បាននិយាយនឹងរាមេស្ហ ឲ្យទៅនៅឯគ្ហាស៊ីបុរីៗ កូនស្រីខ្ញុំស្រឡាញ់នាងជាដំបងស្រីរាទៅទៀត តែមិនដឹងជាយ៉ាងម្ដេចស្រាប់តែនាងនោះគេបោលយើងទាំងអស់គ្នាទៅវិញ បានជាខ្ញុំមិនអស់ចិត្តសោះ ។

— ចុះឥឡូវនេះនាងទៅនៅឯណាទៅ ? (លោកតាកាណាជាបាប៊ូសួរបន្ថែម) :

— លោកកាក់ស្ហាយបាប៊ូ លោកជ្រាបរឿងរ៉ាវគ្រប់សព្វអស់ហើយ ម្ដេចមិនជម្រាបលោកទៅ ខ្ញុំនិយាយមិនចេញទេ អួលណែនអស់ហើយ (លោកមាននិយាយ)

កាក់ស្ហាយដែលរង់ចាំតែបានឱកាស នឹងខ្លាក់សំពុយលើរូបរាមេស្ហ គ្មានបាច់ឲ្យអ្នកណាអង្វរយូរទេ ប៉ុន្តែ ទោះជារាមិនបញ្ចេញបញ្ចូលក៏ដោយ ក៏រាចំរៀបសេចក្ដីយ៉ាងណាឲ្យតែខាងបានកាក្រក់ទៅលើរាមេស្ហ ៗ លុះ

អាក់ស្ហាយបន្ទូរពោះអស់ហើយ លោកអាណាដាប៉ាប៊ីឆ្លើយ :

— រឿងប៉ុណ្ណឹងមានទាន់អស់ឯណា បើចាប់តាំងពីពមេស្ហាចេញ ពីកាលគុត្តាទៅ យើងគ្មានបានដំណឹងអ្វីអំពីវាទាល់តែសោះ ។

— ទេលោកអុំ ការចម្លែកនោះគឺថា បើស្រីនោះជាមនុស្សល្អហើយ គួរអ្វីឡើយនឹងធ្វើបាបគ្នាឲ្យរងទុក្ខ ? ក្នុងរឿងនេះព្រះជាម្ចាស់ដូចជាគ្មានយុត្តិធម៌សោះ ព្រោះលោកឲ្យទុក្ខយ៉ាងធ្ងន់ ទៅលើមនុស្សដែលគ្នាមិនត្រូវទទួលទេ ។

លោកតាអាណាដាប៉ាប៊ីយកដៃច្រងសក់ បែបទឹកសង្វេគដែរ ហើយនិយាយតិចៗថា :

— រឿងនោះកំសត់ណាស់មែនហើយ ប៉ុន្តែឲ្យយើងទៅធ្វើម្តេច ? ម្យ៉ាងទៀត បើយើងកើតទុក្ខជួសគេទៅ ក៏ឯងឯងដែរ តាមយថាកម្មរបស់គេទៅចុះ ។

— លោកអុំ មតិខ្ញុំយល់ថា នាងកាមាណាមិនមែនស្លាប់ខ្លួនទេ នាងអាចភៀសខ្លួនចេញទៅពួនទៅទីកន្លែងណាមួយ ដូចនេះហើយបានជាលោកមានិងខ្ញុំមកតាមដល់ទីនេះ ព្រោះខ្ញុំចង់ដើរស៊ើបរកនាងនៅបេណារេសនេះ ។

— ចុះករមេស្ហ វាទៅណាទៅ ? (លោកអាណាដាប៉ាប៊ីសួរ)

– កាលក៏ណាខ្ញុំទៅ ក៏ឥតបានប្រាប់ខ្ញុំថាទៅទីណាទេ (លោកមាឆ្លើយ)

អាក់ស្ហាយឆ្លើយកាត់ក្លាម

– គេបានជួបទឹងក៏នៅកាលគុត្តា ?

គៀវតាំងពីរនាក់ក្រោក ជម្រាបលាម្ចាស់ផ្ទះ តែលោកតាអាណាជាបាប៊ូឃាត់អាក់ស្ហាយឲ្យនៅបន្តិចសិន . . . ។

– សុំទោសតាន ខ្ញុំបាទនៅមិនបានទេ ។ ចាំលើកក្រោយ ត្បិតខ្ញុំមិនទាន់អស់ចិត្តអំពីរឿងនាងកាមាលាសោះ ។ លោកអ៊ុំគិតមើល តើរឿងនេះ ក៏ទៅជាយ៉ាងម្ដេចទៅ បើនាងធ្លាប់តែរស់នៅដោយមានគេថ្នាក់ថ្នម . . . ប្រសិនជាកមេស្ហក៏មិនវិលដូច្នោះមែន ក៏ស្រេចតែក៏ទៅចុះ តែចំណែកខ្ញុំ ខ្ញុំវេទនាចិត្តណាស់ កាលបើបានដឹងថានាងត្រូវរងទុក្ខដូច្នេះ ។

ថាហើយ អាក់ស្ហាយនិងលោកមាដើរចេញវឹងក្លាម ទុកលោកតាអាណាជាបាប៊ូឲ្យអង្គុយសម្លឹងមុខកូន បែបដូចជាចង់ដឹងដល់ជម្រៅចិត្តកូនខ្លាំងណាស់ ។ នាងហាមណាលីដឹងខ្លួនច្បាស់ថា ឪពុកព្រួយនឹងរូបនាង នាងខំធ្វើចិត្តឲ្យរឹង ដើម្បីកុំឲ្យស្លុត ក្នុងរឿងដែលគេទើបនាំមកប្រាប់នោះ នាងធ្វើបុកក៏បា ហើយនិយាយទៅកាន់ឪពុកថា :

— ពុក ! ពុកត្រូវតែឲ្យពេទ្យពិនិត្យពេតពុកឲ្យហ្មត់ចត់ ធ្វើលេង ៗ មិនបានទេ ។

ឮកូននិយាយទៅឯណាព្រះអើយដូច្នេះ លោកតាអរអើយសែនអរ នៅពេលសព្វដងរៀងមក តែនាងនិយាយរំពុកដូច្នេះ លោកតាតែងប្រកែកមិនស្តាប់ទេ តែពេលនេះលោកយល់ស្របតាំងតែកាយ ។

- គំនិតកូនត្រូវដែរ ម៉េចប្រើក្មេងឲ្យទៅអញ្ជើញលោកណាលីណាក់-ស្ហាប្ដូយ៉ានម៉េច ?

កាលបើបានឮឈ្មោះលោកណាលីណាក់ស្ហាក្លាម នាងមិនសប្បាយចិត្តសោះ ព្រោះនាងនឹកថា បើសិនជាលោកនេះមកជួបនឹងនាង គឺនាងត្រូវប្រើសេចក្ដីក្លាហានយ៉ាងសម្បើម ដើម្បីនឹងធ្វើឲ្យមានការស្និទ្ធស្នាលដូចដើមវិញ ប៉ុន្តែ ទោះជានាងមិនពេញចិត្តក៏ដោយ នាងត្រូវតែប្រើក្មេងឲ្យទៅអញ្ជើញលោកមកដែរ ។ លោកតាឃើញទឹកមុខនាងមិនប្រែប្រួល ក៏ចាប់ផ្ដើមនិយាយអំពីរឿងចម្រូងចម្រុះនោះ :

- ដូច្នេះ ហ៊ឹម ណាលីទីកូន រឿងការមេស្ហនោះគឺថា .. ..

- ពុក ថ្ងៃកាន់តែក្ដៅណាស់ហើយ ពុកត្រូវអញ្ជើញចូលវិញ ( នាងឆ្លើយកាត់ប្រសាសន៍ពុក )

ថាហើយ នាងអូសកៅអីលោកតាចូលជ្រកម្លប់ក្លាម គ្មានទុកពេលឲ្យលោកប្រកែកទាន់សោះ នាងយកកាសែតមកដាក់ក្នុងដៃលោក លើក

វែនតាដាក់ទៅនឹងភ្នែកលោកហើយថា :

ពុកមើលកាសែតលេងទៅ ខ្ញុំមានការបន្តិច ។ (រួចនាងចេញបាត់ទៅ)

លោកតាទំអានកាសែតតាមបង្គាប់កូន តែលោកមើលអ្វីក៏មិនដក់ភ្នែកសោះ ព្រោះខួរក្បាលលោកជាប់តែនឹងរឿងកូន ។ បាត់នាងយូរពេក លោកមិនអស់ចិត្តទេ ក្រោកដើរទៅគេមើលកូន ឃើញនាងទៅសំងំក្នុងបន្ទប់តែម្នាក់ឯង ។

លុះព្រលោកគ្រូពេទ្យអញ្ជើញមក នាងចេញមកទទួលលោកដូចធម្មតា ។ លោកគ្រូពេទ្យពិនិត្យលោកតារួច ងាកយកសួរនាងថា មានការអ្វីនាំឲ្យលោកតាព្រួយចិត្តឬ បានជាលោកមិនស្រួលបែបនេះ នាងឆ្លើយយ៉ាងខ្លីថា មានមែន ...

- សូមនាងខំជៀសវាងកុំឲ្យលោកតាព្រួយ ទើបធាប់ស្រាន្ត ។

ខ្ញុំមានការលំបាកនឹងថែម្ដាយខ្ញុំដូចនាងដែរ តែមានការអ្វីបន្តិច គាត់ឆាប់ភ័យហើយគិតមិនឈប់ឈរសោះ បានជាខ្ញុំពិបាកនឹងថែគាត់ឲ្យមានសុខភាពទឹនខល្អណាស់ ។

– លោកក៏ដូចជាមិនសូវសប្បាយក្នុងខ្លួនដែរ មើលទៅ (នាងសង្កេត)

– មែនហើយនាង ព្រោះយប់មិញខ្ញុំគ្មានបានដេកលក់ស្រួលទេ

ទេ រស់តែគាត់ហៅ ។

– គួរតែលោករកមនុស្សណាម្នាក់ ដើម្បីឲ្យថែដំទីនៅជាប់ជាមួយម្តាយលោកទៅ. . . ។

នាងនិយាយមិនបានគិត លុះសម្តីចេញផុតពីមាត់ទៅហើយ ទើបនាងនឹកឃើញ នឹកខ្មាស់សម្តីរបស់ខ្លួន ឡើងមុខក្រហម ដោយភ័យក្រែងលោកគ្រូពេទ្យយល់ថានាងបន្ទុយសម្តី ម្ល៉ោះហើយនាងខំកែបន្ថែមសេចក្តីថា ។

– តើលោកយល់ដូចម្តេច បើសិនជាខ្ញុំរកក្មេងម្នាក់ជូនលោកសម្រាប់បម្រើលោកយាយ ?

មកដល់ត្រង់នេះ នាងឱបមួយសន្ទុះ រួចទើបនិយាយបន្ត :

តែកាលណាខ្ញុំចង់ធ្វើតាមសេចក្តីព្រមានរបស់លោក ខ្ញុំជួបនឹងឧបសគ្គជាដរាប ខ្ញុំមិនដែលធ្វើអ្វីឲ្យបានសម្រេចដូចបំណងឡើយ ដូច្នេះហើយបានជាខ្ញុំចេះតែអស់សង្ឃឹម ។ បើដូច្នេះ តើកាលណាទើបខ្ញុំនឹងរកសេចក្តីសុខឃើញ បើចេះតែមានការពីក្រៅចូលមករំខានគ្មានឈប់យ៉ាងនេះ ។

– ឧបសគ្គដែលនៅកើតជួបយើង ធ្វើឲ្យយើងរឹតតែមានកម្លាំងប្រឹងទៀត កុំអាលអស់សង្ឃឹម ។

សម្តីសុភាព ទឹកមុខនឹងនរបស់លោកណាហាលីណាក៏ស្ហាធ្វើឲ្យនាង

ហិមណាលិនីជឿយ៉ាងស៊ប់ ទោះជាលោកចេញផុតទៅហើយក្តី ក៏នាងនៅតែនឹកមមៃថា គ្រាន់តែបានជួយសម្តីគ្នាមួយភ្លែតប៉ុណ្ណោះ ហាក់ដូចជាត្រជាក់ចិត្ត ពិតមែនហ្ន៎ ! លោកនេះមានសន្តានចិត្តជាអ្នកស្ងប់ ហើយទោះជាមនុស្សណាមានសន្តានចិត្តឃោរឃៅ ឬជ្រួលច្របល់យ៉ាងណា តែមកជួបប្រស័យនឹងគាត់ ច្បាស់ជាបានស្បើយពេកនោះមិនខានឡើយ ។

នាងហិមណាលិនី ឈរសម្ងំទេសភាពនៅវេលាថ្ងៃអស្តង្គត ដែលមានពណ៌ល្អគួរចេតនា ដែលសង្ខាតាក់តែងឲ្យបេះធ្វើការងាររួចហើយចូលសម្រាកវិញដោយស្ងប់ ។ នៅកាលវេលាដ៏ប្រពៃនេះ រស្មីព្រះអាទិត្យនិងផ្ទៃមហាមេឃដ៏ខៀវស្រស់ ហាក់ដូចជាចទ្វីសព្ទសាធុការពរចំពោះនាងហិមណាលិនី ។

រឿងពីរបេះរកមេស្ហ ដែលគេទើបនឹងនាំមកប្រាប់នាង ជារបួសមួយយ៉ាងឈឺចាប់ ហើយនាងគិតក្នុងចិត្តថា បើសិនជាជីងជាវ៉ាមានគំនិតអាក្រក់បែបនេះហើយ នាងនៅតែមិនទាន់អស់ចិត្តស្តាយទៀតនោះ ជាការថោកទាបពេកណាស់ ។ នាងមិនតាំងចិត្តផ្ទួនទោសដល់អ្នកណាទេ ប៉ុន្តែនាងនឹងបំភ្លេចកុំឲ្យនឹកដល់វាទៀត ។

សេចក្តីអៀនខ្មាស់ សេចក្តីខ្ញើះរអើម ថែមទាំងកណិតកាស្ងូរបន្តិចផងហោយឡីភ្នាធ្វើឲ្យនាងរំជួលចិត្ត លើកដៃទាំងពីរប្រណម្យ ហើយ

ទឹកថា "ឱព្រះជាម្ចាស់លោកអើយ ចុះហេតុអ្វីក៏បេះតែនាំខ្ញុំឲ្យគិតរំពល់ ខ្វល់យ៉ាងនេះ តើខ្ញុំមានកំហុសអ្វី សុំព្រះលោកជួយកុំឲ្យខ្ញុំខ្វល់ ទឹកដល់រឿងនោះទៀតឲ្យសោះ ខ្ញុំគ្មានប្រាថ្នាអ្វីក្រៅអំពីសេចក្ដីសុខឡើយ" ។

លោកតាអាណាជាប្អូនចង់ដឹងថា តើរឿងរ៉ាវទាំងអំបាលម៉ាន ដែលអាក់ស្កាយនាំមកនិយាយប្រាប់នាង តើនាងរកឃើញឬទេ? តែលោកមិនហ៊ានសួរកូនលោកសោះ ព្រោះឃើញទឹកមុខនាងបេះតែព្រងើយ លុះដល់ល្ងាច ទើបគាត់ទឹកនិយាយវិញ :

-តាប៉ុអឺមកព្រឹកមិញ ដូចជាមនុស្សត្រឹមត្រូវដែរណា . . . កូនប៉ុន្តែដល់គាត់និយាយពីកមេស្ហៃបហ្នឹង ពុកដូចជាខ្វល់ . . . ។

-កុំទឹករឿងហ្នឹងទៀត ពុក ។

ពុកចង់មែនទទួលយករឿងរ៉ាវមកគិតធ្វើអ្វីទេ តែព្រហ្មលិខិតបានធ្វើឲ្យសេចក្ដីសប្បាយ និងសេចក្ដីវេទនារបស់យើងទៅជំពាក់លើរូបបុគ្គលណាមួយជាដរាប ហើយបើយើងយល់ថាមិនចង់ដឹងអំពីអាកប្បកិរិយារបស់មនុស្សនោះ ក៏ដូចជាមិនត្រូវដែរ ។

-ទេពុក ! (នាងឆ្លើយជំទាស់) យើងមិនត្រូវយល់ថា សេចក្ដីសប្បាយរបស់យើងត្រូវមានតែដោយសារអ្នកដទៃណាឡើយ ពុកអើយពុកព្រួយចិត្តពីព្រោះតែខ្ញុំបែបនេះ ខ្ញុំខ្មាសគេណាស់ ។

-ខ្ញុំត្រូវដឹងថា ពុកចាស់ហើយ តែកូនមិនទាន់មានផ្ទះសម្បែង

មិនទាន់មានអាណាព្យាបាល ពុកសប្បាយចិត្តម្តេចបាន ពុកស្លាប់ទៅមុខជាទុកកូនឲ្យនៅម្នាក់ឯងហើយ ! កុំពេលដែលកូនមានទុក្ខ កូនមិនយល់ថាការរស់នៅជាការមានប្រយោជន៍ទេ តែកូនបានធ្វើល្អចំពោះពុកច្រើនណាស់ បើដូច្នេះ ត្រូវកូនកុំប្រកែកនឹងសេចក្តីស្នើរបស់ពុកឲ្យសោះ ។

នាងស្តាប់ចប់ហើយ ក៏យកគ្រប់ភ្នែកផ្ទុក់ ៗ ថែបដូចជារកនឹករឿងអ្វីមួយ... បន្តិចមក ទើបនាងសួរទៅឪពុកវិញ :

—ម្តេចក៏ពុកមានប្រសាសន៍អ៊ីចឹង តែពុកបញ្ជាអ្វីដល់ខ្ញុំ ខ្ញុំមិនដែលហ៊ានប្រកែកទេណា ទោះជាយ៉ាងណាក៏ដោយ ខ្ញុំគ្រាន់តែសុំពុកជាឲ្យទុកពេលឲ្យខ្ញុំបំភ្លេចរឿងចាស់ចោលសិន ដើម្បីឲ្យទំនេរឲ្យស្រឡះចិត្តសិន សឹមគិតរឿងថ្មីទៀតតែប៉ុណ្ណោះ ។

លោកតាអាសូរកូនណាស់ លូកដៃទៅអង្អែលក្បាលកូន ដែលមានទឹកភ្នែកហូររហាម ហើយទាញមកថ្នប់នឹងទ្រូងគាត់ ។

(នៅមានត)

# អង្គរជាកាយ - ព្រលឹងខ្មែរ

(កាព្យពាក្យ ៧)

ដោយ លី-ធាមតេង

១ ព្រឹត្តិការណ៍ស្រុកទេសចេះតែហៅ
ឲ្យចិត្តជួបដៅកើតកោឡា
ចាប់តាំងពីទីប្រាំមួយមិថុនា
ឆ្នាំចិតសិបគត់មត់ហ្មួហ្មង ។
មិនគួរពោរខ្ទាំងប៉ូនទឹកដី
ចិត្តអន្យគ្គីយេចូលប៉ុនប៉ង
ទន្ទ្រានរុករានពេញដែនដង
ទីទិសណាផងក៏មានដែរ ។

ស្រណោះអង្គរល្អស័ក្តិសម
ជាគោលឧត្តមវប្បធម៌ខ្មែរ
ចង្កាត់សតវត្សច្រើនហូរហែ
តំណាងឫទ្ធិខ្មែរខ្សែរុងរឿង ។
ចម្លាក់ក្បូរក្បាច់រស់ទន្ទាំ
មានថែបលំនាំសមថ្កុំថ្កើង

ផែនកពសិលាតម្រៀបឡើង
ខ្ញុំជូនតាយើងសាងកេរ្តិ៍ឈ្មោះ ។
រូបថ្លស្អស្រស់រស់វិស័យ
នាគគ្រុឌវេទតៃយក្ខដូចរស់
រូបទេពកញ្ញាឆាយាស្រស់
រកាំក្បាំក្បោះដោះថនា ។
គយគន់វង់ភ័ក្ត្រផង់ញញឹម
ជាចិត្តសង្ឃឹមនៃខេមរ
រាងរៅល្អាសល្អន់ទន់កាយា
ហត្ថារកាំគិរម្យរក្ស ។
ប្រសិនបេះស្តីខ្ញីគត
ស្តាប់ពាក្យអង្វរអ្នកសុំស្ត្រ
ប្រហែលសម្តីស្រីវរលក្ខណ៍
ស្ទពយកក់ទាក់ទន់យ៉ាងណា ។
មើលផ្កាំងចម្បាំងច្បាំងវិកវរ
យក្សទឹងពានរលោតកាប់ផ្ការ
វាយតប់ឡប់ឡកច្បក់សិរសា
ដាក់ថងប្រហារយកជាញជ័យ ។

គន់ហើយគួរគិតពិចារណា
ឃើញថាគំនិតពិតមានន័យ
បង្ហាញទឹកចិត្តខ្មែរខ្លាំងក្រៃ
បញ្ជាក់ទិសស្រ័យឲ្យយើងយល់ ។

ឥឡូវអង្គរវង់គ្រោះថ្នាក់
ខ្មាំងចោរអបលក្ខណ៍ធ្វើអំពល់
ចូលរុកពតត្បាតបលាបល
បំផ្លាញខូចដល់អង្គរហើយ ។

កូនខ្មែរស្រីប្រុសស្រុសចិត្តគ្នា
ចូលច្បាំងការពារពុំកន្ដើយ
ធ្វើតាមតម្រាយដូនតាហើយ
យក្សអើយ! ស្វាអើយ! មកព្រួតគ្នា ។

ម្តេចក៏នៅស្ងៀមជាប់ជញ្ជាំង
ចេញមក! តតាំងកំងយុទ្ធនា
យៀកកុង-យៀកមិញចោរពាលា
យើងបំផ្លាញវាឲ្យអន្តរាយ ។

យើងឈ្នះ ! ឈ្នះពិត ! ចិត្តក៏ឈ្នះ

ដោយសារមានះឥតគិតស្តាយ

ជីវិតជីកខ្មែទាំងឡាយ

អង្គរ ជាកាយ ព្រលឹងខ្មែរ ៗ

(៨ - ៣ - ៣០)

# រឿង វរវង្ស-សូរវង្ស

(បម្លងពីសាស្ត្រស្លឹករឹត)

លោក លី-ធាមតេង ស្រាវជ្រាវ-ពិនិត្យផ្ទៀងផ្ទាត់

---

(ក)

## បទ៖ កាកគតិ

| | | |
|---|---|---|
| មើលគុយពាក់ពិត | ដើមផុលផុះផិត | ល្វើវែងអន្ទាយ |
| ផ្តៅកផ្តៅខ្សែ | ផ្លែផ្កាត្រសាយ | ស្វាស្វាប់ត្រៀកត្រោយ |
| | ប្រដាកក្បួសក្ងួន | ៗ |
| ក្រខុបក្រឡាញ់ | ចំបក់អង្កាញ់ | ពង្រមាក់ប្រាង |
| ស្រម៉ត្រយឹង | កំភ្លឹងសោតហោង | ដើមទំលាយស្នួន |
| | អម្រំប្រែប្រា | ៗ |
| មានទាំងខ្នុរណាំង | ពៅទ្វិតក្រសាំង | អំពិលស្ដីស្វា |
| ទទឹមទេសសោត | កន្ទោតពុទ្រា | រលួសគិការ |
| | អម្រំពួជ្រៃ | ៗ |
| អស់ទាំងព្រឹក្សា | ត្រសាយសាខា | បំពង់លូតលៃ |
| រំយោលផលា | សាខាស្រាស់ក្រៃ | ហាក់ដូចគល់ព្រៃ |
| | នររ័នសួគ៌ា | ៗ |

មានតាំងស្រឡឹក ស្រឡៅដុះកិត ព័ទ្ធព័ទ្ធលើគ្នា
មានតាំងកាកែស បេកទេសក្តាំងផា លន្តៃតាំងច្បារ
ស្វាកែតមហាហាន់ ។

មើលអស់ខ្ទឹងខ្ទុត ដុះដូចគេជ្រុំ សូកីត្រយង់
សាខាយោនយោន មើលមានគន្ធ់ ហិចហើរត្រាច់ត្រង់
ក្រេបយកកេសរ ។

បុស្សនាគនួនស្រី ម្ទិះរួតមាតី ចំប៊ីចម្ប៉ា
រំដួលរំដេញ រៀងរេញសាលា មានតាំងយុថ្កា
តាំងបរសេជាត ។

ផ្កាផងតូចធំ ខ្លះទើបក្រពុំ ខ្លះរីកព្រោងព្រាត
ខ្លះសោតទើបក្តិប ស្រទាប់ស្អាងស្អាត ខ្លះចាស់ដោយខ្នាត
ខ្លះទុំស្រគាល ។

ព្រះមហាបុត្រថ្លៃ រុករនក្នុងព្រៃ ត្រាច់ត្រង់កណ្តាល
ហាក់ពង.បីហា សីហនាថពេញពាល ឯកឯងនុទ្យារ
ចារក្នុហាខ្ទី ។

ព្រះអង្គបោត្រា សក្រុំងម្នា រត់រកប្អូនថ្លៃ
គិតជាយល់អង្គ ស្តេចព្រួយសោកក្រៃ ក៏លាចនោះនៃ
កន្ទនាំព្រៃព្រឹក្ស ។

ស្ដេចយល់ព្រឹក្សា សព្វគ្រប់ហើយណា ស្ដេចទឹកសន្ទឹក
អាឡោះអាល័យ មៃៗញឹកៗ រំរើររលឹក
រកពដទេពី ៗ

## បទព្រហ្មគីតិ

សម្ដេចដំណាលគ្រប់ សរសើរសព្វសត្វបក្សី
គៀងគូទាំងឈ្មោលញី ស្រៀចស្រែកស័ព្ទដោយភាសា ៗ
រុងឆ្មារគ្រុឌឥន្ទ្រីយ៍ កិន្នរីកិន្នរា
ចាកបាទផលីកា តាលិង្គាចក្រក្រពាក ៗ
ករវឹកហង្សទេរសីហ៍ ចាកពតីក្រៀលគ្រាំងក្រាក
ដីវកទូរដីវាគ គោតីលាគទូរទេរសីហ៍ ៗ
គេលឹងហង្សព្រមមេច ក្រាបពះពចត្នាតគូវី
ពូវិកក្អែកទីតី កន្ទត់ខ្មៅកុកក្រោងក្រែង ៗ
កង់កេងកង្កែបកង ក្អែកទឹកផងពាក់កខ្សែង
សារិកាទូរក្រលែង អាចចឹកចាប់ទូរចេកទុំ ៗ
ក្ងរក្ងាខណា ទុងទោមទាក្រសាត្តុំ
មាន់ទឹកប្រវឹកត្រុំ ស្ទឹងកំពូរអាអូតអក ៗ
ចរពៅចាបចន្ទ្រា ក្អាត់កុលដោរឆារគក
កុកសាបទ្នាកុកក្រុក ចង្កៀលខ្វង់ត្រយង ៗ

ច្បានខែលគគាក់គោត ដដៀបណោតចៀបតាមប្រើ
មានទាំងស្ទឹកលោកតាប តទីប្រាបជពបថា ។
ដបលាយសត្វសៀនឃ្មៀន សត្វដើងទៀនក្រួចទទា
អន្ទួយព្រះឥន្ទ្រា សេះលៀវលោតលេងខ្សារខ្សៀវ ។
មុំមៀមទទុយតុក តុមតុលជ្រកជ្រើងប្រជៀវ
តុកគ្រួមាន់ទាមទៀវ ខ្វិតពញាក់ទទាក់ផែះ ។
ខ្វែងខ្លាចទោចផ្ទុឡ សត្វស·កទៀវសេះ
តតុកៗកែះ ខ្វែងស្រាកស្រែកស្ទាំងប្រមង់ ។
ត្បូចៀបស្តេចគោលិត សត្វគគៀវហើរវិលវង់
កង្កក់ខ្មៅយល់យង់ រជៀបហើររង្វៀលសំកាំង ។
ពព្វលទ្វហព្ព ស្តេចបាកគ្វនទោជទ្រាំង
សត្វសំបកទំពាំង ត្បូចៀបទាំងត្រលែងវែក ។
ក្រពើទ្វប្រមា សត្វកកវខ្វែងក្លែងកេទ
មានទាំងសត្វចៀវស្រែក ចៀចកប្បាសហើររេក ។
ឯអស់សត្វបក្សី ទាំងឈ្មោលញីទំទឹមគ្នា
ខ្លះយំជោយកាសា ខ្វែងស្រាកស្រែកស្ទាំងប្រមង់ ។
ខ្លះខ្លាំងហើរឃ្មាតខ្មាញ់ យល់គ្នាដេញផ្ទុកផ្ទោះបង់
ខ្លះពាំនាំគីកកង បុកចំណាចំណង់ភាន ។

ឯអស់សត្វបកី　　រកផលាដោយទីឋាន
សត្វខ្លះហើរដោយដាន　　បានដល់មុខចុះចឹកស៊ី ៗ
ខ្លះទំលើព្រឹក្សា　　ខ្លះរកធៀលទកី
សឹងគ្នាៗឈ្មោលញី　　ស្រែកទ្រូវស័ព្ទក្រាងក្រង ៗ
ខ្លះទំនៅឈើនេះ　　ស្រែកហើយរេះហើរហួសទៅ
ផ្លុកផ្លាះផ្ដោះសំដៅ　　ហើរទៅទំឯទៀតណា ៗ
ស័ព្ទសត្វពិរោះព្រួច　　ព្ទក្រលួចដោយភាសា
ដូចតូរ្យតន្ត្រីណា　　ស្រឡៃផ្លុំប្រគំលេង ៗ
ឯអស់ព្រៃព្រឹក្សា　　រំយោលផ្ការុះរោយឯង
កេសរពិដោរឈ្ងុង　　ឈ្ងួយឈ្ងប់សព្វគ្រប់ទិសា ៗ
ព្រះពោធិសត្វថ្លៃ　　ត្រេចក្នុងព្រៃពន់អង្គា
ស្ដេចយល់អស់បុប្ផា　　នូវសព្វសត្វបក្សីផង ៗ
ស្ដេចរឹងសោកស្រណោះ　　រឹងអាឡោះលើសកន្លង
គិតពីព្រះប្អូនហោង　　ធ្លាប់នៅនិត្យនៃបទឹងគ្នា ៗ
ស្ដេចខ្ញូញៗបណ្ដើរ　　ខ្ញូញរៀបរើសត្វបក្សា
ស្ដេចយល់គៀងគូរ៉ា　　ស្ដេចរឹងគិតព្រះប្អូនថ្លៃ ៗ

## បទកាកគតិ

កូនព្រះព្រៃព្រឹក្ស សឹងសត្វអម្រឹត ដេរដាសគ្រាស់ក្រៃ
ដើរសារស រូបល្អប្រពៃ ឈរឈប់មួប់ជ្រៃ
ស្រឹងស្រេបសោះក្តៅ ៗ
គោកគៀងគោគង់ ព្រនាក់បំពង់ ដោយដិតនិត្យនៅ
ខ្លះបួលចាប់ខ្មោង ខ្លះឈានចាប់ស្នោ ខ្លះចរចេញក្រៅ
លាកបេះពីគ្នា ៗ
ខ្លះចុះប្រេងប្រឹង ស្រែកពេទ៌ទ្រហឹង ចេញចរមហិមា
ដាញដល់ស្រាប់ស្រេច ភព្រេចគ្នាភ ខ្លះចាញ់គេរ
រូតរត់ដោះធ្លាយ ៗ
រមាសរមាំង ឆ្កៃព្រៃខ្លះខ្លាំង ទន្សោងទន្សាយ
ចចកស្វានស្វា ប្រមាំឈ្លូលព្រាយ ឈ្លូសប្រេងឈ្លូសលាយ
ខ្លាត្រីដំបង ៗ
ប្រភងតាំងផ្ដុំ ខ្លារខិនខ្លាឃ្មុំ ជ្រូកខ្ជិងជាសជង
លាញីជជ្រូក ត្រកួតអន្សង ពង្រូលទូវគ្រង
កំប្រុកកន្ធែន ៗ
សម្ពោចឆ្មាចា បង្កួយជាសស្កា ឆ្មាព្រៃថ្កុកថ្មែន
ពស់ពិសយន់ឃ្នង គ្រសងពាក់ពេន ភភររដេន
ផ្ទុររលូកលេង ៗ

ប្រើសព្រាយពស់ព្រៃ ក្របីក្រាស់ក្រៃ រលាស់លង់ស្នែង
ខ្ទះឡើងកវល់ ផាញផល់ឥតក្រែង ខ្ទះរកត្រាំក្រែង
គៀងគ្នាកាល់ញី ។

កែសកាញដឹក ទុសអូជ្ឈលៀងកា គជសិង្ហគជសីហ៍
ពពែស្មានស្មៀម គោចៀមតាមរី កែសភជសីហ៍
គោមៀងកែការ ។

អាតិលវ័ន គុជត្មាយជីស្ពាន់ ហំរលេខបាម៉
អភិមន្ទរ័ក រអិកអម្រឹគា សឹងជួបជុំគ្នា
គជសិង្គគជសិហ៍ ។

សាំងមាំងតុលា ភិមខ្សែរតា មត្តកាសី
មិគ្គកវិក មាំងសាំងភជសីហ៍ ជតាយុកជត្ថ
ដំណាដីក្លាយ ។

សោហាំគរី សត្វសិង្ហនរសីហ៍ មាំងតាមសិរសាយ
អ្នកសឹងសត្វស្លូរ គ្គុហ្វួងហ្វាយ ពិតពុំធីលាយ
ដើរដោយគ្នាប ។

សត្វសិង្ហប្រើនពណ៌ ក្រដឹងក្រស្គាល់ លំនាំនោះណា
គម្ប្រាលនៅក្នុង កំឡុងព្រឹក្សា ក្រគិតគណនា
ក្រស្គាល់សត្វសាយ ។

ខ្លះដេកខ្លះដើរ ខ្លះមឹតខ្លះមើល ខ្លះរត់ខ្លះពយ
ខ្លះឈប់ខ្លះឈរ ងើយងនាយអាយ ស្រើបស្រួលសប្បាយ
ដោយផ្សេងទីទៃ ។

ព្រះពោធិសត្វ ពន្លកបរមត្ថ រកពនក្នុងព្រៃ
ពើបពះសត្វផង ច្រើនហោងក្រាស់ក្រៃ ស្តែងស្តេចនិរភ័យ
ពិតពុំភ្លេចឆាយ ។

សង្វាតដើរកាត់ ត្រេចរកបូទរ័ត្ន ជាអម្ពុងឆ្ងាយ
ប្រាំពីរខែស្ងាត់ អស់អ្នកទាំងឡាយ ប្រាំពីរថ្ងៃថ្វាយ
សេះសង់ផងណា ។

សម្តេចជៀសជ័យ ត្រេចក្នុងព្រះព្រៃ លង់លេចអគ្គា
ទៀងមើលស្តេចផុង ត្រើយត្រាណមាតា ឆ្ពោះទៅទិសា
គន្ធពបុរី ។

បម្រាយមាតា បាសិបះយាជនា កំណត់ប្រក្រតី
ស្តេចតើនពីព្រឹក រុងរៀងរស្មី រសៀលនាទី
ដួចដល់ព្រះនគរ ។

ស្តេចដើរទាំងទុក្ខ ពិតពុំស្រណុក ឯកអង្គពេញរ
ស្តេចព្វគេថា ស្តេចនាព្រះនគរ មួយនោះស្មោះសរ
ប្រទះព្រះសន្ធា ។

ធ្វើបុណ្យឲ្យមាន ឲ្យសង់ជាស្ពាន បរមសាលា
ឲ្យគូរគំនូរ ក្បាច់ក្បូររចនា និយាយក្សត្រា
ព្រាត់ប្អូននិងបង ៗ

ស្ដេចព្រះព្រហ្មណា ស្ដេចគិតឯងថា គួរអញទៅលង
មៀងមើលគំនូរ ក្បាច់ក្បូរនោះហោង អញយកមានផង
បំពេញកុសល ៗ

សម្ដេចក្សត្រា ពន្ធុកព្ទា ត្រើយត្រាណមង្គល
ព្រះអង្គគិតស្រេច ស្ដែងស្ដេចដើរដល់ សាលាមណ្ឌល
ឈរឈប់រេក ៗ

កាលនោះអ្នកនាំ អម្បាលនាចាំ បរមសាលា
មៀងមើលមុខប្រាណ យល់មានរូបា អរឯងមហិមា
អញ្ជើញស្ដេចទៅ ៗ

ឲ្យអស់ប្រជាប់ អាហារស្រេចស្រាប់ ឲ្យប្រេងមេប្រៅ
ឲ្យអស់ប្រជាប់ បម្រាប់និត្យនៅ សំពត់នូវអាវ
ថ្វាត់ថ្វាយក្សត្រា ៗ

ហើយឲ្យនាំមើល និយាយដំណើរ ព្រះធម្មាតីតា
ពីកាលកើតស្ថិត និត្យនឹងមាតា ទេវនាយណា
ស្ដេចសុខសប្បាយ ៗ

ព្រះពោធិសត្វ　មៀងមើលរបរ័ត្ន　ឆ្វេងយល់សព្វសាយ
ដោយព្រះប្រាជ្ញា　ថ្លៃថ្លាប្រះប្រាយ　ដឹងដើមនិយាយ
ដំណើរព្រះអង្គ　។

ស្តេចទប់ពុំបាន　ជួលជេកប្រះប្រាណ　គរគក់ទ្រូងទ្រង់
ព្រះកន្សែងសព្វ　សន្ទប់លុះលង់　ហើយភ្ញាក់ឡើងគង់
ទៀងទួញទូលថា　។

ឱតំរូវនេះ　សោះសារដូចម៉េះ　អស់អង្គរូបា
រូបមួយហាក់ដូច　ព្រះវរមាតា　គគង់ស្ថិតនា
មន្ទីររ័តនហោង　។

រូបតីរនេះណា　ហាក់ដូចអាត្មា　យើងប្អូនទិនបង
បណ្ដើរតាទៅ　លេងនៅពេញទង　ដូចកាលសព្វថង
ពីមុននោះហោង　។

ឱរូបមារយាទ　មួយនោះសោតស្អាត　ដូចនាងមន្ទា
គាត់លួងយើងទៅ　លំនៅអាត្មា　ហើយគាត់មោហា
កុបកេកាចកល　។

រូបមួយនេះណា　ហាក់ព្រះបិតា　ក្រេវក្រោធណាល់
ឲ្យពេជ្ឈឃាដ　ប្រហែចសោតសល់　នាំយើងដូចដល់
ព្រះព្រៃព្រឹក្សា　។

ប៉ុនប៉ងសម្លាប់ គេជះជីងធាប់ ដល់ព្រះមាតា
អ្នករត់សង្វាត ខ្ញុំឃ្លាតយាត្រា ទាន់យើងហើយណា
ឱបអង្គស្រដី ៗ

រូបមួយសោកសព្វ កាលអ្នកសន្ធប់ ភ្លេចភ្លាំងស្មារតី
យើងប្អូនទិនបង ផ្សងនូវបារមី ទើបរស់ជីវី
អង្គព្រះមាតា ៗ

រូបមួយសោកសោធ ហាក់រូបគេឲ្យឃាត នោះឯងហោងណា
ក្រាបថ្វាយបង្គំ ប្រណម្យវន្ទា ប្រើយើងយាត្រា
រួតរត់ចេញហោង ៗ

រូបពីរនោះណា ហាក់យើងយាត្រា តែប្អូនទិនបង
បណ្តើរគ្នាមក ដោយប្រកដ្រលង ដល់ស្រុកមួយហោង
បស្ចិមទិសា ៗ

ពីរពង្សគ្រូអាល ចរចូលក្នុងផ្សារ ស្រុកនោះឯងណា
ហើយដើររំលង ដោយដងខាគា ចូលក្នុងព្រឹក្សា
ស្ងប់ស្ងាត់ជ្រងំ ៗ

នូរូបនេះណា ហាក់យើងយាត្រា ដល់ដើមជ្រៃធំ
គ្រងាក់សប្បាយ គ្រសរយគ្រសុំ ស្រងាត់ខ្ទមរម
ជួបចូលសន្និយា ៗ

| | | |
|---|---|---|
| យើងឈប់សម្រាន្ត | ឡើងដេកទាហាន | មែកមួយសាខា |
| មានមាន់សខ្មៅ | និត្យនៅនោះណា | ប្រដល់គ្នាព |
| | សឹងស្តាប់ចាំងពីរ | ៗ |
| យើងយកខ្មោចមាន់ | នោះមកចម្អិន | ស៊ីហើយចេញចីរ |
| ប្រុទះសឹងសត្វ | ច្រើនក្ដាត់ជាសំដេរ | យល់យើងទាំងពីរ |
| | ពិតពុំហ៊ានក្រ | ៗ |
| ទុរូបពីរនេះ | ហាក់យើងឈប់ស្ទេះ | និត្យនៅសាលា |
| ដេកចាំងពីរទាក់ | ពុំភ្ញាក់និទ្រា | ព្រាត់ប្រាសពីគ្នា |
| | កាលណោះឯងហោង | ៗ |
| ទុអ្នកឯណា | មែនមានប្រាជ្ញា | ដឹងអស់គាថផង |
| អាចចាំនិយាយ | តាមដោយគន្លង | គួរដោយចំនង |
| | ដំណើរយើងណា | ៗ |
| កាលណោះអ្នកនាំ | អម្បាលនាចាំ | បរមសាលា |
| ស្ដេចស្ដាប់ចំនួញ | ទៀនទូញសោកា | អរឯងមហិមា |
| | ទៅទូលក្សត្រថៃ | ៗ |
| បពិត្រក្រាបទូល | ព្រះអង្គឥស្សូរ | ក្សត្រាជេដ្ឋជ័យ |
| ឥឡូវយល់ជា | ប្ញែកនាសត្វថៃ | មិនអ្នកដទៃ |
| | សមព្រះអនុជា | ៗ |

កាលទើបមកដល់ ទើបទេពមណ្ឌល ឈរឈប់រេរា
សាលាទ្រង់ត្រាយ ពោមពាយសោភា ហាក់ដូចរាជា
ពិតពុំទេឡើយ ៗ
យល់ដូច្នោះណា យើងខ្ញុំអស់គ្នា អញ្ជើញមកហើយ
ថ្វាយអស់ប្រដាប់ សម្រាប់ជាត្រើយ ទទួលស្រេចហើយ
ទើបបរិភោគ្គា ៗ
បរិភោគស្រេចហើយ ពិតពុំលង់ឡើយ យើងខ្ញុំអស់គ្នា
ឲ្យមើលគំនូរ ក្បាច់ក្បូរអតីតា មើលហើយសោភា
ប្រះប្រាយស្ងប់ស្ងល់ ៗ
ព្រះវៀមកជា ស្ដាប់ពាក្យសេនា ទូលថ្លែងអស់កល
ទើបស្ដេចលេលា យាត្រាទៅដល់ ស្ពែងស្ដេចយន់យល់
ព្រះអនុជថ្លៃថ្លា ៗ
ស្ដេចអរទុនទុប ថ្នាក់ថ្នមក្រសោប ដួញដិតអង្គា
ទ្រង់ព្រះកន្សែង ថ្មឹងថ្លែងខ្ញួញថា ខ្អូនពុំងា
កម្សត់បងអើយ ៗ
ខ្អូនស្នេហ៍ស្នង អ្នកប្រាសទីដបង ប្រាំពីរឆ្នាំហើយ
បងគិតសព្វថ្ងៃ មៃៗឥតស្បើយ ឥតឯល្ហែល្ហើយ
ដល់តិចឡើយណា ៗ

ទមាសព្រលឹង    បងតែងទន្ទឹង    សព្វទិនទិវា
ហេតុផលសំណាង    បងស្អាងសាលា    ទើបបានយល់គ្នា
ឥឡូវនេះម្តង    ៗ
ឯព្រះអនុជា    សឹងសោយសោកា    ទៀងទូញទូលស្នង
ប្រាប់ពីគោកយ៉ាក    លំបាកក្តាក់ហោង    ច្រើនគ្រាច្រើនដង
ឥតឯល្ហែល្ហើយ    ៗ
ព្រះវៀមជេដ្ឋា    នូវព្រះអនុជា    ទៀងទូលឆ្លាស់ឆ្លើយ
កិលាបក្តាត់ហោង    បន្ទោរហោកស្បើយ    ជូតជលនេត្រហើយ
សំណេះបរោ    ៗ
ព្រះអនុជទៀងទូល    បពិត្រឥស្សូរ    ខ្ញនខ្ញុំនេះណា
លំបាកកន្លង    ច្រើនដងច្រើនគ្រា    ណាស់ទឹងបានជា
មនុស្សជួបេះនៃ    ៗ
បពិត្រដំណើរ    ព្រះទម្រង់ប្រសើរ    មែនមានតម្លៃ
គេចាប់ជាហោរ    គេធ្វើទុក្ខភ័យ    គិតជាទីងក្សយ
កាលណោះឯងណា    ៗ
សព្វគ្រប់ទូញទៀង    ប្រាប់ពីរឿង ៗ    តទីងយក្យា
ប្រាប់ពីទេពី    ក្សត្រីថ្លៃថ្លា    ទាំងពីរអង្គារ
អាឃិអគ្គមហេសី    ៗ

ប្រាប់ពីអាត្មា បានសោយរាជា គ្រប់គ្រងបុរី
ប្រាកដជាក់ជា ក្សត្រាធិបតី ប្រាប់ទៀតមកខ្ញី
បានហោះយាត្រា ។

ប្រាប់ពីតាបស ឥតធម៌សប្បុរស លបលួចកែវជា
ប្រាប់ពីទំនង ហែលជូនគង្គា ព្រាត់ប្រាសភរិយា
ពុំយល់ឡើយហោង ។

ប្រាប់ពីកាលព្រាត់ ប្រទះនឹងសត្វ សាហាវទ្រើស្តយ្មង
ប្រាប់ពីរុករាន ដោះដានព្រៃផង លំបាកក្តាត់ហោង
ថ្ងៃងជួនពុំបាន ។

បពិត្រព្រះបាទ ព្រះរៀមនរនាថ ឥស្សរត្រើយត្រាណ
នាំខ្ញុំកូនអើយ យាត្រាចាកស្ថាន ប៉ននឹងទៅឋាន
ព្រះវរមាតា ។

ខ្ញុំលាក់អ្វីហោង គិតថាអ្នកបង ក្ស័យព្រះជន្មា
ម្ល៉េះគេតាមចាប់ សម្លាប់ហើយណា មិនដឹងបានជា
ស្តែងស្តេចដូចប៉ុន ។

ខ្ញុំមកមានភ័ព្វ រស់រួចពីស្លាប់ បានយល់អ្នកបង
រួចរស់ជីវិត ដូចចិត្តប៉ុនប៉ង បរិបូណ៌ទេះម្តង
ដល់ដូចប្រាថ្នា ។

ខ្ញុំជប់តែកល ត្បិតខ្ញុំពុំយល់ ប្រពន្ធខ្ញុំណា
ត្រូវមាបឯកឯង វង្វេងមាគ៌ា ខ្លាចក្ស័យជន្មា
សូន្យសោះក្នុងព្រៃ ៗ
នាងក្រេងគតិផង បរិទេវហើយហោង ទើបប្រាសទីទៃ
ឥឡូវគម្រប់ ខែដប់ហើយនៃ ហើយឃ្លាយតាំងថ្ងៃ
ប្រាំពីរផងណា ៗ
ព្រះរៀមស្ដេចស្ដាប់ ព្រះអនុជប្រុងប្រាប់ ស្ដេចឆ្លើយវិញថា
ប្អូនអើយចង់រើស កូនគេមួយណា ពោលទូវថ្លៃថ្លា
នោះបោះបង្កៀត ៗ
ប្រាប់ឪនសំពត់ ខៀវទើបតាំងផ្ចិត សសាប់សត្វសៀត
បំពៀនបវិត ក្រូចបរមៀត មិនស្អកកន្ទៀត
នោះសមកូនបា ៗ
បងរើសពិកាល ទើបឧង់សម្ងាល ប្រាំពីរទិស
មើលយល់ស្គាល់ បន្ទាល់នោះណា បំពៀនត្បូងជា
ទ្រព្យប្អូនឯងហោង ៗ
បង់ឲ្យកញ្ញា រកសត្វទិសា រុករកសួរហោង
សត្វស្រុកគូបធំ និទ័យាវាងផង ពុំយល់ឡើយហោង
បងលានសាលា ៗ

ហើយបន៍ឲ្យបរ អស់ទាំងនគរ ឲ្យយកតានណា
ឲ្យមើលនិយាយ អំពីដូចគ្រា កាលយើងប្រាសគ្នា
ដំណើរនោះហោង ។

ហេតុបុណ្យយើងឯង អំពើពីព្រេង ជាមុនមកហោង
ឥឡូវនេះណា ប្រាថ្នាប៉ុនប៉ង បានដូចបំណង
ពិតពុំឃ្លាតឃ្លា ។

ព្រះអនុជនរនាថ បង្គំក្រាបបាទ ហើយទៀងទូញថា
បពិត្រព្រះអង្គ ទ្រើសទ្រង់ករុណា កូននោះនៅឯណា
ខ្ញុំសួរចង់យល់ ។

ព្រះរៀមរកជា ត្រាស់ប្រើសេនា ស្រេកខ្វាយខ្វល់
នានាំពងបុត្រ . បរិសុទ្ធនិមល ថ្នាក់ថ្នមមកដល់
ថ្វាត់ថ្វាយក្សត្រា ។

ព្រះពៅរវង្ស យល់ព្រះទម្រង់ ទឹងកូននោះណា
ស្តេចថ្នមត្រសោប ទទឧបអង្គា កិហបសោកា
ថ្ងូនថ្ងឹងពុំបាន ។

ស្តេចទៀងទូញថា ក្មូងពុំងា អាសមិត្តកល្យាណ
ខ្ញុំពុំឃើញអ្នក ជៀងជាក់ងាស្ពាន អានេះហៅមាន
បុណ្យបរិបូណ៌ក្រៃ ។

| | | |
|---|---|---|
| ឱកូនសង្សារ | ម្តេចមកសម្រាល | ដោយផ្លូវដោយព្រៃ |
| ព្រះបិតុច្ឆា | បើសបាមាសមៃ | អគ្គីបាក្ស័យ |
| | នៅខានផ្លូវផ្កា | ៗ |
| ឱមាសមហាថ្លៃ | ម្តាយបាសោកនៃ | ពុំឃើញឡើយណា |
| ក៏ឃើញតែពៅ | គេងនៅកំព្រា | កណ្តាលផ្លូវផ្កា |
| | ត្រមោចឯកអង្គ | ៗ |
| ឱមាសថ្លើមថ្លៃ | ក្រែងម្តាយបាក្ស័យ | ជីវិតបាត់បង់ |
| ឬក្រែងតែបរ | ចេញចរត្រាច់ត្រង់ | ប្រទះយក្សយង់ |
| | ចោមចាប់យកទៅ | ៗ |
| ស្តេចទូញកិលាប | សព្ទគប់ផកប | ខ្សឹកខ្សួលក្តាត់ក្តៅ |
| បំរះនេទៀល | មទៀលនិត្យនៅ | សន្ទប់ស្ទូន្យទៅ |
| | ពុំក្សាក់អាត្មា | ៗ |
| ព្រះបាទសូរវង្ស | កាំនិះសោយៈហាកទ្រង់ | កន្ទ្បែងសោកា |
| កិលេបសោកសល់ | យន់យល់អនុជា | សន្ទប់ញាះណា |
| | ស្តេចកិតក្ត៉ះហាង | ៗ |
| ក្សិណក្សត្រមុឱ្មា | យកព្រះគន្ធា | វិចិត្រក្បៀងរង |
| ត្បឹតព្រះកគ្រា | សំរសារោះផង | ក្សិណក្សាក់ឡើងហោង |
| | កិលាបឥតបិ | ៗ |

# បទភុជង្គលីលា

ទីនថ្លែងសម្តែងស្រដី នាងកែសកេសី បម្រើជូនតាស់ ។
តោកយ៉ាកលំបាកក្រៃក្រាស់ គាត់ដេរពោលណាស់ រំលើកបណ្តេញ ។
នាងនាថធ្វើការអស់អញ បម្រើលំគេញ ឲ្យសោះគាត់ដេរ ។
ថ្ងៃមួយពុំព្រួយទំនេរ ពិតពុំបានល្ហែ ដល់តិចឡើយណា ។
លុះគ្រប់គំរប់ទិវា ប្រាំពីរហើយណា មានលាជូននោះ ។
នាងដើរដំណើរទៅស្ទោះ ប៉ុនប៉ងចំពោះ រកកូនពុំឃា ។
ដើរដល់មណ្ឌលសាលា សម្តេចក្សត្រា មៀងមើលយង់យល់ ។
ក្សត្រថ្លៃប្រពៃសួស្ត៍សល់ រួសរត់មកដល់ ព្រះប្អូនស្នេហា ។
ឧបអង្គួញទ្រង់សោកា នៅមុខសាលា កិលាបឥតបី ។
ថ្លែងសោកអមោកអស់ក្តី ថ្លែងប្រាប់អំពី ហែលក្នុងសមុទ្រ ។
ភិតភ័យហឫទ័យរន្ធត់ ហត្ថហៀបផុតៗ ស្ទើរដាច់ខ្យល់ណា ។
ក្សត្រីប្រាប់ពីគាលគ្រា គ្រាច់ព្រៃព្រឹក្សា វង្វេងវិលវល់ ។
ដំណាលប្រាប់គាលដើរដល់ តាចាស់យង់យល់ នាំនាងយាត្រា ។
ប្រាប់គាលសម្រាលបុត្រា ភិតភ័យមហិមា កិលាបថ្ងូញទៀង ។
នាងប្រាប់រៀបកប់រឿងៗ ពិតពុំឲ្យល្អៀង ព្រះរៀមកជា ។
ឯកអង្គពីរពង្សក្សត្រា ប្រាប់ដោយអាត្មា ទល់ទុក្ខពីថ្ងៃ ។

ថ្ងៃនេះសោកអាមោកក្រាស់ក្រៃ ថ្ងៃគិតថ្ងៃភ័យ ប្រាប់ឥតខ្វះឡើយ ។
ក្សត្រីប្រពៃត្រាណត្រើយ បន្ទោរសោកស្បើយ ស្រេចស្តេចយាត្រា ។
មកគង់កំឡុងសាលា ព្រះវៀមពជា រួមក្សេមត្រី ។
ស្តេចប្រាប់រៀមពប់ស្រដី ដំណើរអំពី រើសកូនពុំឆា ។
នាងស្តាប់ស្តេចប្រាប់ហ្នេះណា យង់យល់ពជា ត្បិតនាងឯងហោង ។
នាងឧបក្រសោចត្រកង ខ្សឹកខ្សួលយំផង ទឹងបុត្រពុំឆា ។
នាងទ្ងួញទំនួញថប់ថា កូនអើយបុណ្យបា លើសក្រៃកន្ទង ។
បាកើតកំណើតនេះម្តង ហៅបាបានសង គុណយើងហោងណា ។
បទបុណ្យបាលន់កាលគ្រា នេះទើបព្រះមហា រើសបាមហាថ្ងៃ ។
ស្តេចស្គាល់បន្ទាល់នោះនៃ ទ្រព្យធនប្រពៃ ពីឪពុកបា ។
ទើបស្តេចសម្រេចសទ្ធា ប្រដាប់សាលា តាំងនៅនោះផង ។
យើងគិតគំនិតប៉ុនប៉ង ហាក់យកទានហោង បំពេញសទ្ធា ។
ទើបមូលជួបបូលទឹងបា ហេតុនោះម្តាយថា បាបានសងគុណ ។
បាឯងពីព្រេងជាតិមុន បាបានធ្វើបុណ្យ ប្រាថ្នាដឹងអើយ ។
មាសថ្ងៃប្រពៃម្តាយអើយ បាឯងជាត្រើយ ពំនាក់ម្តាយហោង ។
ហើយម្តាយរក្សាឥតហ្មង អរក្រៃកន្ទង ត្បិតម្តាយឃើញបា ។
ម្តាយមត់កំណត់ទិវ៉ា ប្រាំពីរហើយណា ម្តាយដើរមកផ្ទោះ ។
ម្តាយគិតក្នុងចិត្តម្តាយស្មោះ ស្មានជាដូចនោះ គាត់យកបាទៅ ។

ត្បិតថាសូមបាជាចៅ  មិនដឹងទុកទៅ  នាខាងផ្លូវថ្លា ។
ឃើញឯត្នោតគេបាំងបា  នោះសមទេវតា  និមិត្តដឹងអើយ ។
នាងទួញទំនួញស្រេចហើយ  បន្ទោរសោកសៀយ  ស្រាន្តស្រាលឧក ។
ព្រះអង្គពីរពង្សក្សត្រា  នូវនាងជាយា  ប្រសើរមង្គល ។
នាំគ្នាលីលាដួចដល់  មន្ទីរមណ្ឌល  វែនទិព្វសុវណ្ណ ។
ព្រះអង្គសូរវង្សរាជា  នាងសរបុប្ផា  អាយិអគ្គមហេសី ។
ស្និទ្ធស្នាលត្រកាលស្រដី  រួមរ័ក្សមេត្រី  សំណេះចរចា ។
ស្តេចត្រាស់ប្រើអស់សេនា  ប្រជាប់ប្រជា  សព្វគ្រប់ទីទៃ ។
ស្រាប់ស្រេចស្នែងស្តេចចងដៃ  ព្រះអនុជថ្វាថ្លៃ  នូវបុត្រពុំងា ។
បុត្រនោះស្តេចឲ្យនាមា  ឈ្មោះហៅចៅមហា  វរវង្សសុរិយា ។
រសអង្គកជវង្សស្នេហ៍ណា  នូវពស្ត្រប្រជា  ដេរជាសរាស់រ ។
ប្រណម្យបង្គំកាយករ  សឹងមានអំណរ  ទីទៃគ្រប់ប្រាណ ។
ឥតទុក្ខជាសុខក្សេមក្សាន្ត  ភរហាក់ដូចបាន  ទាន់ព្រះភគវ ។
បានស្តាប់ស័ព្ទធម៌ទេសនា  អរឯងមហិមា  គ្រប់សព្វទីទៃ ។

## បទកាកគតិ

រីកាលណោះណា  ព្រះរៀមកជា  បន្ទូលថាហៃ
ប្អូនអើយបងបាន  កែវធ្យានប្រពៃ  កែវនេះម្តេចនៃ
បងចងដៃបា ។

កៅមួយបង់ប៉ាន រើសមុខព្រះលាន រស្មីថ្ងៃថ្ងា
រីកៅនោះឯង ខ្លាចក្រែងកៅបា បង់ឲ្យគេក្បា
ទុកនៅនេះហោង ៗ

ពោធិសត្វស្តាប់ ព្រះរៀមប្រាយប្រាប់ ស្តេចអរកន្ទង
បន្ទូលឆ្លើយថ្កាន សូមតាទុកបង់ ឲ្យយកមកហោង
ឥឡូវនេះណា ៗ

ព្រះរៀមនរនាថ ត្រាស់ប្រើអមាត្យ ទៅយកកៅជា
មកថ្វាយព្រះអង្គ ររន្ទ្រថ្ងៃថ្ងា ស្តេចមើលហើយថា
នេះកៅខ្ញុំហើយ ៗ

បពិត្រត្រៃថ្ងៃ ព្រះរៀមជៀសជ័យ ឥស្សរត្រាណត្រើយ
រីកៅនេះនៃ ថ្ងៃឥតជួមឡើយ កៅខ្ញុំឯងហើយ
ខ្ញុំទឹងហោះថ្វាយ ៗ

ស្តេចកាន់កៅនោះ គ្រវីហៀរហោះ ទល់អាកាសនាយ
កណ្តាលនភ័ ស្មើព្រានព្រាយ អស់ក្សត្រទាំងឡាយ
មើលហើយស្ញប់ស្ញែង ៗ

ហើយទើបស្តេចហោះ វិលវៃផ្លេកផ្លោះ ធៀលជុំកំពែង
កំពូលប្រាសាទ សីហនាទថ្កល់ថ្កើង ព្រះរៀមស្តេចស្តែង
គោរពព្រះបារមី ៗ

| | | |
|---|---|---|
| ស្តេចហោះចុះចាន | ប្រាសាទត្រឹះស្ពាន | លំនៅវាំងខ្ញុំ |
| ព្រះវៀមកជា | ក្សត្រាធិបតី | ស្តេចវៃងបេតី |
| | រួមរក្សស្នេហា | ៗ |
| ព្រះអនុជនរនាថ | ក្រាបក្រោមព្រះបាទ | ព្រះវៀមកជា |
| ទូលថាបពិត្រ | ឥឡូវនេះណា | សមព្រះមាតា |
| | អ្នកតែងទន្ទឹង | ៗ |
| អ្នកផ្ដែផ្ដាំបុត្រ | តែជប់ឆ្នាំគត់ | ប្រើយើងវិលវឹង |
| ទៅដោយគំនិត | ខ្ញុំគិតរំពឹង | ប្រាំពីរឆ្នាំទឹង |
| | ឆ្នាំថ្មីនេះណា | ៗ |
| ឥឡូវនេះម្តង | បពិត្រអ្នកបង | គួរយើងយាត្រា |
| ដូចបណ្តាំម្តាយ | ចាំដោយអាត្មា | អាសូរមាតា |
| | អ្នកតែងទល់ទុក្ខ | ៗ |
| បើព្រមហើយណា | ខ្ញុំនឹងក្រាបលា | វិលវឹងទៅស្រុក |
| យកអស់សេនា | ហោធាមាត្យមុខ- | មន្ត្រីពីស្រុក |
| | ជុំនៅនេះណា | ៗ |
| យើងគិតឲ្យឆាប់ | គាត់តែងប្រដាប់ | សំពៅកេត្រា |
| យើងគិតឲ្យឆាប់ | ប្រដាប់ប្រដា | រើសរកអាសា |
| | ខ្ទះខ្ទាំងកន្ទង | ៗ |

ព្រះរៀមកថា បន្ទូលត្រាស់ថា ពាក្យពិតឥតគួន
ប្អូនអើយគំនិត ប្អូនគិតតាមហោង បើច្នោះជាបង
ប្រដាប់ទ័ពដើរ ។

បើទៅទទេ ឥតការសមគេ ដឹងជាក់ជាយើង
គេស្គាល់មុខក្រោយ មិនឲ្យយើងឡើង វិលមកបបើង
ពុំបានដូចប៉ង ។

ព្រះអនុជឆ្លាស់ឆ្លើយ ថាបើច្នោះហើយ ខ្ញុំនឹងលាផង
នាងកែសកេសី ប្អូនស្រីអ្នកបង ផ្ញើនៅនេះហោង
នឹងកូនពុំផា ។

បពិត្រអ្នកបង តោះនាងផ្គាំផ្គង សូមមានករុណា
ណែនាំប្រដៅ បុត្រនៅកំព្រា តោះថ្លៃតោះជា
មើលនាងផងហោង ។

ព្រះពោធិសត្វ បង្គំប្រណិប័តន៍ ក្រញាក្រាបបាទបង
ផ្ដាំបវរ លីកូណាឥតហ្មង ចុះទៅឋានផង
កជាទេពី ។

ស្ដេចផ្ដាំនាងនាថ ហៃប្អូនសង្ហារ ប្រសើរស្រស់ស្រី
បងលាប្អូនទៅ ទីនេះទៅទីទៃ នគរបុរី
យើងនាយហោងណា ។

ហៃប្អូនស្នេហ៍ស្និទ្ធ　ម៉្លេះសមប្អូនស្ងាត់　ឯកអង្គអាត្មា
ពីកាលព្រាត់ប្រាស　នឹកសកាលគ្រា　នោះមិញបងមហា
សោកសល់អន្ទោល　ៗ

ឥឡូវនេះណា　បងនឹងឃ្លាតឃ្លា　បងប្អូនពុំយល់
កុំមេប្អូនសោក　អមោក្ខទុក្ខល់　ហឫទ័យសល់វល់
សព្វថ្ងៃឡើយហោង　ៗ

ប្អូនអើយបងទៅ　បងយកប្អូនទៅ　មូលមិត្តនឹងបង
ខ្លាចតែព្រាត់ប្រាស　នឹកសឯងហោង　ត្បិតបងហោះផ្សង
រួតចង់ឲ្យដាច់　ៗ

បងទៅនេះណា　នឹងអាលយាត្រា　វិលវិញក្រឡាប់
ហើយតែងគេគ្រា　ប្រដាប្រដាប់　សំរៀបសម្រាប់
ទៅជាន់មាគ៌ា　ៗ

ហៃប្អូនប្រសើរ　បូរមេមាសមើប　កជបុត្រពុំឆា
កុំមាសឧត្តម　ផ្ការម្ភបងណា　បងទៅយាត្រា
វិលវិញមកខ្ញុំ　ៗ

ចាំបើបងមក　ហើយសមបងបក　នាងរតន៍រតី
នូវអស់សេនា　យោធាមន្ត្រី　នូវអស់ពាំងស្រី
គាំស្និទ្ធស្នេហា　ៗ

កាលណោះមហាក្សត្រ ផ្ទៃផ្កាប្អូនរ័ត្ន ស្រេចត្រាប់ហើយណា
ហើយទើបព្រះអង្គ ស្តេចទ្រង់កែវផា ហិចហោះយាត្រា
ត្រាច់ត្រង់ព្រះនគរ ។

កម្លាំងត្រអាល ហោះឥតស្រយាល ពិតពុំឈប់ឈរ
ដូចកជហង្ស ឯកអង្គបវរ ហិចហើរចេញចរ
ហាកពីហេមពាន្ត ។

ស្តេចហោះមួយថ្ងៃ ផ្ទុកផ្ទោះប្រៀបប្រែ ស៊ីហនាថថ្កើងថ្កាន
បរិបូណ៌បានដល់ មណ្ឌលកេរ្យក្សាន្ត ប្រាសាទពិមាន
បរមពជសម្បត្តិ ។

ស្តេចចរចូលថ្កាន ព្រះប្អូនកល្យាណ សង្វាស្នេហ៍ស្និទ្ធ
នាងគន់តើ ក្សត្រីបមក្សត្រ នាងសោតប្រណិបតន៍
រមសេមេត្រី ។

សម្តេចក្សត្រា ឧបគង្គជាយា ថ្នាក់ថ្នមបេតី
បន្ទូលប្រុយប្រាប់ ស្រៀវកប់អ៊ីពី ងាងកែសរសី
ព្រាត់ប្រាសកាលគ្រា ។

នាងគេនតី ងារស្តាប់ស្វាមី ប្រាប់ដូច្នោះណា
នាងនាថទន់គិត គាណិតគន្ធា នាងសោយសោកា
ពិលេះបក្តាតិក្តៅ ។

ស្រេចហើយព្រះអង្គ ព្រះបាទវរវង្ស នូវព្រះប្អូនពៅ
ប្រដាប់អាត្មា លីលាឡើងទៅ ប្រយោជន៍គាល់ហ្មៅ
ព្រះវរបិតា ៗ

ស្ដេចថ្វាយបង្គំ ក្រញ្ញក្រាបប្រណម្យ សម្ដេចពកជា
ព្រះបាទសោទត្ត អរក្ដាត់ត្រាស់ថា កូនអើយអរបា
មកដល់នេះនៃ ៗ

ពីបាទៅបាត់ កូនអើយយើងស្មាត់ ត្រមោចពេកក្រៃ
យើងគិតពីបា យើងមហាអាល័យ ទន្ទឹងសព្វថ្ងៃ
តែងមើលផ្លូវបា ៗ

ឯកែសរកសី ជារាជបុត្រី តើនៅឯណា
ក្រែងមួយជាទុក្ខ អផ្សុកអង្គា ឬមួយនៅជា
ហើយថ្វីពុំមក ៗ

បាទៅនេះណា សង្វាតយាត្រា ប៉ុនប៉ង់ទៅរក
ព្រះជនកក្សត្រា មាតាពន្ធក ហេតុម្ដេចមិនយក
ពលៈរេហ៍មកផង ៗ

ព្រះពោធិសត្វ ក្រញ្ញក្រាបប្រណិបតន៍ បង្គំទូលស្នង
ប្រាប់ពី តាកយ៉ាក លំបាកក្ដីហោង សមុទ្រនោះផង
ព្រាត់ប្រាសទឹងគ្នា ៗ

កាលណោះព្រះបាទ សោទត្តនរនាថ ស្តាប់បុត្រប្រសា
ស្តេចទ្រង់ព្រះកន្សែង ថ្ងូនថ្ងែងសោកា ពិលាបមហិមា
អាណិតពេកក្រៃ ។

ស្រេចហើយព្រះអង្គ បន្ទោរសោកបង់ ស្រាន្តស្រាលហឫទ័យ
បង្គំក្រាបលា ក្សត្រាជៀសជ្ជ័យ ស្តេចទៅសួរទ័យ
បាក្មេកមួយណា ។

ស្តេចកាន់កែវហោះ រំពេចផ្ទុកផ្ទោះ ដល់ដូចចិន្តា
បានថ្វាយបង្គំ ប្រណម្យវន្ទា បាក្មេកនោះណា
សឹងសួរដំណឹង ។

ពោធិសត្វប្រាប់ ទៀងទូលរៀបរាប់ ដំណើរដំបង
កាលពីព្រាត់ប្រាស ទឹកសបផ្សែងផ្សែង ក្តៅក្តាត់កទ្រូង
សង្រេងខ្លោចផ្សា ។

មហាក្សត្រស្តេចស្តាប់ ពោធិសត្វប្រាប់ ស្តេចសោយសោកា
អនាថអាណិត គន់គិតអនិច្ចា ពិលាបក្តាត់ណា
ថ្មើមថ្ងៃពុំបាន ។

ស្រេចហើយមហាក្សត្រ បន្ទោរសោកថ្កាត់ ហឫទ័យស្រាកស្រាន្ត
បន្ទូលមេត្រី ស្រដីក្សេមក្សាន្ត សោមនស្សសោតបាន
ចិត្តដូចចិន្តា ។

ពោធិសត្វទូល បពិត្រឥសូរ ត្រើយត្រៃលោកា
ខ្ញុំមកសូមពល សកលយោធា ហើយសុំគេត្រា
ទាំងប្រាំរយផង ។
បាក្រេកឆ្លើយថា កូនអើយចូរបា យកដូចបំណង
ស្រុកនេះឪពុក ឲ្យបាឯងគ្រង បាគិតត្វីហោង
តាមចិត្តប្រាថ្នា ។
កាលណោះព្រះអង្គ ព្រះបាទវរវង្ស បង្គំក្រាបលា
ពលប្រាំរយនោះ ឲ្យចុះគេត្រា ស្រេចស្តេចលីលា
ទៅជ័យបុរី ។
ស្តេចឡើងទៅថ្វាត់ ចូលទូលមហាក្សត្រ សោទត្តធិបតី
សូមអស់យោធា សេនាមន្ត្រី ទាហានសេនីយ
ពលពាលអាសា ។
ហើយសូមសំពៅ ប្រដាប់ទឹងទៅ នគរសេមា
ប្រុងប្រៀបស្រាប់ស្រេច ស្អែកស្តេចក្រាបលា ព្រះវរបិតា
ធិកជះជៀសស្ជ័យ ។
បពិត្រព្រះអង្គ សូមទានស្តេចគង់ ក្សេមក្សាន្តហឫទ័យ
ខ្ញុំទៅនគរ បវរនាយទៃ សួគិមាគាល័យ
សមយូរហោងណា ។

នាងរេនវតី ព្រះរាជបុត្រី សូមបានក្រាបលា
ឲ្យបានទៅដល់ យន់យល់មាតា ហើយនឹងបិតា
វិលវិញមកវិញ ។

កាលណោះព្រះបាទ សោទត្តនរាធ ឥស្សរាធិបតី
ព្រះអង្គធិរាជ ពុំអាចដើម្បី ឃាតខាំងបុត្រី
ដល់តិចឡើយណា ។

ស្តេចបន្ទូលថាត់ ថាហៃកូនរេ្ន បាបុត្រប្រុសា
ឪពុកពុំឃាត់ តាមចិត្តបាណា ទៅហោះចូរបា
វិលវិញមកឆាប់ ។

ឪពុកបានបា ជាកូនប្រុសា ហោះមកមានគំនិត
បាដោះឪពុក ពីទុកនឹងហ្វាប់ បាមានគុណណាស់
នឹងឪពុកក្រែ ។

ស្តេចផ្តាំបុត្រី ហៃរេ្នវតី ពន្ធកហាប់ចយ
មាសមេកុំព្ធោយ ដើរដោយផ្លូវព្រៃ ប្រណិប័តន៍ក្សត្រថ្ងៃ
តម្លង់ក្រឡា ។

បើមេទៅដល់ បរិបូណ៌បានយល់ កន្ទាន់នរេណា
ចូរមេប្រណិបតន៍ នូវនិត្យគេក្យា បម្រើលោកជា
បាកេ្កមេហោង ។

បើបាក្មេកប្រើ　　ម្ដេចៗចូរធ្វើ　　ពិតពុំឲ្យហួស
ចូរមេបម្រើ　　កុំធ្វើឲ្យឆ្គង　　ទីងអស់ក្រស្ដផង
នូវខ្ញុំបម្រើ　　ៗ

បើប្ដីស្នេហា　　ទីងអ្នកឯណា　　កុំធ្វើឲ្យហួស
ចូរមេស្រដី　　បំពេញប្ដីផង　　ពោះបីឆ្គាំឆ្គង
មើលឲ្យល្ហក់ល្ហម　　ៗ

ពោះបើស្នេហា　　ទីងអ្នកឯណា　　កុំធ្វើទីងព្រម
ចូរមេទៀងទូល　　បង្គូលចិត្តស្ងួម　　មេមើលឲ្យល្ហម
ទូលពាស់ផ្ទាសឆ្លើយ　　ៗ

ហៃបងឧត្តម　　កុំបីមេផ្ដុំ　　ផ្ដល់ផ្ដុំមកសកើយ
ប្រមាថអ្នកជា　　ស្វាមីនេះហើយ　　បុណ្យអ្នកជាត្រើយ
គ្រាណាត្រើយលោកផង　　ៗ

ព្រះបាទសោទត្ត　　ផ្ដែផ្ដាំកូនវេត្ត　　ពិតពុំឲ្យឆ្គង
នាងសោភអរទុខ　　លំពោខត្រង់វង　　ទូន្មានទោះផង
ទុកលើសិរសា　　ៗ

ស្រេចហើយព្រះអង្គ　　ព្រះបាទវរវង្ស　　បង្គំក្រាបលា
នាងនាថមហេសី　　ក្សត្រីថ្ងៃថ្លា　　បរបុះកេត្រា
បើកទៅបុរី　　ៗ

ស្តេចបើកគេត្រា លុះអំលុងជា ខែបីបានដល់
ពិភពទិព្វឋាន ក្សេមក្សាន្តសុខសល់ ស្តេចឡើងទៅដល់
ព្រះរៀមនោះហោង ៗ
ព្រះរៀមអនុជា សំណេះចរចា ទៅមកស្នេហ៍ស្នង
សារស័ព្ទទទួល ស្រាកស្រួលឥតហ្មង មូលមិត្រហើយហោង
ដូចព្រះចិន្តា ៗ
នាងកែសកេសី នាងរត្នវតី ជួបបួលជានា
ប្រាប់ពីព្រាត់ប្រាស និរាសទឹងគ្នា សឹងសោយកេសា
ទុនទុបទៅមក ៗ
រីព្រះរាជបុត្រ ពិសេសបរិសុទ្ធ ថ្ងើមថ្ងៃពន្លក
នាងរត្នវតី មេត្រីយោនយក រាជបុត្រនោះមក
បីថ្នមទុបអង្គ ៗ
ហើយនាងទូញថា ឱបុត្រពុំងា ត្រកូលភូជពង្ស
ម្តាយបានយង់យល់ ហេតុផលអស់ហ្នឹង ជូនជួយផ្គត់ផ្គង់
ពិភ័ក្តិរក្សា ៗ
ឪពុកបាមិញ ប្រាសព្រាត់ខ្ចាយចេញ ពុំយល់ឡើយណា
ម្តាយបាសោតព្រាត់ ខ្ចាយខ្ចាត់ឃ្លាតឃ្លា ត្រមោចតែបា
ឯកឯងឥតត្រើយ ៗ

(នៅមានត)

**ផ្នែកកំណត់-ប្រវត្តិការណ៍**

# អង្គការអន្តរជាតិខាងវិប្បធម៌

# បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើប្រាសាទអង្គរ

ដោយ លី - ធាមតេង

យើងនៅចាំច្បាស់ថា សត្រូវខ្មែរយើង គឺយួនវៀតកុង-វៀតមិញ បានរុករានទន្ទ្រានចូលខេត្តសៀមរាប ចាប់តាំងពីថ្ងៃទី ៦ មិថុនា ហើយបាននាំគ្នាចូលទៅកកត្បាត ក្នុងប្រាសាទអង្គរវត្ត និងប្រាសាទនានាទៀតនៅក្នុងខេត្តសៀមរាប ដូចជាក្នុងបាខែង បាយ័ន ព្រះខ័ន បន្ទាយស្រី និងប្រាសាទលលៃ ជាដើម ។

រដ្ឋាភិបាលខ្មែរយើង បានធ្វើសេចក្តីប្រកាសមួយ ប្តឹងដល់មតិសកលលោកអំពីការឈ្លានពាននៃពួកសត្រូវ ដែលបំពារបំពានចូលមកប្រាសាទអង្គរ ដែលសកលលោកចាត់ទុកជាបេតិកភណ្ឌវប្បធម៌របស់មនុស្សជាតិទាំងមូល ។ សេចក្តីប្រកាសនេះ ចេញនៅថ្ងៃ ១១ មិថុនា ១៩៧០ ដូចយើងបានចុះផ្សាយក្នុងលេខមុនរួចមកហើយ ។

ឯលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ អ៊ូ-ថាន់ ក៏បានធ្វើសេចក្តីអំពាវនាវមួយពីថ្ងៃទី ៨ មិថុនា ១៩៧០ ភ្លាមដែរ ដើម្បី

ឲ្យមតិសាកលលោកចាប់អារម្មណ៍ទៅលើបញ្ហាការពារកេរ្តិ៍ប្រាសាទអង្គររបស់ខ្មែរយើង ។ បន្ទាប់ពីនេះមក អង្គការយូណេស្កូ ដែលជាសាខារបស់អង្គការសហប្រជាជាតិ ផ្នែកខាងវប្បធម៌ ក៏បានកោះប្រជុំគណៈកម្មការប្រតិបត្តិការណ៍របស់ខ្លួន ដើម្បីពិភាក្សាគ្នាអំពីមធ្យោបាយការពារថែទាំប្រាសាទបុរាណរបស់ខ្មែរយើងនេះទៀត ។ ហេតុដែលនាំឲ្យអង្គការនេះ ចាត់ចែងការយ៉ាងសកម្មដូច្នេះ ព្រោះកាលពីឆ្នាំ ១៩៥៤ ប្រទេសនានាចំនួនជាង ៨០ បានប្រជុំគ្នានៅទីក្រុងឡាហេ ប្រទេសហូលឡង់ សម្រេចចិត្តបង្កើតជាច្បាប់មួយឲ្យឈ្មោះថា « អនុសញ្ញាអន្តរ-ជាតិ ស្តីពីកិច្ចការពារសម្បត្តិវប្បធម៌ ក្នុងករណីមានសង្គ្រាម » ។ ច្បាប់នោះ បានទុកមុខងារជាទូកចាត់ចែងការ ក្នុងរបៀបចាត់ការ និងកិច្ចការពារនេះ ទៅលើអង្គការ «យូណេស្កូ» ។ ច្បាប់នេះឯង បានដៅយ៉ាងច្បាស់អំពីវត្ថុដែលហៅថា សម្បត្តិវប្បធម៌នោះ គឺមានវត្តអារាម ប្រាសាទបុរាណ ទីទុកឯកសារផ្សេងៗ ឬទីតាំងបុរាណវត្ថុនានា ដូចជាសារមន្ទីរ បណ្ណាល័យ ។ល។

ដោយអំណាចអនុសញ្ញាអន្តរជាតិនេះ អង្គការយូណេស្កូ ក៏បានចាត់ការប្រជុំសមាជិករបស់ខ្លួន ហើយរិះរកវិធានការជួយអនុគ្រោះទីតាំងប្រាសាទខ្មែរយើង ឲ្យបានគង់វង្សក្នុងពេលមានសង្គ្រាមចូលមកយាយីដល់ទីកន្លែង ។

យើងសូមបញ្ជាក់ថា ក្នុងពេលនេះអង្គការវប្បធម៌នានាក្នុងស្រុកយើងដូចជាសមាគមអ្នកនិពន្ធខ្មែរជាដើម បានធ្វើសេចក្តីអំពាវនាវមួយចំពោះមតិអ្នកនិពន្ធ អ្នកអក្សរសាស្ត្រ អ្នកវប្បធម៌ទាំងអស់ក្នុងសកលលោក សូមឲ្យជួយចាប់អារម្មណ៍ឲ្យខ្លាំងក្លា និងសូមជួយធ្វើអន្តរាគមន៍ចំពោះរដ្ឋាភិបាលរៀងខ្លួន ពិសេសអ្នកនិពន្ធអ្នកអក្សរសាស្ត្រ នៃប្រទេសដែលបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិនៅក្រុងឡាហេពីឆ្នាំ ១៩៥៤ សូមឲ្យជួយដោះស្រាយជាបន្ទាន់កុំឲ្យខ្មាំងសត្រូវរបស់ខ្មែរគឺវៀតកុង-យួនខាង-ជើង ប្រព្រឹត្តរំលោភលើបេតិកភណ្ឌវប្បធម៌របស់មនុស្សជាតិ គឺប្រា-សាទបុរាណខ្មែរនៅទីក្រុងអង្គរ ព្រមទាំងអំពាវនាវចំពោះអង្គការយូណេ-ស្កូ សូមចាត់ការតាមសមត្ថកិច្ចរបស់ខ្លួន ឲ្យត្រូវតាមអនុសញ្ញាអន្តរជាតិនេះផង ។

បន្តមក អង្គការយូណេស្កូ ក៏សម្រេចចិត្តភ្លាមតាំងជាវិធានការទប់ទល់និងការពារបុរាណវត្ថុរបស់ខ្មែរ ។ អង្គការនេះ បានចាត់អ្នកជំនាញការម្នាក់គឺលោក វ៉ាឌីម អេលីស៊ីហ្វ ជាតិបារាំង ឲ្យធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ពិនិត្យឲ្យឃើញច្បាស់ និងផ្តល់មតិផ្សេងៗចំពោះអ្នកមានសមត្ថកិច្ចក្នុងនាទីការពារបុរាណវត្ថុរបស់យើង ។ ស្របជាមួយពេលនេះ រដ្ឋាភិបាលខ្មែរក៏បានតែងតាំងគណៈកម្មាធិការមួយឡើងភ្លាមតម្រូវតាមឧបញ្ញត្តិដែលមានចែងអនុសញ្ញាអន្តរជាតិនោះ សម្រាប់ទទួល

មុខងារពាក់ព័ន្ធការនេះពិសេសដោយឡែក អមជាមួយអង្គការអន្តរជាតិដែលចូលមកជួយធ្វើអន្តរាគមន៍ផង ។ គណៈកម្មាធិការនេះ មាននាមថា " គណៈកម្មាធិការជាតិខាងកិច្ចការពារសម្បត្តិវប្បធម៌ " ។ អង្គការទាំងនេះបានពាក់ព័ន្ធការយ៉ាងស្រួចទៅតាមសមត្ថភាពរបស់ខ្លួន ក្នុងរយៈពេលក្លាមៗ ក្រោយដែលតែងតាំងហើយ ។

យើងគួរកត់សម្គាល់ថា ប្រទេសនានាដែលជាសមាជិកប្រតិបត្តិការរបស់យូណេស្កូ ដែលបានបើកពេលប្រជុំពិសេសនៅក្រុងប៉ារីសកាលពីថ្ងៃទី ១៨ មិថុនា ១៩៧០ ហើយបានពិនិត្យសេចក្ដីស្នើរបស់ប្រតិភូប្រទេសបារាំង ឥណ្ឌា ប៉ាគីស្ថាន និង ជប៉ុន ហើយឲ្យសច្ចានុម័តសម្រាប់យកទៅប្រតិបត្តផងនោះ មានៈ ប្រទេសអ៊ីតាលី ជាប្រធាន, ឆេកូស្លូវ៉ាគី, ឥណ្ឌា, គង់ហ្គូទី និង ប៉េរូជាអនុប្រធាន, និងមានសមាជិកដូចតទៅៈ ម៉េចស៊ិក, អូស្រ្តាលី, ម៉ាលី, ស៊ូស, ប្រេស៊ិល, ស៊ីលី ទីហ្សេរីយ៉ា, គុយ្យូបា, អាហ្វ្រិចទិន, បារាំង, លង្កា, អាហ្វហ្គានីស្ថាន, សហរដ្ឋអាមេរិក, អេត្យូពី, ហុំងឡង់, ប៉េអ៊ីបា, ហុងគ្រី, កូស្តារីកា, គុងហ្គូប្រាហ្សាវីល, ចក្រភពអង់គ្លេស, សេណេហ្កាល, កាណាដា, ហ្សុំប៊ី, អាក់ចរូម, លីបង់, ប៉ាគីស្ថាន, អាល់ហ្សេរី, ជប៉ុន និង សហភាពសូវៀត ។

នៅក្នុងរយៈពេលប្រហាក់ប្រហែលគ្នានេះ "សាលាបារាំងសែសនៅចុងបូព៌ាប្រទេស" ដែលជាមជ្ឈមណ្ឌលស្រាវជ្រាវដ៏ចំណាស់មួយហើយដែលជាអ្នករួមធ្វើសហការក្នុងកិច្ចការស្រាវជ្រាវ-ជួសជុលប្រាសាទបុរាណនានានៅអង្គរជាច្រើនឆ្នាំមកហើយផងនោះ, បានធ្វើសេចក្ដីអំពាវនាវជាសាកលមួយទៀត ដាស់សតិស្មារតីអន្តរជាតិឲ្យរឹងរឹតតែយកចិត្តទុកដាក់លើកិច្ចការពារប្រាសាទនិងបុរាណវត្ថុទាំងអស់នៅប្រទេសកម្ពុជា ដែលកំពុងមានភយន្តរាយ ដោយសារពួកសត្រូវយោធានិយម ចក្រពត្តិនិយមយៀកកុង-យៀកមិញ ឈ្លានពានក្នុងពេលនេះ ជាហេតុជួយឲ្យអ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រខាងការស្រាវជ្រាវបុរាណវត្ថុចាប់ចិត្តគិតគូរខ្លាំងឡើង ថែមមួយកម្រិតទៀត ។

យើងជាអ្នកវប្បធម៌បានតាមដានយ៉ាងយកចិត្តទុកដាក់បំផុតក្នុងរឿងនេះ ទោះបីជាបានផ្សាយសេចក្ដីអំពាវនាវទៅគ្រប់អង្គការ នៅគ្រប់ប្រ-ទេសដែលជាសមាជិកអង្គការយូណេស្កូ ពិសេសប្រទេសដែលបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិនៅទីក្រុងឡាហេ ឆ្នាំ ១៩៥៤ ហើយក៏ដោយ ។

មកដល់ខែកក្កដានេះ យើងបានទទួលដំណឹងដ៏ជាទីពេញចិត្តមួយទៀត ព្រោះអង្គការអក្សរសាស្ត្រអន្តរជាតិដែលមាននាមជាអក្សរកាត់ថា : PEN, (ប៉េន) គឺបានន័យថា=Poète: អ្នកកវី, Essayiste: អ្នកប្រលោមលោក

Nouvelliste : អ្នកតែងរឿងនិទានកថា ។ អង្គការនេះ បានបើកសម័យប្រជុំសមាជអន្តរជាតិលើកទី ៣៧ របស់ខ្លួននៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង ក្នុងពេលថ្មីៗនេះ បានលើកយកបញ្ហាការពារប្រាសាទបុរាណខ្មែរយើង ទៅចុះក្នុងរបៀបវារៈ ហើយបានធ្វើការពិភាក្សាយ៉ាងហ្មត់ចត់ រហូតដល់ចុះបញ្ហានេះក្នុងសេចក្ដីសម្រេចចិត្តរបស់សមាជគេ ដើម្បីផ្សាយជាសាកលថែមទៀត ។ ចំពោះចំណុចនេះ យើងខ្មែរអ្នកវប្បធម៌ទាំងអស់ សូមថ្លែងអំណរគុណពីចម្ងាយ ជូនចំពោះអស់លោកអ្នកនិពន្ធ និង កវី នៃប្រទេសជាមិត្តទាំងអស់ ដែលបានជួយឈឺឆ្អាលលើកយកបញ្ហាប្រទេសយើងទៅពិភាក្សាយ៉ាងសកម្ម ។

សរុបសេចក្ដីទៅ យើងយល់បានយ៉ាងច្បាស់ថា: សកម្មភាពទាំងប៉ុន្មាន ដែលរដ្ឋាភិបាលយើង បានប្រកាសទៅហើយ និង មានអង្គការវប្បធម៌ក្នុងស្រុកយើងជួយបន្ថែមផងទៀតនោះ ពិតជាមានប្រសិទ្ធិភាពធ្វើឱ្យមតិសកលលោកភ្ញាក់ផ្អើលឈូងរមែន ជាភស្តុតាងដូចយើងបានចង្អុលបង្ហាញរួចមកហើយ ក្នុងអត្ថបទនេះស្រាប់ ។ ត្រង់នេះទៀតបញ្ជាក់ថា៖ ប្រាសាទអង្គរមិនត្រឹមតែជាសិល្បកម្មរបស់ខ្មែរតែប៉ុណ្ណោះទេ, ថែមទាំងសកលលោកទទួលទុកជាបេតិកភណ្ឌវប្បធម៌របស់មនុស្សជាតិទាំងមូល ជាពិតប្រាកដណាស់ទៀតផង ។